ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម

# INTEGRATION OF MOTHER TONGUE IN TEACHING AND LEARNING ENGLISH AT SECONDARY SCHOOL IN KAMPONG CHAM PROVINCE

ដោយ/By

ហៀង ណេន/HEANG NEN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម

# INTEGRATION OF MOTHER TONGUE IN TEACHING AND LEARNING ENGLISH AT SECONDARY SCHOOL IN KAMPONG CHAM PROVINCE

ដោយ/By

ហៀង ណេន/HEANG NEN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោល ៖ បណ្ឌិត អ៊ុំ ចាន់ចំណាន

គ្រូណែនាំរង ៖ លោកស្រី សុខ វណ្ណា

# សេចក្ដីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជា បានសិក្សាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣ កើត ខែ កត្តិក ឆ្នាំខាលចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

**ហត្ថលេខាបេក្ខជន**

**ហៀង ណេន**

# លិខិតបញ្ជាក់

| | | |
|---|---|---|
| បណ្ឌិត | **អ៊ុំ ចាន់ចំណាន** | ជាគ្រូណែនាំគោល |
| លោកស្រី | **សុខ វណ្ណា** | ជាគ្រូណែនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ហៀង ណេន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣ កើត ខែ កត្តិក ឆ្នាំខាលចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

| | |
|---|---|
| ........................................................ | ........................................................ |
| **បណ្ឌិត អ៊ុំ ចាន់ចំណាន** | **លោកស្រី សុខ វណ្ណា** |
| គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសមានគណៈកម្មការមេប្រយោគសម្រាប់ការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣០២៥ អយក.ខុទក

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉ែយ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ រិភា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្សា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនីន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រ៉ាវ

# លិខិតឧទ្ទេសមានគណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ...៣៧២៦.អយក.ទទន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម ភ័ន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ធី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ជាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ខិ៍ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វេដអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក និងអ្នកម្តាយជាទីគោរពស្រឡាញ់បំផុត ដែលផ្តល់ឱ្យរូបកូនបានឃើញនូវពិភពលោកដ៏ស្រស់បំព្រងមួយនេះ រួមនិងការចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុង គាំទ្រ លើកកម្លាំងចិត្ត និងផ្តល់ឱកាសដល់រូបខ្ញុំបាទឲ្យទទួលបានការសិក្សាគ្រប់កម្រិតសិក្សា ហើយខ្ញុំបាទសូមថ្លែងអំណរគុណដល់បងប្អូនប្រុសស្រីដែលតែងតែផ្តល់ការប្រឹក្សាយោបល់ដល់រូបខ្ញុំបាទ និងក្មួយៗដែលតែងតែផ្តល់កម្លាំងចិត្តនៅក្នុងការបន្តការសិក្សាមួយនេះ។

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំ និងផ្តល់នូវអាហារូបករណ៍ ក៏ដូចជាផ្តល់ឱកាសឱ្យខ្ញុំបាទបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ សម្រាប់ឆ្នាំសិក្សា ២០២០-២០២២។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មការគ្រប់គ្រងវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកគ្រូ អ្នកគ្រូដែលជាគ្រូឧទ្ទេសទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុតក្នុងការបង្ហាត់បង្រៀន ការណែនាំ និងផ្តល់អនុសាសន៍ល្អៗដល់ក្រុមនិស្សិតទាំងអស់គ្នានាពេលកន្លងមក។ ជាពិសេសខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះ **លោកបណ្ឌិត អ៊ុំ ចាន់ចំណាន** ដែលជាគ្រូណែនាំគោល សម្រាប់ការសរសេរនិក្ខេបបទនេះ ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយពន្យល់ណែនាំបង្ហាញផ្លូវដារៀងរហូតមក ធ្វើឲ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ និងបញ្ចប់ប្រកបដោយភាពរលូន។ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកស្រី សុខ វណ្ណា** ជាគ្រូណែនាំរងដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃ ជួបពិភាក្សា ពន្យល់ណែនាំ និងជំរុញលើកទឹកចិត្តឱ្យខិតខំប្រឹងប្រែងក្នុងការសរសេរនិក្ខេបបទនេះ។ ក្នុងនោះផងដែរ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះ **លោកបណ្ឌិត ឈន ថន** ដែលជាគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ ដែលតែងតែផ្តល់នូវអនុសាសន៍ល្អៗ និងណែនាំដល់រូបខ្ញុំបាទ ទាក់ទងទៅនឹងប្រធានបទនៃការស្រាវជ្រាវនេះ។ បន្ថែមទៅទៀត ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់មិត្តរួមជំនាន់ទាំងអស់ដែលបានផ្តល់នូវការសហការណ៍ ការពិភាក្សា ការប្រឹក្សាយោបល់

ក៏ដូចជាការជំរុញលើកទឹកចិត្តដល់រូបខ្ញុំរហូតដល់ការបញ្ចប់ការសិក្សានេះ ហើយខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅតាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត ព្រមទាំងជួយសម្រួល និងធ្វើការសហការណ៍ដល់ការចុះប្រមូលទិន្នន័យឱ្យមានភាពងាយស្រួល និងសម្រេចបានជោគជ័យ។

ជាចុងក្រោយ ខ្ញុំបាទសូមគោរពបួងសួងដល់ទេវតាឆ្នាំថ្មី សូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ លោក-លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ ទទួលបាននូវសុភមង្គលគ្រប់ក្រុមគ្រួសារ ដោយសូមឱ្យមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ប្រកបការងារប្រចាំថ្ងៃទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

សេចក្តីអះអាងរបស់បេក្ខជន ....... i
លិខិតបញ្ជាក់ ....... ii
លិខិតឧទ្ទេសមានគណៈកម្មការមេប្រយោគសម្រាប់ការការពារនិក្ខេបបទ ....... iii
លិខិតឧទ្ទេសមានគណៈកម្មការការពារនិក្ខេបបទ ....... iv
សេចក្តីថ្លែងអំណរគុណ ....... v
បញ្ជីតារាង ....... x
បញ្ជីក្រាប ....... xi
បញ្ជីអក្សរកាត់ ....... xii
មូលន័យសង្ខេប ....... xiii
ជំពូក ១ ៖ សេចក្តីផ្តើម ....... 1
១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ....... 1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ....... 4
១.៣ គោលបំណងនៃការស្រាវជ្រាវ ....... 5
១.៤ សំណួរស្រាវជ្រាវ ....... 5
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ....... 5
១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ....... 6
១.៦.១- ប្រជាជន និងភាគសំណាក ....... 6
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... 6
ជំពូក ២ ៖ រំលឹកទ្រឹស្តី ....... 8
២.១ និយមន័យនៃពាក្យគន្លឹះ ....... 8
២.២ កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ....... 9
២.៣ ការប្រើប្រាស់ភាសាកំណើតក្នុងថ្នាក់រៀនភាសាអង់គ្លេស ....... 12
២.៣.១ ការប្រើប្រាស់ភាសាកំណើតរបស់គ្រូបង្រៀនក្នុងថ្នាក់ភាសាអង់គ្លេស ....... 15
២.៣.២ ការប្រើប្រាស់ភាសាកំណើតរបស់សិស្សក្នុងថ្នាក់ភាសាអង់គ្លេស ....... 16

**២.៤ សារៈសំខាន់នៃភាសាកំណើតនៅក្នុងការអប់រំ** ........ 17

**២.៥ ឥទ្ធិពលអវិជ្ជមាននៃភាសាកំណើតចំពោះការរៀនភាសាអង់គ្លេស** ........ 20

**២.៦ ផលវិបាកនៃការប្រើតែភាសាអង់គ្លេសដើម្បីបង្រៀន និងរៀនភាសាអង់គ្លេស** ........ 21

**ជំពូក ៣ ៖ វិធីសាស្ត្រស្រាវជ្រាវ** ........ 25

**៣.១ គម្រោងវិភាគ** ........ 25

**៣.២ ការប្រមូលទិន្នន័យ** ........ 25

**៣.៣ ឧបករណ៍ស្រាវជ្រាវ** ........ 26

៣.៣.១ កម្រិតចង្អុលបង្ហាញ ........ 27

៣.៣.២ កម្រងសំណួរ ........ 28

**៣.៤ ការជ្រើសរើសភាគសំណាក** ........ 30

**៣.៥ ការវិភាគទិន្នន័យ** ........ 31

**ជំពូក ៤៖ លទ្ធផល និងការពិភាក្សា** ........ 32

**៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ ស្តីពីព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន និងសិស្សានុសិស្ស** ........ 32

៤.១.១ ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន ........ 33

៤.១.២ ព័ត៌មានប្រជាសាស្ត្ររបស់សិស្ស ........ 34

**៤.២ ទិន្នន័យឆ្លើយតបលើការប្រើប្រាស់ភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ** ........ 35

៤.២.១ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការប្រើប្រាស់ភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា ........ 35

៤.២.២ ទិន្នន័យឆ្លើយតបរបស់សិស្សលើការប្រើភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា ........ 48

**៤.៣ ការពិភាក្សាលើលទ្ធផល** ........ 61

៤.៣.១ លទ្ធផលនៃការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សលើការប្រើភាសាខ្មែរ ........ 61

៤.៣.២ លទ្ធផលនៃប្រើភាសាអង់គ្លេស និងភាសាខ្មែររបស់គ្រូបង្រៀន និងសិស្ស ........ 62

**ជំពូក ៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 64

**៥.១ សេចក្តីសន្និដ្ឋាន** ........ 64

**៥.២ សំណូមពរ** ........ 65

ក. ក្រសួងអប់រំយុវជន និងកីឡា ........ 65

ខ. មន្ទីរអប់រំ យុវជន និងកីឡា/ក្រុង ........ 66

គ. សម្រាប់នាយកសាលា ........ 66

ឃ. សម្រាប់គ្រូបង្រៀន ........ 66

ង. សម្រាប់សិស្ស ........ 67

ច. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត ........ 67

**ឯកសារយោង** ........ 68

**ឧបសម្ព័ន្ធ** ........ 72

ឧបសម្ព័ន្ធ (ក) កម្រងសំណួរសម្រាប់គ្រូបង្រៀន ........ 72

ឧបសម្ព័ន្ធ (ខ) តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន ........ 77

ឧបសម្ព័ន្ធ (គ) កម្រងសំណួរសម្រាប់សិស្ស ........ 79

ឧបសម្ព័ន្ធ (ឃ) តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់សិស្ស ........ 84

ឧបសម្ព័ន្ធ (ង) លិខិតចុះប្រមូលទិន្នន័យអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា ........ 86

ឧបសម្ព័ន្ធ (ច) លិខិតចុះប្រមូលទិន្នន័យ អនុញ្ញាតដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ... 87

ឧបសម្ព័ន្ធ (ឆ) លិខិតឧទ្ទេសនាមចាត់តាំងគ្រូណែនាំគោល និងគ្រូណែនាំរង ........ 88

ឧបសម្ព័ន្ធ (ជ) លិខិតបង្គាប់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់ ........ 91

# បញ្ជីតារាង


| តារាង | បរិយាយ | ទំព័រ |
|---|---|---|
| ២.១ | បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃភាសាកំណើត | 23 |
| ៣.១ | ភាគសំណាកនៃការស្រាវជ្រាវ | 30 |
| ៤.១ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាសភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស | 35 |
| ៤.២ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការជួយសិស្សរៀនបំណិនភាសា | 38 |
| ៤.៣ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសា | 39 |
| ៤.៤ | ការយល់ឃើញរបស់គ្រូទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស | 39 |
| ៤.៥ | ការយល់ឃើញរបស់គ្រូចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀន | 40 |
| ៤.៦ | ទិន្នន័យសរុប ការយល់ឃើញរបស់គ្រូបង្រៀនលើការប្រើប្រាស់ភាសាខ្មែរក្នុងបង្រៀននិងរៀនភាសាអង់គ្លេស | 41 |
| ៤.៧ | ការយល់ឃើញរបស់សិស្សទាក់ទងនឹងការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេស | 48 |
| ៤.៨ | ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនភាសាអង់គ្លេស | 51 |
| ៤.៩ | ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសា | 52 |
| ៤.១០ | ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសា | 52 |
| ៤.១១ | ការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស | 53 |
| ៤.១២ | ទិន្នន័យសរុប ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងបង្រៀននិងរៀនភាសាអង់គ្លេស | 54 |

# បញ្ជីក្រាប


| ក្រាប | បរិយាយ | ទំព័រ |
|---|---|---|
| ៤.១ | រង្វាយតម្លៃរបស់គ្រូបង្រៀនលើកម្រិតនៃការយល់ដឹងភាសាអង់គ្លេសរបស់សិស្ស | 43 |
| ៤.២ | កម្រិតនៃការប្រើភាសាអង់គ្លេសនិងភាសាខ្មែររបស់គ្រូបង្រៀននៅក្នុងថ្នាក់ភាសាអង់គ្លេស | 44 |
| ៤.៣ | ការយល់ឃើញរបស់គ្រូបង្រៀនទៅលើកម្រិតនៃការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស | 45 |
| ៤.៤ | ទំនាក់ទំនងរវាង កម្រិតនៃការបង្រៀន និងការប្រើភាសាអង់គ្លេស-ខ្មែរ | 46 |
| ៤.៥ | ទំនាក់ទំនងរវាង បទពិសោធនៃការបង្រៀនភាសាអង់គ្លេស និងកាប្រើប្រាស់ភាសាអង់គ្លេស-ភាសាខ្មែរ | 47 |
| ៤.៦ | កម្រិតនៃការយល់ដឹងភាសាអង់គ្លេសរបស់សិស្សនៅពេលគ្រូប្រើភាសាអង់គ្លេស | 56 |
| ៤.៧ | កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែររបស់សិស្សនៅក្នុងថ្នាក់រៀន | 57 |
| ៤.៨ | ទំនាក់ទំនងរវាងកម្រិតថ្នាក់នៃការរៀនភាសាអង់គ្លេសនិងការប្រើប្រាស់ភាសាអង់គ្លេស-ខ្មែរ | 58 |
| ៤.៩ | កម្រិតភាគរយនៃការយល់ នៅពេលគ្រូបង្រៀននិយាយភាសាអង់គ្លេសធៀបទៅតាមកម្រិតថ្នាក់ | 59 |
| ៤.១០ | ការយល់ឃើញរបស់សិស្សានុសិស្សទៅលើកម្រិតនៃការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស | 60 |

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| វិ.ហស ជើងធ្នុក | : | វិទ្យាល័យហ៊ុនសែន ជើងធ្នុក |
| វិ.សតជ សង្កើប | : | វិទ្យាល័យសម្ដេចអគ្គមហាសេនាបតី ហ៊ុនសែន សង្កើប |
| វិ.សតជ បាជាយ | : | វិទ្យាល័យសម្ដេចអគ្គមហាសេនាបតី ហ៊ុនសែន បាជាយ |
| វិ.ហណ ព្រៃញា | : | វិទ្យាល័យហោណាំហុង ព្រៃញា |
| វិ.សតជ សណ្ដែក | : | វិទ្យាល័យសម្ដេចអគ្គមហាសេនាបតី ហ៊ុនសែន សណ្ដែក |
| អនុ. ច្បារអំពៅ | : | អនុវិទ្យាល័យ ច្បារអំពៅ |
| អនុ. ជាលា | : | អនុវិទ្យាល័យ ជាលា |
| អនុ. សេរិចំប៉ាមេព្រីង | : | អនុវិទ្យាល័យ សេរីចំប៉ាមេព្រីង |
| អនុ. គ្រប់ | : | អនុវិទ្យាល័យ គ្រប់ |
| អនុ. ទំនប់ | : | អនុវិទ្យាល័យ ទំនប់ |
| អនុ. ជើងព្រៃ | : | អនុវិទ្យាល័យ ជើងព្រៃ |
| អនុ. តាំងក្រសាំង | : | អនុវិទ្យាល័យ តាំងក្រសាំង |
| L1 | : | First Language |
| L2 | : | Second Language |
| EFL | : | English as a Foreign Language |

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវពីការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា នៅក្នុងខេត្តកំពង់ចាម មានគោលបំណងសិក្សាស្វែងយល់ពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀននិងសិស្សានុសិស្ស និងកម្រិតនៃការប្រើប្រាស់នៃភាសាកំណើត នៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេស។

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ គឺអនុវត្តតាមបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យ គឺតាមរយៈកម្រងសំណួរដោយធ្វើឡើងនៅវិទ្យាល័យចំនួន ០៥ និងអនុវិទ្យាល័យចំនួន ០៧ នៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ដែលមានចំនួនសំណាកសរុប ២៩២នាក់ ក្នុងនោះលោកគ្រូ-អ្នកគ្រូមានចំនួន ៤២នាក់ និងសិស្សានុសិស្សមានចំនួន ២៥០នាក់។ ការវិភាគទិន្នន័យ គឺសិក្សាលើចំនួនមធ្យមភាគ និងចំនួនភាគរយនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ០៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សនៅខេត្តកំពង់ចាម យល់ថាភាសាខ្មែរគឺជាផ្នែកមួយដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ ក្នុងនោះគ្រូបង្រៀនចូលចិត្តប្រើប្រាស់ទាំងភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងការបង្រៀន។ គ្រូបង្រៀនប្រើប្រាស់ភាសាខ្មែរដើម្បីពន្យល់គំនិតឬចំណុចណាដែលពិបាក ដើម្បីគ្រប់គ្រងថ្នាក់រៀន និងផ្តល់ព័ត៌មានត្រឡប់ទៅកាន់សិស្សានុសិស្សវិញ។ បន្ថែមទៅទៀត គ្រូបង្រៀនជឿថា ការប្រើប្រាស់ភាសាខ្មែរគឺជួយសិស្សក្នុងការរៀនវាក្យស័ព្ទ វេយ្យាករណ៍ ជំនាញអាន រួមនិងជំនាញសរសេរ។ មិនត្រឹមតែប៉ុណ្ណោះ ការប្រើប្រាស់ភាសាខ្មែរគឺជួយកាត់បន្ថយភាពភ័យខ្លាចរបស់សិស្សផងដែរ។ សម្រាប់សិស្សានុសិស្ស គឺឯកភាពទៅលើចំណុចខាងលើនេះស្ទើរតែទាំងស្រុង ហើយពួកគេថែមទាំងយល់ថា ភាសាខ្មែរគឺជួយពួកគេក្នុងការរៀនជំនាញនិយាយ និងជំនាញស្តាប់ថែមទៀត។ ក្នុងនោះផងដែរ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យឃើញពីកម្រិតនៃការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សទៅលើការប្រើប្រាស់ភាសាខ្មែរធៀបនិងការប្រើប្រាស់ជាក់ស្តែងផងដែរ។ ក្នុងនោះ គ្រូបង្រៀនចំនួន ៨១.0% និង

សិស្សចំនួន ៧៥.២% យល់ថាភាសាខ្មែរគួរប្រើពីចន្លោះ ២០-៥៩% ចំណែកការប្រើប្រាស់ជាក់ស្តែកវិញ យើងឃើញថាគ្រូបង្រៀនចំនួន ៨០.៩% និងសិស្សចំនួន ៦៦.៨% បានប្រើភាសាខ្មែរពី ៤០-៧៩%។

សរុបមកការរួមបញ្ចូលភាសាខ្មែរនៅក្នុងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា គឺជាវិធីសាស្ត្រមួយដែលជួយជំរុញឲ្យការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្សានុសិស្សដំណើរការទៅបានប្រកបដោយភាពល្អប្រសើរ។ វិធីសាស្ត្រនៃការរួមបញ្ចូលភាសាខ្មែរក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនេះក៏បានឆ្លើយតបទៅនឹងកញ្ចប់សមត្ថភាពរបស់ធនធានគ្រូបង្រៀន និងកម្រិតយល់ដឹងភាសាអង់គ្លេសរបស់សិស្សានុសិស្សជាក់ស្តែងផងដែរ។

# ABSTRACT

The purposes of this study intend to reveal the teachers and students´ perspectives on the integration of mother tongue in teaching and learning English at Secondary School in Kampong Cham Province and the degrees of using it.

The research methodology used in this study is quantitative method. The questionnaires were designed to collect the data from 5 upper-secondary schools and 7 lower-secondary schools in Batheay district, Kampong Cham province with the total number of 292 samples, 42 teachers of English and 250 students. The data analysis is focused on mean and percentage of each part in the questionnaires with Likert Scale.

According to the research result, teachers of English and students thought that mother tongue, Khmer, played an important role in teaching and learning English at Secondary school. Teachers like to use bother Khmer and English in their teaching. They use Khmer to explain difficult ideas or points, to manage their class, and to give feedback to their students so on. In addition, teachers believed that using Khmer helps students learn vocabulary, grammar, reading skill, and writing skill and it is also used to reduce students´ stress and fear. The students also strongly agreed with all mentioned above. They thought that Khmer helps them learn listening skill and speaking skill, too. The research result also showed the teachers and students´ perception on the level of using Khmer and the real use of it. 81.0% teachers and 75.2% students think that Khmer should be used from 20-59% in English class but 80.9% teachers and 66.8% students use Khmer from 40-79% in their real teaching and learning.

In short, the integration of mother tongue in teaching and learning English at Secondary School is a vital method to improve the process of teaching and learning English. It is also appropriate for the ability and the numbers of major teachers and students´ knowledge in Cambodia.

( *Keyword: Integration, Mother tongue, Teaching English, Learning English* )

# ជំពូក ១
# សេចក្តីផ្តើម

# ជំពូក ១ ៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការអភិវឌ្ឍប្រទេសជាតិមួយឱ្យមានវឌ្ឍនភាព វិបុលភាព និងភាពថ្កុំថ្កើងរុងរឿងទៅបាននោះជាដំបូងបំផុតគឺត្រូវកសាងធនធានមនុស្ស ដែលមានលក្ខណៈសម្បត្តិពេញលេញប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិនិងមនុស្សជាតិ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។ វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់។ ពោលគឺ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដែលជួយបង្កើនកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព និងបរិយាបន្ន (ក្រសួងអប់រំយុវជននិងកីឡា, ២០១៩)។ រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងផ្តល់ឱកាសតាមគ្រប់រូបភាពដល់ប្រជាជនកម្ពុជាគ្រប់រូប ដើម្បីទទួលបានការអប់រំ ដោយបើកយុទ្ធនាការរំដោះគ្រោះមិនចេះអក្សរនិងគ្រោះភ្លេចអក្សរ តាមរយៈពាក្យស្លោកមួយចំនួន ក្នុងន័យលើកកម្ពស់ការអប់រំដូចជា «អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ» (ក្រសួងអប់រំយុវជននិងកីឡា, ២០១៩)។ នៅក្នុងរដ្ឋធម្មនុញ្ញមាត្រា៦៥ បានចែងថា «រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហាន ដើម្បីឱ្យការអប់រំបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប» ។ យើងឃើញថាការសិក្សាត្រឹមតែភាសាជាតិ មិនទាន់ឆ្លើយតបទៅនឹងបដិវត្តនៃយុគឌីជីថលនេះនៅឡើយទេ។ ដោយក្នុងនោះអ្នកសិក្សាត្រូវមានចំណេះដឹងខាងបច្ចេកវិទ្យាព័ត៌មានវិទ្យា និងភាសាបរទេស។ ទន្ទឹមនឹងនោះផងដែរ ភាសាអង់គ្លេសត្រូវបានគេចាត់ទុកថាជាភាសាអន្តរជាតិ ហើយដោយសារតែសកលភាវូបនីយកម្ម ភាសានេះបានក្លាយទៅជាភាសាអាទិភាពខ្ពស់ ដែលមានការប្រើប្រាស់នៅក្នុងប្រទេសជាច្រើននៅជុំវិញពិភពលោក (Jong & Zhang, 2021)។ ភាសាអង់គ្លេស គឺជាភាសាដែលមានអ្នកនិយាយច្រើនជាងគេបំផុត ដោយគិតត្រឹមឆ្នាំ២០២២ ចំនួនអ្នកនិយាយភាសានេះមានប្រមាណ ១៥០០លាននាក់នៅទូទាំងពិភពលោក (Szmigiera, 2022)។ ការរៀនភាសា

អង់គ្លេសត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ ហើយជាពិសេសសម្រាប់អ្នកដែលចង់ស្វែងរកការងារល្អប្រសើរឬសម្រាប់អ្នកចង់ទទួលបានការអប់រំដ៏ល្អ។ ហេតុផលនេះហើយបានជាប្រទេសជាច្រើននៅជុំវិញពិភពលោកបានទទួលស្គាល់ថាភាសាអង់គ្លេសជាប្រភពនៃការអប់រំសម្រាប់ប្រទេសរបស់ពួកគេ។ ដោយយល់ឃើញថា ធនធានមនុស្សគឺជាកម្លាំងចលករមួយដ៏ចាំបាច់បំផុតនៅក្នុងការអភិវឌ្ឍប្រទេសជាតិ និងបានមើលឃើញពីសារៈសំខាន់នៃតម្រូវការនៅក្នុងការប្រើប្រាស់ភាសានេះ ទើបនាំឲ្យប្រទេសជាច្រើននៅជុំវិញពិភពលោកបានដាក់បញ្ចូលភាសាអង់គ្លេស ជាមុខវិជ្ជាដ៏ចាំបាច់ក្នុងគោលនយោបាយអប់រំជាតិនៅតាមសាលារៀនសាធារណៈ។ បើយើងក្រឡេកមកមើលប្រទេសកម្ពុជាយើងវិញ ក៏បានដាក់ចេញនូវគោលនយោបាយរដ្ឋាភិបាលកម្ពុជាឌីជីថល ២០២២-២០៣៥ ដោយផ្តោតសំខាន់លើសេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថល (ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ២០២២) ដែលនាំឱ្យមានតម្រូវការខាងបច្ចេកវិទ្យា ព័ត៌មានវិទ្យា និងអ្វីដែលមិនអាចខ្វះបាននោះគឺ តម្រូវការខាងភាសាបរទេស។ សម្រាប់ប្រទេសកម្ពុជាយើងក៏ជាប្រទេសមួយ ដែលបានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសជាភាសាបរទេសទៅក្នុងកម្មវិធីសិក្សានៅក្នុងសាលាចំណេះទូទៅផងដែរ។ មុខវិជ្ជានេះត្រូវបានអនុញ្ញាតឱ្យមានការសិក្សាជាផ្លូវការនាអំឡុងឆ្នាំ ១៩៨៩ រហូតមកដល់បច្ចុប្បន្ននេះ (Neau, 2003)។ គោលដៅនៃសាលារៀនចំណេះទូទៅ គឺការកសាងធនធានមនុស្សឲ្យក្លាយជាពលរដ្ឋពេញលេញ ដែលប្រកបដោយ ចំណេះដឹង សីលធម៌ និងជំនាញ។ ផ្នែកមួយដើម្បីសម្រេចគោលដៅនេះក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសជាបន្តបន្ទាប់ពីថ្នាក់ទី៤ រហូតដល់កម្រិតមធ្យមសិក្សា។ ទន្ទឹមនឹងនោះផងដែរ ក្តីព្រួយបារម្ភដើម្បីឱ្យសម្រេចនូវគោលដៅនេះ គឺវិធីសាស្ត្រនៃការផ្ទេរចំណេះដឹងរបស់គ្រូបង្រៀនទៅឱ្យសិស្សានុសិស្ស។ គេសង្កេតឃើញថា គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សនៅតាមសាលារដ្ឋនៅក្នុងប្រទេសកម្ពុជាភាគច្រើនមិនបានប្រើប្រាស់ត្រឹមតែភាសាអង់គ្លេសនៅក្នុងការបង្រៀន និងរៀននោះទេ ដោយពួកគាត់បានរួមបញ្ចូលភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសផងដែរ។ គោលបំណងនៃការប្រើភាសាខ្មែរនេះគឺ ដើម្បីសម្រួលដល់ការបង្រៀន និងរៀនឱ្យកាន់តែមានភាពទាក់ទាញនិងងាយស្រួលឡើង។

អ្នកសិក្សាភាសាអង់គ្លេសទូទៅ និងអ្នកអប់រំតែងតែប្រើពាក្យ L1 ដើម្បីសំដៅលើភាសាទីមួយឬភាសាកំណើត និងពាក្យ L2 សំដៅដល់ភាសាទីពីរ ឬភាសាបរទេសដែលកំពុងសិក្សា។ ចំពោះការប្រើប្រាស់ភាសាកំណើត (L1) នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសជាភាសាបរទេស (EFL) បានក្លាយទៅជាប្រធានបទដែលត្រូវបានគេលើកយកមកពិភាក្សារហូតដល់សព្វថ្ងៃនេះ។ ដោយការសិក្សាខ្លះបានគាំទ្រក្នុងការប្រើប្រាស់ភាសាកំណើតនៅក្នុងថ្នាក់រៀនភាសាអង់គ្លេស ហើយខ្លះទៀតក៏បានបដិសេធ (Hasrina, Aziz, & Fitriani, 2018)។ ទោះបីជាយ៉ាងណាក៏មានការលើកបង្ហាញថា គ្រូបង្រៀនប្រើភាសាកំណើតនៅក្នុងការបង្រៀនភាសាបរទេស ដើម្បីផ្តល់ការឆ្លើយតបជាមួយសិស្ស បង្រៀនវាក្យស័ព្ទថ្មី ពន្យល់វេយ្យាករណ៍ បង្កើតទំនាក់ទំនងយ៉ាងសុខដុមជាមួយសិស្ស ជួយសិស្សជាបុគ្គលៗ និងធ្វើឱ្យចំណេញពេលវេលានៅក្នុងការពន្យល់មេរៀន (Mohebbi & Alavi, 2014)។ បន្ថែមទៅទៀត ការប្រើភាសាកំណើត គឺជាកត្តាកំណត់មួយដ៏សំខាន់សម្រាប់ការរៀនភាសាបរទេស។ ក្នុងនោះភាសាកំណើតត្រូវបានគេចាត់ទុកថា គឺជាប្រភពដែលអ្នករៀនបានប្រើប្រាស់នៅក្នុងគោលបំណង ដើម្បីជួយពួកគេរៀបចំទិន្នន័យនៃធាតុចូលសម្រាប់ការរៀនភាសាបរទេស ហើយបន្ទាប់មកពួកគេចាប់ផ្តើមអនុវត្តវាឱ្យបានល្អតាមដែលពួកគេអាចធ្វើទៅបាន (Yadav, 2014)។ គ្រូបង្រៀនប្រើប្រាស់ភាសាកំណើតស្ទើរតែនៅគ្រប់ស្ថានភាពទាំងអស់នៃការបង្រៀនរបស់ពួកគេ ដោយក្នុងនោះរួមមាន ការផ្តល់ការពន្យល់ណែនាំ ការបកប្រែ ឬការបង្ហាញនូវទម្រង់នៃការប្រើប្រាស់ភាសាបរទេស ហើយរឿងទាំងនេះបានកើតមានឡើង គឺដោយសារគ្រូបង្រៀនខ្លះយល់ថាភាសាកំណើតគឺតែងតែដើរតួយ៉ាងសកម្ម និងមានប្រយោជន៍សម្រួលដល់ការរៀន និងបង្រៀនភាសាបរទេស (Koucká, 2007)។ ការសិក្សាស្រាវជ្រាវមួយបានធ្វើឡើង ដោយបានប្រើប្រាស់តែភាសាអង់គ្លេសតែប៉ុណ្ណោះនៅក្នុងថ្នាក់រៀនភាសាបរទេស ហើយធ្វើការប្រៀបធៀបទៅនិងថ្នាក់រៀនមួយទៀតដែលប្រើប្រាស់ពីរភាសា។ លទ្ធផលបានបង្ហាញឱ្យឃើញថា សិស្សរៀននៅក្នុងថ្នាក់ពីរភាសា គឺភាសាកំណើតរួមជាមួយនិងភាសាអង់គ្លេសទទួលបានលទ្ធផលល្អជាងថ្នាក់រៀន ដែលមានតែមួយភាសាគឺភាសាអង់គ្លេស (Madriñan, 2014)។

ជារួមភាសាកំណើតអាចត្រូវបានគេប្រើជាឧបករណ៍មួយដ៏សំខាន់ នៅក្នុងថ្នាក់រៀនភាសាបរទេស សម្រាប់ការទំនាក់ទំនងក្នុងការបង្រៀន និងរៀនរបស់គ្រូនិងសិស្ស។ ក្នុងនោះក៏មានទស្សនៈខ្លះមិនសូវគាំទ្រ ទៅលើការប្រើប្រាស់ភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនោះទេ ហើយបានលើក ឡើងថាភាសាកំណើតគួរតែប្រើក្នុងស្ថានភាពចាំបាច់តែប៉ុណ្ណោះ (MAHMUTOĞLU & KICIR, 2013)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសនៅក្នុងកម្រិតបឋមសិក្សា ទើបតែត្រូវបានអនុវត្តនៅក្នុងឆ្នាំ ២០១៤ ហើយការបង្រៀននិងរៀនភាសាអង់គ្លេសនេះ ត្រូវបានបែងចែកនៅក្នុងកាលវិភាគប្រចាំសប្តាហ៍ ដោយអនុវត្តចំនួន ២ម៉ោងក្នុងមួយសប្តាហ៍ ចំណែកគ្រូបង្រៀនវិញ គឺតម្រូវឲ្យគណៈគ្រប់គ្រងសាលាជ្រើស រើសយកគ្រូបង្រៀន ដែលចេះភាសាអង់គ្លេសសម្រាប់បង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅថ្នាក់ទី៤ ហើយ សមាសភាពគ្រូបង្រៀនទាំងនោះនឹងទទួលបានការបណ្តុះបណ្តាលជំនាញឬបំប៉នសមត្ថភាព ផ្នែកភាសា អង់គ្លេសបន្ថែមទៀត (សេចក្តីណែនាំស្តីពីការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋម សិក្សា, ២០១៤)។ ការអនុវត្តនេះមិនទាន់បានជួយសិស្សកម្រិតបឋមសិក្សាឱ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រើប្រាស់ភាសាអង់គ្លេស ដើម្បីបន្តការសិក្សាឆ្លងភូមិសិក្សាទៅកាន់កម្រិតមធ្យមសិក្សាបឋមភូមិនៅ ឡើយទេ។ កត្តាដែលនាំឱ្យការអនុវត្តនេះមិនអាចជួយសិស្សបាន គឺដោយសារចំនួនម៉ោងសម្រាប់បង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសតិចពេក ដែលធ្វើឱ្យការបង្រៀន និងរៀនមិនអាចសម្រេចបានល្អ។ បន្ថែមពី នេះទៅទៀត ការដែលនាំឱ្យការអនុវត្តនេះមិនអាចឆ្លើយតបបានល្អ គឺការកង្វះគ្រូបង្រៀនមុខវិជ្ជាឯកទេស ភាសាអង់គ្លេស សម្រាប់ការបង្រៀននៅកម្រិតបឋមសិក្សា។

ទន្ទឹមនឹងនេះផងដែរ សមត្ថភាពនៃការប្រើប្រាស់ភាសាអង់គ្លេសរបស់គ្រូបង្រៀននៅកម្រិតមធ្យម សិក្សាបឋមភូមិ និងកម្រិតមធ្យមសិក្សាទុតិយភូមិក៏នៅមានកម្រិត ដោយគ្រូដែលបង្រៀនមុខវិជ្ជាភាសា អង់គ្លេស មិនមែនជាមុខវិជ្ជាឯកទេសរបស់គាត់ទេ តែដោយសារតម្រូវការក្នុងការបង្រៀនមុខវិជ្ជានេះ ទើប ថ្នាក់គ្រប់គ្រងសាលារៀនក៏បានរៀបចំយកគ្រូ ដែលមានចំណេះដឹងភាសាអង់គ្លេសខ្លះៗមកបង្រៀនជំនួស ដើម្បីបំពេញតម្រូវការជាក់ស្តែង។ ហើយចំពោះគ្រូបង្រៀនដែលមានមុខវិជ្ជាឯកទេសភាសាអង់គ្លេសភាគ

ច្រើនមានគុណវឌ្ឍត្រឹមតែ ១២+២ ឬអាចក្រោមនេះប៉ុណ្ណោះ។ ក្រៅពីសមត្ថភាពនៃការប្រើប្រាស់ភាសាអង់គ្លេសរបស់គ្រូនិងសិស្សនៅមានកម្រិត កត្តាផ្សេងទៀតដែលនាំឱ្យភាសាកំណើតត្រូវបានគេប្រើនៅក្នុងថ្នាក់រៀនភាសាអង់គ្លេសមានដូចជា ភាពអៀនខ្មាសនៅក្នុងការប្រើប្រាស់ ឬក៏គ្មានចំណាប់អារម្មណ៍ក្នុងការប្រើប្រាស់ភាសាអង់គ្លេសនេះជាដើម (Afzal, 2013)។ ហេតុដូចនេះការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសមិនអាចដំណើរការទៅបានដោយគ្មានវត្តមានរបស់ភាសាកំណើត ដែលជាភាសាទី១នៅក្នុងថ្នាក់រៀនបានឡើយ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅក្នុងគោលបំណងជាក់លាក់សំខាន់ពីរះ

១- សិក្សាពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀន និងសិស្សកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមទៅលើការរួមបញ្ចូលភាសាកំណើត (ភាសាខ្មែរ) នៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេស។

២- កំណត់ពីកម្រិតនៃការប្រើប្រាស់ភាសាកំណើត (ភាសាខ្មែរ) នៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងនូវសំណួរស្រាវជ្រាវចំនួនពីរះ

១- តើគ្រូបង្រៀន និងសិស្សនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមយល់ឃើញយ៉ាងដូចម្តេចទៅលើការប្រើប្រាស់ភាសាកំណើត (ភាសាខ្មែរ) នៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេស?

២- តើគ្រូបង្រៀន និងសិស្សរួមបញ្ចូលការប្រើប្រាស់ភាសាកំណើត(ភាសាខ្មែរ)កម្រិតណានៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធាន **«ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម»** ពិតជាមានសារៈសំខាន់ណាស់ ដោយបានបង្ហាញពី

ការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សនៅកម្រិតមធ្យមសិក្សានៅក្នុងខេត្តកំពង់ចាម លើការរួមបញ្ចូលនៃការប្រើប្រាស់ភាសាខ្មែរនៅក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស រួមនិងកម្រិតនៃការប្រើប្រាស់របស់វាផងដែរ។ វាក៏ផ្ដល់ជាឯកសារមួយសម្រាប់គ្រូបង្រៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានយល់កាន់តែស៊ីជម្រៅពីចំណុចវិជ្ជមាននិងចំណុចអវិជ្ជមាន នៃការប្រើប្រាស់ភាសាខ្មែរក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ ក្នុងនោះផងដែរ វានឹងបង្ហាញឱ្យឃើញអំពីសារៈសំខាន់នៃទំនាក់ទំនងក្នុងការប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស។ ការសិក្សាស្រាវជ្រាវនេះ ក៏អាចជាផ្នែកមួយនៅក្នុងការជំរុញការបង្រៀន និងរៀនភាសាអង់គ្លេសនៅតាមសាលារដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង និងកាន់មានប្រសិទ្ធភាពខ្ពស់តាមរយៈការប្រើប្រាស់ភាសាកំណើតឱ្យសមស្របទៅតាមពេលវេលា និងស្ថានភាព។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

### ១.៦.១- ប្រជាជន និងភាគសំណាក

**ក. ប្រជាជន** គឺសំដៅដល់គ្រូបង្រៀន និងសិស្សនៅកម្រិតមធ្យមសិក្សានៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាម របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ខ. ភាគសំណាក** ក្នុងការសិក្សាស្រាវជ្រាវនេះ គឺត្រូវធ្វើឡើងដោយកំណត់យកវិទ្យាល័យចំនួន ០៥ និងអនុវិទ្យាល័យ ចំនួន០៧ ដែលជាវិទ្យាល័យ និងអនុវិទ្យាល័យ ក្នុងឃុំទាំង១២ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានបែងចែកជា៥ជំពូក ដូចខាងក្រោម៖

ជំពូក១ សេចក្ដីផ្ដើម៖ នៅក្នុងជំពូកនេះបានបង្ហាញពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ព្រមទាំងដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ «**ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**»។

ជំពូក២ រំលឹកទ្រឹស្តីៈ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវប្រមូលយកនូវរាល់ទ្រឹស្តីរបស់អ្នកស្រាវជ្រាវមុនៗ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ លិខិតបទដ្ឋានគតិយុត្តិ ប្រកាស សារាចរណ៍ ណែនាំ និងឯកសារនានារបស់ក្រសួង និងស្ថាប័ននានា ដែលពាក់ព័ន្ធនឹងប្រធានបទនេះ ដើម្បីធ្វើជាគំនិតឆ្លុះបញ្ចាំងទៅនឹងការរកឃើញថ្មីក្នុងស្នាដៃស្រាវជ្រាវនេះ។

ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវៈ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានបង្ហាញនូវ ឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសគំរូសំណាក និងប្រភេទសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យដែលប្រមូលមកតាមបណ្តុំគំនិត និងតាមតារាង។

ជំពូក៤ លទ្ធផលនៃការស្រាវជ្រាវៈ ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ បកស្រាយ និងពិភាក្សាស្វែងរកចំណុចល្អ ចំណុចដែលត្រូវកែលម្អ និងចំណុចដូចគ្នានិងខុសគ្នានៃការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សនៅក្នុងបរិបទជាក់ស្តែង នៃការរួមបញ្ចូលភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។

ជំពូក៥ សេចក្តីសន្និដ្ឋាន និងការផ្តល់សំណូមពរៈ នេះជាផ្នែកដែលអ្នកសិក្សាស្រាវជ្រាវ ត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់និងលើកឡើងនូវសំណូមពរមួយចំនួនដល់ក្រសួងអប់រំ មន្ទីរខេត្ត ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេស និងភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ ដើម្បីធ្វើឱ្យការបង្រៀននិងរៀនភាសាអង់គ្លេសមានភាពល្អប្រសើរឡើង។

# ជំពូក ២
# រំលឹកទ្រឹស្តី

# ជំពូក ២ ៖ រំលឹកទ្រឹស្ដី

## ២.១ និយមន័យនៃពាក្យគន្លឹះ

មានទស្សនៈនិងការសិក្សាស្រាវជ្រាវមួយចំនួនបានឱ្យនិយមន័យទៅលើពាក្យ «**ភាសាកំណើត**» ដោយមានលក្ខណៈស្រដៀងៗគ្នា។ ក្នុងនោះភាសាកំណើតត្រូវបានគេកំណត់ថា ជាភាសាដែលគេរៀនមុនដំបូងបង្អស់ ជាភាសាដែលត្រូវបានគេចេះខ្លាំងជាងគេ និងជាភាសាដែលត្រូវបានគេប្រើប្រាស់ច្រើនជាងគេ (Skutnabb-kangas, 1981)។ ភាសាកំណើត ក៏ជាភាសាមួយដែលត្រូវបានគេរៀនមុនភាសាផ្សេងទៀត ហើយមនុស្សម្នាក់អាចមានភាសាកំណើតច្រើនជាងមួយ (Gupta, 1997)។ មនុស្សដែលមានភាសាកំណើតចំនួនពីរលុះត្រាណាតែភាសាទាំងពីរនោះត្រូវបានរៀននៅក្នុងពេលវេលាដូចគ្នា ហើយភាសាទាំងនោះត្រូវបានគេយល់ច្បាស់ដូចគ្នាផងដែរ។ ក្នុងករណីភាគច្រើន ពាក្យ «ភាសាកំណើត» សំដៅទៅលើភាសាដែលមនុស្សម្នាក់ទទួលបានក្នុងវ័យកុមារភាព ពីព្រោះវាត្រូវបាននិយាយនៅក្នុងគ្រួសារ ឬវាជាភាសានៃតំបន់ដែលកុមាររស់នៅ ហើយវាត្រូវបានគេស្គាល់ផងដែរថាជា ភាសាកំណើត ជាភាសាដំបូង ឬជាភាសាសរសៃឈាម។ ភាសាកំណើតក៏ត្រូវបានគេសំដៅដល់ភាសាទីមួយដែលក្មេងៗចេះ ពីកំណើតឬជាភាសាដែលពួកគេនិយាយជាមួយឪពុកម្តាយរបស់ពួកគេ ឬវាគឺជាភាសាដែលមនុស្សនិយាយជាទូទៅនៅក្នុងប្រទេសរបស់ពួកគេ (Bidya, 2022)។ ភាសាកំណើតអាចសំដៅដល់ភាសាដំបូង ឬភាសាជាតិដែលត្រូវបាននិយាយជាទូទៅ ហើយសិស្សខ្លះមានឪពុកម្តាយចម្រុះជាតិសាសន៍ទៀតផង។ ដូច្នេះពួកគេអាចចេះនិយាយបានពីរឬច្រើនភាសា មុនពេលគ្រប់អាយុត្រូវចូលរៀន។ អាស្រ័យហេតុដូចនេះហើយ ភាសាកំណើត គឺជាភាសាមួយដែលត្រូវបានគេនិយាយច្រើនបំផុតនៅផ្ទះជាមួយគ្រួសារ (Savage, 2021)។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ការមានមូលដ្ឋានគ្រឹះភាសាកំណើតខ្លាំង អាចជួយឱ្យមានការយល់ដឹងពីកម្មវិធីសិក្សាបានល្អ ក៏ដូចជាមានឥរិយាបថវិជ្ជមានចំពោះការសិក្សារៀនសូត្រ។ ដូច្នេះវាសំខាន់ណាស់ដែលសិស្សចេះភាសាកំណើតរបស់ពួកគេនៅពេលពួកគេបានផ្ដើមរៀនភាសាដទៃទៀត។ ក្នុងនោះផងដែរ សារៈសំខាន់នៃភាសាកំណើតត្រូវបានគេសិក្សា ពីព្រោះនៅពេលសិស្សអភិវឌ្ឍភាសាកំណើតរបស់ពួកគេ នោះពួកគេកំពុងជំរុញនូវបំណិនសំខាន់ៗក្នុងពេលដំណាលគ្នានោះផងដែរ។ បំណិនទាំងនោះមានដូចជា

បំណិនក្នុងការត្រិះរិះនិងបំណិនអក្ខរកម្មជាដើម។ ការសិក្សាក៏បានបង្ហាញផងដែរថា ការអភិវឌ្ឍចំណេះដឹង ក៏ដូចជាការអភិវឌ្ឍផ្នែកបញ្ញាស្មារតី គឺមានលក្ខណៈលឿនចំពោះអ្នកដែលមានការយល់ដឹងភាសាកំណើតបានច្បាស់លាស់ល្អ (Nishanthi, 2020)។

យោងតាមវចនានុក្រម **សម្តេចព្រះសង្ឃរាជ ជួន ណាត** បានឱ្យនិយមន័យនៃ **ការបង្រៀន** ថាជាការញ៉ាំងអ្នកដទៃឱ្យរៀន ការប្រៀនឱ្យចេះ ការឱ្យចំណេះដោយការបង្ហាត់ ការបង្ហាញឱ្យចេះ។ ការបង្រៀនគឺជាកិច្ចការលំបាក និង មានទ្រង់ទ្រាយច្រើន។ សកម្មភាពនៃការបង្រៀន រួមមានដូចជា ការពន្យល់ណែនាំ ការបង្ហាញឱ្យឃើញ ការចោទសួរឬការដាក់ចំណោទសួររកហេតុផល ការលើកទឹកចិត្ត ការតាមដានការសិក្សារបស់សិស្ស ការប្រឡងឬការវាយតម្លៃអំពីវឌ្ឍនភាពនៃការសិក្សារបស់សិស្សានុសិស្ស និងការផ្តល់ព័ត៌មានត្រឡប់។ នៅក្នុងការបង្រៀន គ្រូបង្រៀនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំថ្នាក់រៀន ដែលធ្វើយ៉ាងណាជួយសិស្សក្នុងការរៀនសូត្រឲ្យមានភាពល្អប្រសើរ។ ដើម្បីសម្រេចបាននូវគោលដៅនេះ គ្រូបង្រៀនត្រូវរៀបចំមេរៀនឱ្យមានប្រសិទ្ធភាព ចាត់ចែងសិស្សឲ្យធ្វើកិច្ចការនិងផ្តល់ព័ត៌មានត្រឡប់ទៅកាន់ពួកគេវិញ រៀបចំសម្ភារៈថ្នាក់រៀន និងត្រូវសហការជាមួយបុគ្គលិកផ្សេងៗទៀតនៅក្នុងអង្គភាព (Cox, 2020)។ ចំណែកនិយមន័យនៃ **ការរៀន** គឺជាការសិក្សា ការខំសង្កេតឱ្យចេះ ការទទួលយកចំណេះដឹង ការហាត់ ការហ្វឹក។ ការរៀនសូត្រគឺជា ដំណើរការនៃការបញ្ចូលព័ត៌មានតាមរយៈចំណេះដឹងបច្ចេកទេស ឬជំនាញថ្មីៗ (សព្វវចនាធិប្បាយ, 2022)។ សិស្សដែលមានរបៀបរៀនតាមរយៈការប្រើប្រាស់កាយវិការ ឬចលនា អាចរៀនបានយ៉ាងពូកែ និងយ៉ាងឆាប់រហ័សលុះត្រាតែមានការតឿន និងបង្រៀនពីភាពពាក់ព័ន្ធនឹងការធ្វើសកម្មភាព។ ជារួមការសិក្សារៀនសូត្រ គឺជាដំណើរការនៃការទទួលយកនូវអ្វីដែលថ្មី និងអភិវឌ្ឍទៅលើអ្វីដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាពឡើង ដើម្បីទទួលបានការផ្លាស់ប្តូរទាំងស្រុងដែលឆ្ពោះទៅរកភាពជាពលរដ្ឋពេញលេញ។

## ២.២ កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស

ភាសាអង់គ្លេស គឺជាមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាគោលសំខាន់ៗដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាចំណេះទូទៅ។ យោងតាមសេចក្តីណែនាំលេខ ៤៤ អយក.ស

ណាន ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ *ស្តីពីការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា* ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណេះទូទៅ ចាប់ពីថ្នាក់ទី៤ ឡើងទៅដើម្បីផ្តល់ឱកាសឲ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសសម្រាប់ជាគ្រឹះ ក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ ក្រសួងអប់រំបានបន្តថា សម្រាប់ការសិក្សាភាសាអង់គ្លេសនៅក្នុងកម្រិតថ្នាក់បឋមសិក្សានេះ គ្រប់គ្រឹះស្ថានបឋមសិក្សាចំណេះទូទៅសារធារណៈទាំងអស់ ត្រូវប្រើប្រាស់សៀវភៅ ភាសាអង់គ្លេស «English Grade4 Grade5 and Grade6» ដែលជាសៀវភៅសិក្សាគោលតែមួយគត់ ក្នុងការបង្រៀន និងរៀននៅកម្រិតបឋមសិក្សាទូទាំងប្រទេស។ ជាមួយគ្នានោះផងដែរ ដើម្បីអនុវត្តកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលម៉ោងសិក្សាទៅក្នុងកាលវិភាគចំនួន២ម៉ោងក្នុងមួយសប្តាហ៍ដែលមួយម៉ោងរៀនត្រឹម៤០នាទី ហើយប្រធានកម្រងត្រូវសហការជាមួយនាយកសាលាដើម្បីកំណត់ម៉ោងក្នុងកាលវិភាគឱ្យច្បាស់លាស់ឲ្យបានគ្រប់សាលាបឋមសិក្សា។ ក្រសួងអប់រំបន្ថែមទៀតថា នីតិវិធីនៃការរើសគ្រូបង្រៀន គឺជាការចាត់តាំងរបស់នាយក-នាយិកាសាលាដោយផ្តោតលើចំណេះដឹងផ្នែកភាសាអង់គ្លេស ឬធ្លាប់បានចូលរួមវគ្គតម្រង់ទិសនៃការប្រើប្រាស់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសសម្រាប់ថ្នាក់ទាំងបីកម្រិតពីថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ហើយម៉ោងដែលគ្រូបង្រៀននៅសេសសល់ត្រូវជួយការងាររដ្ឋបាលសាលា ឬការងារបណ្ណាល័យសាលារៀន។ សម្រាប់សាលារៀនដែលគ្រូបង្រៀនពុំទាន់ទទួលការបណ្តុះបណ្តាលស្តីពីការណែនាំការប្រើប្រាស់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេស ក្រសួងអប់រំក៏បានអនុញ្ញាតឱ្យគណៈគ្រប់គ្រងជ្រើសរើសគ្រូបង្រៀនដែលចេះភាសាអង់គ្លេស ដើម្បីបណ្តុះបណ្តាលពីជំនាញ ឬបំប៉នសមត្ថភាពសម្រាប់បង្រៀននាពេលខាងមុខ។ ចំណែកការកំណត់ពិន្ទុត្រូវធ្វើឡើងតាមការវាយតម្លៃទៅលើសមាសភាគទាំង៤នៃភាសាអង់គ្លេសគឺ ការស្តាប់ ការអាន ការនិយាយ និងការសរសេរ ដែលពិន្ទុសរុបស្មើនឹង១០ពិន្ទុដូចមុខវិជ្ជាផ្សេងទៀតផងដែរ។

សម្រាប់កម្រិតអនុវិទ្យាល័យ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចផ្លាស់ប្តូរសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែមានភាពល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។ យោងតាមសេចក្តីណែនាំលេខ ៤៥ អយក.សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពី *ការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស English «Grade7-9» និងការប្រើប្រាស់សៀវភៅ «English is Fun» សម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ* ក្រសួងអប់រំបានសហការជាមួយអង្គការមណ្ឌលគាំទ្រការអប់រំ «គីហ្សូណា» បានអភិវឌ្ឍសៀវភៅសិក្សាគោលភាសាអង់គ្លេស សម្រាប់មធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ទី៨ និងទី៩ គឺសៀវភៅ English Grade 7-8-9 ដើម្បីជំនួសសៀវភៅភាសាអង់គ្លេស English for Cambodia Book One-Two-Three។ ក្រៅពីប្តូរសៀវភៅហើយនោះ ក្រសួងអប់រំក៏បានដាក់ឱ្យមានកម្មវិធីបង្រៀន «English is Fun» ផងដែរ សម្រាប់បង្កើនការស្តាប់ និងនិយាយភាសាអង់គ្លេស។ លិខិតណែនាំនេះ ក៏បានតម្រូវឱ្យគ្រប់គ្រឹះស្ថានចំណេះទូទៅមធ្យមសិក្សាបឋមភូមិទាំងអស់ ត្រូវអនុវត្តការបង្រៀន និងរៀនចំនួន ៤ម៉ោងក្នុងមួយសប្តាហ៍ ដោយ៣ម៉ោងសម្រាប់សិក្សាសៀវភៅ English Grade 7-8-9 និង១ម៉ោងសម្រាប់ការសិក្សាកម្មវិធី English is Fun។ បន្ថែមទៅទៀត សម្រាប់ការដាក់ពិន្ទុ មិនខុសគ្នាទៅនឹងកម្រិតបឋមសិក្សាទេ គឺត្រូវផ្អែកលើសមត្ថភាពជំនាញទាំងបួននៃភាសាអង់គ្លេសគឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ហើយយកពិន្ទុតាមរបបដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ក្រសួងអប់រំបានរៀបចំកម្មវិធីសិក្សាថ្នាក់ទី១០ ដោយតម្រូវឱ្យបង្រៀនភាសាអង់គ្លេសចំនួន ៤ម៉ោងក្នុងមួយសប្តាហ៍ ហើយគោលបំណងនៃកម្មវិធីសិក្សានេះ គឺពង្រឹង និងពង្រីកចំណេះដឹងដែលសិស្សទទួលបានពីកម្រិតមូលដ្ឋាន។ ក្នុងនោះផងដែរ សាលារៀនត្រូវផ្តល់ការណែនាំតម្រង់ទិសដល់សិស្សអំពីជម្រើសមុខវិជ្ជាដែលត្រូវបន្តសិក្សានៅថ្នាក់ទី១១ និងទី១២ (នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ, ២០០៤)។ ចំពោះថ្នាក់ទី១១ និងទី១២ ត្រូវបានបែងចែកទៅជា ថ្នាក់វិទ្យាសាស្ត្រពិតនិងថ្នាក់វិទ្យាសាស្ត្រសង្គម ហើយសម្រាប់មុខវិជ្ជាភាសាអង់គ្លេស គឺតម្រូវឱ្យសិក្សារយៈ២ម៉ោងក្នុងមួយសប្តាហ៍ដោយឆមាសទីមួយត្រូវបង្រៀនចាប់ពីជំពូកទី១ រហូតដល់ជំពូកទី៩ ហើយឆមាសទី២ត្រូវបង្រៀន

ចាប់ពីជំពូកទី៩ ដល់ជំពូកទី១៣។ ចំណែកប្រធានវិញ្ញាសាសម្រាប់ការប្រឡងឆមាសត្រូវជ្រើសយកចេញពីខ្លឹមសារនៃមេរៀនដែលបានសិក្សាទៅតាមឆមាសនីមួយៗ។ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ប្រធានវិញ្ញាសាត្រូវជ្រើសរើសយកចេញពីគ្រប់ជំពូក មេរៀននៃសៀវភៅសិក្សាមុខវិជ្ជាភាសាអង់គ្លេសថ្នាក់ទី១២ចាស់ ដែលបានកំណត់ឱ្យសិក្សាតាមបណ្តុំមុខវិជ្ជានីមួយៗ និងមេរៀនខ្លះនៃសៀវភៅសិក្សាមុខវិជ្ជាភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២ នៃជំពូកដែលនៅសេសសល់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១១)។ ចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្មី សម្រាប់ថ្នាក់ទី១០ ត្រូវបានគេរៀបចំផលិតឡើងហើយ ប៉ុន្តែមិនទាន់មានសេចក្តីណែនាំ សម្រាប់ការប្រើប្រាស់នៅឡើយទេ ហើយសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី១១ និងទី១២គឺមិនទាន់មានការអភិវឌ្ឍនៅឡើយទេ ។ ហេតុដូចនេះ កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសដែលត្រូវអនុវត្តនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គឺនៅអនុវត្តតាមសៀវភៅសិក្សាគោលចាស់ដដែល គឺសៀវភៅ «English For Cambodia BOOK Four ,Book Five និង Book Six»។

## ២.៣ ការប្រើប្រាស់ភាសាកំណើតក្នុងថ្នាក់រៀនភាសាអង់គ្លេស

ការប្រើប្រាស់ភាសាកំណើតនៅក្នុងការរៀនភាសាបរទេសបានក្លាយទៅជាប្រធានបទមួយដែលមានការលើកយកមកជជែកវែកញែករកខុសត្រូវយ៉ាងខ្លាំង ដោយក្នុងនោះការសិក្សាស្រាវជ្រាវខ្លះបានគាំទ្រ និងខ្លះទៀតបានបដិសេធសម្រាប់ការប្រើប្រាស់នេះ។ តែទោះបីជាយ៉ាងណា យើងឃើញថាវត្តមាននៃភាសាកំណើតបានចូលរួមចំណែកធ្វើឲ្យដំណើរការនៃការបង្រៀន និងការរៀនភាសាកាន់តែមានភាពល្អប្រសើរ។ ការសិក្សាស្រាវជ្រាវមួយបានបង្ហាញថា នៅក្នុងរយៈពេលពី៦ទៅ៨ឆ្នាំនៃការរៀនភាសា គឺចាំបាច់ត្រូវអភិវឌ្ឍកម្រិតនៃការអាន ការសរសេរ និងសមត្ថភាពនៃការនិយាយ ដែលជាតម្រូវការសម្រាប់ការសម្រេចបាននូវការសិក្សានៅកម្រិតអនុវិទ្យាល័យ (Yada, 2014)។ បើប្រៀបធៀបទៅនឹងការសិក្សាស្រាវជ្រាវផ្សេងៗទៀត វាបានបង្ហាញឱ្យឃើញពីតួនាទីមួយចំនួនរបស់ភាសាកំណើតដែលមានលក្ខណៈស្រដៀងៗគ្នា ដែលក្នុងនោះមានដូចជា ការនិយាយរឿងកំប្លែងខ្លីៗជាមួយសិស្ស ការពន្យល់ចំណុចវេយ្យាករណ៍ និងការពិភាក្សាបញ្ហាលំហូរនៃវប្បធម៌ (Agustin & Mujiyanto , 2015)។ ការសិក្សា

ស្រាវជ្រាវបានបង្ហាញថា គ្រូបង្រៀនភាសាបរទេសភាគច្រើនប្រើភាសាកំណើត ដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅកាន់សិស្ស បង្រៀនវាក្យស័ព្ទថ្មី ពន្យល់វេយ្យាករណ៍ បង្កើតនូវទំនាក់ទំនងជាមួយសិស្ស រៀបចំថ្នាក់រៀន ផ្តល់ជំនួយដល់សិស្សជាលក្ខណៈបុគ្គលៗ និងធ្វើឱ្យចំណេញពេលវេលាក្នុងការពន្យល់កិច្ចការ (Alavi, 2014)។ មួយវិញទៀត ទាំងគ្រូ និងសិស្សមិនមានការជំទាស់ទៅនឹងការប្រើប្រាស់ភាសាកំណើតនៅក្នុងថ្នាក់រៀននោះទេ។ ដោយពួកគេបានគិតថាភាសាកំណើតគួរត្រូវបានប្រើនៅក្នុងស្ថានភាពចាំបាច់ ហើយពួកគេជឿថាការប្រើប្រាស់នេះអាចកាន់តែមានប្រសិទ្ធភាព បើប្រើក្នុងស្ថានភាព និងពេលវេលាដ៏ត្រឹមត្រូវនោះ (MAHMUTOĞLU & KICIR, 2013)។ តាមរយៈកាប្រើប្រាស់ភាសាកំណើត ធ្វើឱ្យអ្នកសិក្សាអាចរៀនគិតពិចារណា រៀនទំនាក់ទំនង និងទទួលបាននូវការយល់ដឹងយ៉ាងស៊ីជម្រៅពីវេយ្យាករណ៍។ មិនត្រឹមតែប៉ុណ្ណោះភាសាកំណើត ក៏ជាឧបករណ៍ដ៏អស្ចារ្យដែលមនុស្សបានយកមកប្រើប្រាស់ក្នុងការរៀនភាសាបរទេស ដែលផ្តល់នូវប្រព័ន្ធគាំទ្រនៃការរៀនភាសាផងដែរ (Butzkamm, 2003)។ Latsanyphone & Bouangeune (2009) បានបង្ហាញនូវហេតុផលមួយចំនួនដែលភាសាកំណើតគួរត្រូវបានប្រើប្រាស់ជាឧបករណ៍នៅក្នុងថ្នាក់ភាសាបរទេស៖

- វាគឺជាទម្លាប់នៃការប្រើភាសាកំណើតជាមួយមនុស្សដែលមានភាសាកំណើតដូចគ្នា។
- វាកាន់តែមានភាពងាយស្រួលនិងមានប្រសិទ្ធភាពក្នុងការទំនាក់ទំនងតាមរយៈការប្រើភាសាកំណើត។
- ការប្រើតែភាសាបរទេស គឺអាចជាប្រភពនៃសេចក្តីខ្មាស សម្រាប់សិស្សដែលមានអារម្មណ៍ខ្មាសអៀន និងសម្រាប់សិស្សដែលមិនប៉ិនប្រសប់នៅក្នុងការប្រើប្រាស់ភាសាបរទេស។
- ភាសាកំណើតអាចជួយធ្វើឱ្យកិច្ចការដំណើរការទៅមុខតាមរយៈការបង្កើតនូវការយល់ដឹងនៃអត្ថបទ និងអាចជួយរៀបចំកិច្ចការបានល្អ។
- ភាសាកំណើតអនុញ្ញាតឱ្យសិស្សផ្តោតអារម្មណ៍លើវាក្យស័ព្ទ និងវេយ្យាករណ៍។

- ភាសាកំណើតអាចសម្រួលដល់សកម្មភាពថ្នាក់រៀន ហើយជាពិសេសនោះគឺសម្រាប់សិស្ស ដែលមានកម្រិតទាបនិងសម្រាប់កិច្ចការដែលមានលក្ខណៈស្មុគស្មាញ។
- ភាសាកំណើតផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់សិស្សទៅលើការបង្កើតទម្រង់នៃការប្រើប្រាស់ ភាសាបរទេស ជាពិសេសអំឡុងពេលធ្វើសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន។

ចំណែក Nation (2001) បានបង្ហាញតួនាទីដ៏សំខាន់របស់ភាសាកំណើតនៅក្នុងការរៀនភាសាបរទេសដោយផ្តោតទៅលើ៖

- អត្ថន័យដោយផ្តល់លើជាតុចូល (ការរៀនតាមរយៈការស្តាប់ និងការអាន)។
- អត្ថន័យដោយផ្តល់លើជាតុចេញ (ការរៀនតាមរយៈការនិយាយ និងការសរសេរ)។
- ភាសាដោយផ្តោតលើការរៀន (ការរៀនតាមរយៈផ្តោតអារម្មណ៍យ៉ាងយកចិត្តទុកដាក់បំផុត ចំពោះ លក្ខណៈពិសេសនៃភាសា)។
- អភិវឌ្ឍភាពស្ទាត់ជំនាញ (ការរៀនតាមរយៈការធ្វើការជាមួយឧបករណ៍ដែលបានស្គាល់ ដោយឆ្លងកាត់បំណិនទាំងបួន)។

សរុបមកយើងឃើញថា ភាសាកំណើត គឺជាផ្នែកមួយដែលមិនអាចកាត់ផ្តាច់បានទេនៅក្នុងការបង្រៀនភាសា ហើយវាពិតជាមានតួនាទីសំខាន់ៗផ្សេងៗដូចជា ការបង្កើតទំនាក់ទំនងដ៏ល្អ ការធ្វើឲ្យមេរៀនកាន់តែមានអត្ថន័យច្បាស់លាស់ និងការពន្យល់គំនិតពិបាកៗជាដើម ( Paker & Karaağaç, 2015) ។ ការប្រើប្រាស់ភាសាកំណើតក្នុងបរិមាណច្រើនឬតិច គឺអាស្រ័យទៅលើភាពប៉ិនប្រសប់ឬស្ទាត់ជំនាញរបស់សិស្សនៅក្នុងការប្រើប្រាស់ភាសាអង់គ្លេស (Kavaliauskiene, 2009)។ ប៉ុន្តែការប្រើប្រាស់ភាសាកំណើតច្រើនពេក វាក៏អាចជាកំហុសឆ្គងផងដែរ។ ហេតុនេះវាគួរត្រូវបានប្រើនៅក្នុងកម្រិត និងស្ថានភាពដែលសមស្រប។

### ២.៣.១ ការប្រើប្រាស់ភាសាកំណើតរបស់គ្រូបង្រៀនក្នុងថ្នាក់ភាសាអង់គ្លេស

ការប្រើប្រាស់ភាសាកំណើតក្នុងថ្នាក់រៀនភាសាអង់គ្លេសគឺមានគោលបំណងផ្សេងៗ។ ក្នុងនោះ គ្រូបង្រៀនប្រើភាសាកំណើតដើម្បីពន្យល់ចំណុចថ្មីឬចំណុចពិបាកៗ ចំណុចវេយ្យាករណ៍ សំណួរពិបាកៗ ពន្យល់ការណែនាំ ដឹកនាំកិច្ចពិភាក្សាក្រុម ដាក់កិច្ចការផ្ទះ និងពន្យល់ការអានអត្ថបទ ( Kharma & Hajjaj, 1989)។ គ្រូបង្រៀនជាច្រើនយល់ថាការប្រើប្រាស់ភាសាកំណើតផ្តល់នូវពេលវេលាបន្ថែមទៀតសម្រាប់សិស្សដើម្បីអនុវត្តការរៀនភាសាបរទេស ពីព្រោះសិស្សទទួលបានការយល់ដឹងយ៉ាងឆាប់រហ័សតាមរយៈការប្រើប្រាស់ភាសាកំណើត ហើយគ្រូបង្រៀនប្រើប្រាស់ភាសាកំណើតដើម្បីធ្វើឱ្យគោលបំណងតាមចំណុចនីមួយៗកាន់តែច្បាស់។ មិនត្រឹមតែប៉ុណ្ណោះ ភាសាកំណើតបានអនុញ្ញាតឱ្យសិស្សយល់ដឹងពីភាពដូចគ្នា និងភាពខុសគ្នារវាងវប្បធម៌ និងទម្រង់ភាសាដែលអាចជួយធ្វើឱ្យការបកប្រែកាន់មានភាពត្រឹមត្រូវច្រើន (Morahan, 2010)។ គ្រូបង្រៀនប្រើភាសាកំណើតភាគច្រើនសម្រាប់បង្កើតនូវបរិស្ថានថ្នាក់រៀនដោយគ្មានការសម្ពុតគំរាមគំហែង ពន្យល់វេយ្យាករណ៍ បកប្រែពាក្យ រៀបចំថ្នាក់រៀន និងផ្តល់ការណែនាំ (Samadi, 2011)។ ការប្រើប្រាស់ភាសាកំណើតនៅក្នុងការបង្រៀនថ្នាក់ភាសាអង់គ្លេសត្រូវបានគេចាត់ទុកថាជាយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ ហើយវាត្រូវបានគេចែកទៅជាបីផ្នែក ចំពោះគោលបំណងរបស់គ្រូក្នុងការប្រើប្រាស់ភាសាកំណើតគឺ សម្រួលដល់ការទំនាក់ទំនងរវាងគ្រូនិងសិស្ស សម្រួលភាពចុះសម្រុងយ៉ាងសុខដុមរវាងគ្រូនិងសិស្ស និងសម្រួលដល់ការសិក្សារៀនសូត្រ (Harbord, 1992)។ បន្ថែមទៅទៀតនោះ គ្រូបង្រៀនភាសាអង់គ្លេសប្រើភាសាកំណើតដើម្បីបង្ហាញឱ្យឃើញ និងត្រួតពិនិត្យអត្ថន័យរបស់ពាក្យ ឬប្រយោគ ពន្យល់វេយ្យាករណ៍ រៀបចំថ្នាក់រៀន រក្សាវិន័យក្នុងថ្នាក់រៀន រក្សាទំនាក់ទំនងជាមួយសិស្សជាបុគ្គលៗ និងដើម្បីតេស្តការយល់ដឹងរបស់សិស្ស ( Mayni & Paramasivam , 2021)។ ជារួមយើងឃើញថា គ្រូបង្រៀនបានប្រើភាសាកំណើតដើម្បីធ្វើឱ្យសម្រេចបាននូវវត្ថុបំណងនៃមេរៀន និងដើម្បីសម្រួលដល់ការបង្រៀន និងរៀនឱ្យកាន់តែមានភាពទាក់ទាញឡើង។ តាមរយៈការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញឱ្យឃើញថា មានចំណុចខ្លះត្រូវបានលើកឡើងដោយមានលក្ខណៈប្រហាក់ប្រហែលគ្នាចំពោះគោលបំណង នៃការប្រើប្រាស់ភាសាកំណើតរបស់គ្រូនៅក្នុងការបង្រៀនភាសាអង់គ្លេស។

### ២.៣.២ ការប្រើប្រាស់ភាសាកំណើតរបស់សិស្សក្នុងថ្នាក់ភាសាអង់គ្លេស

សិស្សប្រើប្រាស់ភាសាកំណើតនៅក្នុងការរៀនភាសាអង់គ្លេស ដើម្បីធ្វើឱ្យដំណើរការនៃការរៀនកាន់តែមានភាពងាយស្រួល និងល្អប្រសើរឡើង។ ការប្រើប្រាស់ភាសាកំណើតបានចូលរួមចំណែកជួយសិស្សធ្វើការងារជាមួយដៃគូដើម្បីបាននូវដំណោះស្រាយល្អប្រសើរចំពោះកិច្ចការដែលគ្រូដាក់ឱ្យ និងដើម្បីធ្វើការវាយតម្លៃទៅលើការសរសេរ ហើយវាក្យស័ព្ទដែលជាភាសាកំណើតអនុញ្ញាតឱ្យអ្នកសិក្សាប្រើប្រាស់ភាសាដែលពួកគេមិនទាន់ចេះនៅក្នុងភាសាបរទេស ដើម្បីធ្វើឱ្យដំណើរការនូវការគិត និងឈានដល់ការយល់ដឹងកម្រិតខ្ពស់ Afzal (2013)។ Wells (1999) ភាសាកំណើតក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចការសរសេររបស់សិស្ស ពីព្រោះវាបានជួយធ្វើឱ្យការសរសេរកាន់តែមានភាពច្បាស់លាស់ និងមានន័យគ្រប់គ្រាន់ថែមទៀត។ គ្រូបង្រៀនគួរតែដឹងទស្សនៈយល់ឃើញរបស់សិស្ស ពីព្រោះវានឹងមានឥទ្ធិពលទៅលើរបៀបដែលសិស្សនឹងទទួលបានចំណេះដឹង ហើយទស្សនៈនៃការយល់ឃើញទាំងនោះនឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនៃការបង្រៀន និងរៀន ដែលអាចជាផ្នែកមួយនៃភាពជោគជ័យលើការសិក្សារបស់សិស្ស (Puspitasari, 2021)។ ចំណែក Morahan (2010) ក៏បានបង្ហាញពីការប្រើប្រាស់ភាសាកំណើតរបស់សិស្សនៅខណៈពេលដែលពួកគេកំពុងនិយាយ ដោយបានលើកឡើងថា សិស្សប្រើវាដើម្បី៖

- សួរបញ្ជាក់សំណួរឱ្យកាន់តែច្បាស់។
- បង្ហាញនូវក្តីព្រួយបារម្ភចំពោះចំណុចដែលពួកគេមិនយល់។
- ធ្វើឱ្យច្បាស់នូវអត្ថន័យនៃពាក្យជាភាសាបរទេស។
- ប្រើភាសាកំណើតដើម្បីដំណើរការគំនិតឬចំណុចពិបាកៗ។
- ស្វែងរកពាក្យថ្មីជាភាសាបរទេសដែលទាក់ទងគ្នាជាមួយពាក្យដែលបានចេះរួចមកហើយជាភាសាកំណើត។

យោងតាម Agustin & Mujiyanto (2015) បានបង្ហាញថាសិស្សប្រើភាសាកំណើត ដើម្បីសួរគ្រូអំពីមេរៀនដែលកំពុងត្រូវបានបង្រៀន ឆ្លើយសំណួរអំពីមេរៀនដែលកំពុងរៀន ជជែកជាមួយមិត្តរួមថ្នាក់

ទំនាក់ទំនងជាមួយគ្រូ ដំណើរកិច្ចការងារជាមួយដៃគូ ឬជាក្រុម និងស្វែងរកជំនួយពីមិត្តរួមថ្នាក់នៅពេលឆ្លើយសំណួរដែលគ្រូបានសួរ។

## ២.៤ សារៈសំខាន់នៃភាសាកំណើតនៅក្នុងការអប់រំ

ភាសាកំណើត គឺជាមធ្យោបាយមួយ ដែលជួយមនុស្សនៅក្នុងគ្រួសារ ក៏ដូចជានៅក្នុងប្រទេសទាំងមូលឱ្យមានការប្រាស្រ័យទាក់ទងយល់ពីគ្នាទៅវិញទៅមក។ មិនត្រឹមតែប៉ុណ្ណោះភាសាកំណើតបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការអប់រំ ដែលអនុញ្ញាតឱ្យគ្រូនិងសិស្សយល់ពីគ្នា ដើម្បីឈានទៅរកការសម្រេចបាននូវគោលបំណងរួម គឺលទ្ធផលនៃការសិក្សាប្រកបដោយប្រសិទ្ធភាព។ សិស្សត្រូវអនុវត្តយុទ្ធសាស្ត្រផ្សេងៗ ដែលជំរុញពួកគេឆ្ពោះទៅរកការសម្រេចនូវគោលដៅនៃការសិក្សារៀនសូត្ររបស់ពួកគេ។ ភាសាកំណើតក៏បានផ្សារភ្ជាប់មនុស្ស ដែលរស់នៅក្នុងសង្គមមួយ ទៅនឹងពិភពលោកខាងក្រៅតាមរយៈចំណេះដឹងដែលទទួលបានពីរបៀបនៃការប្រាស្រ័យទាក់ទងក្នុងការរស់នៅ ពីការសិក្សារៀនសូត្រដែលគ្រូផ្តល់ឲ្យសិស្ស ដែលមាននៅក្នុងសៀវភៅ និងតាមរយៈការចែករំលែកតាមទម្រង់រូបភាពផ្សេងៗទៀត។ ភាសាកំណើតត្រូវបានគេចាត់ទុកថាជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌។ ការប្រើប្រាស់ភាសាកំណើតក៏បានជំរុញសិស្សឱ្យមានការចែករំលែកវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេទៅវិញទៅមក ហើយវាក៏ជាមធ្យោបាយមួយដ៏ល្អដែលធ្វើឱ្យសិស្សយល់ដឹងនូវភាពខុសប្លែកគ្នាពីវប្បធម៌ (Verner, 2014)។ នៅពេលមនុស្សចេះភាសាកំណើតរបស់ខ្លួនឯងបានច្បាស់លាស់ វាងាយស្រួលសម្រាប់ពួកគេក្នុងការរៀនភាសាថ្មីមួយទៀត។ Atkinson (1987) បានលើកឡើងថាភាសាកំណើតបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ដោយសិស្សដែលមានកម្រិតទាបជារើយៗយល់ឃើញថាវាពិតជាពិបាកយល់ចំពោះការណែនាំរបស់គ្រូដែលបានផ្តល់ឱ្យជាភាសាអងគ្លេស។ ហេតុដូចនេះ វាពិតជាមានសារៈសំខាន់ណាស់ដែលភាសាកំណើតត្រូវបានគេប្រើប្រាស់នៅក្នុងការផ្តល់ការណែនាំមេរៀន ដើម្បីឱ្យសិស្សយល់អំពីអ្វីដែលគ្រូបានស្នើឱ្យពួកគេធ្វើ។ Auerbach (1993) បានផ្តល់នូវហេតុផលមួយចំនួនសម្រាប់ការប្រើប្រាស់ភាសាកំណើតនៅក្នុងថ្នាក់រៀនភាសាបរទេស ក្នុងនោះវាត្រូវបានគេរកឃើញថាសិស្សដែលអនុញ្ញាតឱ្យប្រើប្រាស់ភាសាកំណើតបានរៀនភាសាបរទេសលឿនជាងសិស្ស ដែលប្រើតែភាសាបរទេសនៅក្នុងថ្នាក់រៀន

របស់ពួកគេ។ ហើយការប្រើភាសាកំណើតជួយកាត់បន្ថយឧបសគ្គចំពោះការរៀនភាសាបរទេស និងធ្វើឱ្យទំនាក់នងរវាងគ្រូនិងសិស្ស ក៏ដូចជាទំនាក់ទំនងរវាងសិស្សនិងសិស្សកាន់តែប្រសើរឡើង។ ការប្រើប្រាស់ភាសាកំណើតបានជួយលើកកម្ពស់ទំនាក់ទំនងដ៏ល្អរវាងផ្ទះនិងសាលា ហើយធ្វើឱ្យការសិក្សារបស់សិស្សកាន់តែល្អប្រសើរ និងរក្សាទុកចំណេះដឹងបានយូរមិនងាយភ្លេចឡើយ។ ភាសាកំណើត គឺជាផ្នែកមួយដែលមិនអាចញែកចេញពីការបង្រៀនភាសាបរទេសបានឡើយ ហើយវាក៏មានតួនាទីមួយចំនួនដែលបានជួយគ្រូនិងសិស្សនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ ការប្រើប្រាស់ភាសាកំណើតនៅក្នុងសាលារៀនបង្កើតបានជាស្ពានដ៏ជោគជ័យមួយ សម្រាប់ផ្សារភ្ជាប់រវាងបទពិសោធនៃការសិក្សារបស់សិស្សនៅផ្ទះ និងនៅសាលារៀន។ មិនត្រឹមតែប៉ុណ្ណោះ ភាសាកំណើតដែលសិស្សានុសិស្សបានចេះនេះ នឹងជួយយ៉ាងខ្លាំងនៅក្នុងការធ្វើឱ្យការអប់រំរបស់ពួកគេមានភាពរីកចម្រើនផងដែរ (Kioko, Ndung'u, Njoroge, & Mutiga, 2014)។ តាមរយៈការសិក្សាស្រាវជ្រាវរបស់ Madriñan (2014) បានបង្ហាញឱ្យឃើញថា សិស្សអាចទាញយកប្រយោជន៍ពីការប្រើប្រាស់ភាសាកំណើតនៅក្នុងថ្នាក់រៀន ដោយប្តូរគំនិតឬការគិតពីភាសាកំណើតទៅជាភាសាថ្មីមួយទៀត។ យោងតាម Savage (2021) បានបង្ហាញថាមានសារៈសំខាន់ជាច្រើនចំពោះការរៀនរបស់សិស្សដោយប្រើភាសាកំណើតរបស់ពួកគេដែលមានដូចខាងក្រោម៖

- ភាសាកំណើតធ្វើឱ្យមានភាពងាយស្រួលសម្រាប់សិស្ស ក្នុងការចាប់យកនូវការរៀនភាសាផ្សេងទៀត។
- ភាសាកំណើតអភិវឌ្ឍនូវបុគ្គលិកលក្ខណៈ អត្តសញ្ញាណនៃវប្បធម៌ និងសង្គមរបស់សិស្ស។
- ការប្រើប្រាស់ភាសាកំណើតជួយសិស្សអភិវឌ្ឍការត្រិះរិះពិចារណា និងអភិវឌ្ឍបំណិននៃការអាន និងបំណិននៃការសរសេររបស់ពួកគេទៀតផង។
- បំណិនដែលរៀនដោយប្រើប្រាស់ភាសាកំណើត និងមិនត្រូវរៀនឡើងវិញទេ នៅពេលសិស្សប្តូរទៅរៀនដោយប្រើភាសាបរទេស។

- ការវាយតម្លៃលើខ្លួនឯងគឺមានកម្រិតខ្ពស់សម្រាប់សិស្សដែលរៀនដោយប្រើប្រាស់ភាសាកំណើត។
- ទំនាក់ទំនងរវាងឪពុកម្ដាយឬអាណាព្យាបាលនិងកូនៗ កាន់តែល្អប្រសើរ នៅពេលពួកគាត់អាចជួយកិច្ចការផ្ទះរបស់កូនៗគាត់។

Nishanthi (2020) បានលើកឡើងនូវសារៈសំខាន់នៃភាសាកំណើតត្រូវបានគេសិក្សា ពីព្រោះនៅពេលដែលសិស្សអភិវឌ្ឍភាសាកំណើត ក្នុងពេលដំណាលគ្នានោះពួកគេក៏កំពុងពង្រឹងជំនាញសំខាន់ៗផ្សេងទៀតដូចជាការគិតពិចារណា និងជំនាញអក្ខរកម្មផងដែរ។ សារៈសំខាន់នៃការប្រើភាសាកំណើតទាំងនេះត្រូវបានបង្ហាញដូចខាងក្រោម៖

- ធ្វើឱ្យមានការអភិវឌ្ឍខាងផ្នែកបញ្ញាស្មារតី។
- ធ្វើឱ្យអភិវឌ្ឍអត្តសញ្ញាណបុគ្គល និងវប្បធម៌។
- ធ្វើឱ្យមានទំនាក់ទំនងល្អប្រសើរជាមួយវប្បធម៌។
- ធ្វើឱ្យអភិវឌ្ឍមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការរៀនភាសាផ្សេងទៀត។
- ធ្វើឱ្យអភិវឌ្ឍនិងយល់ដឹងនូវជំនាញទំនាក់ទំនង។
- ជំរុញទំនុកចិត្តរបស់សិស្ស និងបង្កើតនូវការយល់ដឹងជាបុគ្គលៗ
- បង្កើតនូវឱកាសការងារ។

តាមរយៈការសិក្សាស្រាវជ្រាវរបស់ Xhemaili (2016) បានបង្ហាញឱ្យឃើញពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀនទៅលើប្រសិទ្ធភាពនៃការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងការរៀនភាសាអង់គ្លេសដូចខាងក្រោម៖

- គំនិតដែលពិបាកៗមួយចំនួនជាភាសាអង់គ្លេស ចាំបាច់ត្រូវបកប្រែជាភាសាកំណើតរបស់សិស្សដើម្បីជួយពួកគេឱ្យបន្តនូវសកម្មភាពក្នុងការធ្វើកិច្ចការក្នុងថ្នាក់រៀន។

- ការប្រើប្រាស់ភាសាកំណើតជួយសិស្សឱ្យរៀនគ្រប់ជំនាញ(ស្តាប់ និយាយ សរសេរ អាន) កាន់តែល្អប្រសើរ។
- ការប្រើប្រាស់ភាសាកំណើតធ្វើឱ្យកាន់តែច្បាស់នូវគំនិតឬវាក្យស័ព្ទដែលសិស្សមិនចេះ ហើយគ្រូមិនអាចទាញយកអត្ថន័យនៃពាក្យទាំងនោះពីសិស្សបាន ឬនៅពេលគ្រូមិនអាចទាញអត្ថន័យរបស់វាពីអត្ថបទបាន។
- ការប្រើប្រាស់ភាសាកំណើតធ្វើឱ្យសិស្សមានអារម្មណ៍មិនសូវភ័យខ្លាច នៅពេលរៀនមេរៀនពិបាកៗជាភាសាអង់គ្លេស។
- ការប្រើប្រាស់ភាសាកំណើតជួយឱ្យគ្រូអាចត្រួតពិនិត្យនូវកម្រិតយល់ដឹងរបស់សិស្សចំពោះមេរៀនពិបាកៗបាន។
- ការប្រើប្រាស់ភាសាកំណើតជួយសិស្សដែលមានកម្រិតទាបនៅពេលពួកគេរៀនវាក្យស័ព្ទថ្មី។

## ២.៥ ឥទ្ធិពលអវិជ្ជមាននៃភាសាកំណើតចំពោះការរៀនភាសាអង់គ្លេស

ការប្រើប្រាស់ភាសាកំណើតរបស់សិស្សនៅក្នុងថ្នាក់រៀនភាសាបរទេស ត្រូវបានគេលើកយកមកពិភាក្សា ដោយសារតែការប្រើប្រាស់នេះបានលេចឡើងនូវផលវិជ្ជមាន និងអវិជ្ជមានតាមរយៈការប្រើប្រាស់របស់គ្រូ និងសិស្សនៅខណៈពេលកំពុងបង្រៀន និងរៀន។ ការប្រើប្រាស់ភាសាកំណើតច្រើនហួសពេកបានបង្កជាបញ្ហានៅក្នុងការបង្រៀន និងរៀនភាសាបរទេស។ ការប្រើប្រាស់បែបនេះត្រូវបានគេចាត់ទុកថាជាប្រភពនៃកំហុសរបស់អ្នករៀនភាសាបរទេស ហើយវាគឺជាកត្តាមួយដែលធ្វើឱ្យការសិក្សាភាសាបរទេសរបស់សិស្សចុះខ្សោយ (Krashen, 1981)។ នៅពេលភាសាកំណើតត្រូវបានប្រើដើម្បីជួយសិស្ស វាអាចនាំឱ្យសិស្សងាកទៅរករបៀបនៃការប្រើប្រាស់នោះ បើទោះបីជាមិនស្ថិតក្នុងស្ថានភាពចាំបាច់ ដែលតម្រូវឱ្យប្រើវាក៏ដោយ។ ដូច្នេះវត្ថុបំណងនៃការរៀន និងការប្រើប្រាស់ភាសាបរទេសដែលបានកំណត់ត្រូវបានងាកខុសគោលដៅ (Kaynardağ, 2016)។ នៅក្នុងថ្នាក់ដែលមានសិស្សទាំងអស់មានភាសាកំណើតដូចគ្នា គ្រូបង្រៀនត្រូវប្រើជម្រើសជាច្រើនដើម្បីលើកទឹកចិត្តសិស្សឱ្យប្រើភាសាបរទេសឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។ សិស្សដែលយល់ឃើញថាខ្លួនឯងអាចឈានដល់កម្រិតអាចប្រើប្រាស់ភាសាអង់គ្លេស នឹងមាន

ទំនុកចិត្ត ក្នុងការបំលែងជំនាញនៃការទំនាក់ទំនងរបស់ពួកគេទៅជាកិច្ចការនិងស្ថានភាពផ្សេងៗទៀត។ ក្នុងនោះដើម្បីឈានដល់កម្រិតនេះបាន និងដើម្បីធ្វើឱ្យសិស្សកាន់តែមានទំនុកចិត្តលើខ្លួនឯងបាន ពួកគេត្រូវជំរុញឲ្យមានការប្រើភាសាអង់គ្លេសឱ្យបានច្រើនតាមរយៈគ្រូបង្រៀនរបស់ពួកគេ។ ការជំរុញសិស្សឱ្យប្រើប្រាស់ភាសាអង់គ្លេសនេះ គឺផ្តល់ឲ្យពួកគេនូវអារម្មណ៍មួយដែលហាក់ដូចជាពួកគេសម្រេចបាននូវភាពជោគជ័យ (Levine, 2003)។

## ២.៦ ផលជះនៃការប្រើតែភាសាអង់គ្លេសដើម្បីបង្រៀន និងរៀនភាសាអង់គ្លេស

ការរៀនភាសាគឺមិនមែនជាកិច្ចការដ៏ងាយស្រួលនោះទេ មិនថាការរៀនភាសាណាក៏ដោយ។ វិធីដ៏ល្អបំផុត គឺត្រូវជំរុញសិស្សឱ្យចាប់ផ្តើមគិត និងស្វែងយល់ពីរបៀបនៃការប្រើប្រាស់ភាសានោះ។ ការប្រើតែភាសាអង់គ្លេសនៅក្នុងថ្នាក់ គឺជាមធ្យោបាយមួយនៃការបង្រៀន និងរៀនភាសាអង់គ្លេស ដែលតម្រូវឱ្យគ្រូនិងសិស្សប្រើតែភាសាអង់គ្លេសប៉ុណ្ណោះ ដោយសិស្សមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ភាសាកំណើតរបស់ពួកគេឡើយ ដោយគ្រូជឿថាការចេញគោលការណ៍បែបនេះ គឺជាវិធីសាស្រ្តមួយដ៏មានប្រសិទ្ធភាពខ្ពស់សម្រាប់សិស្សរៀនភាសាអង់គ្លេស។ ប៉ុន្តែមានគ្រូបង្រៀនជាច្រើនយល់ថាការប្រើប្រាស់វិធីសាស្រ្តនេះក៏បានបង្កជាបញ្ហាដល់ការបង្រៀន និងរៀនផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់តែភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន គឺបានផ្តល់ឱកាសឱ្យសិស្សរៀនសូត្រតាមរយៈការប្រើប្រាស់ភាសាអង់គ្លេស និងកាន់តែមានពេលវេលាច្រើនបន្ថែមទៀតនៅក្នុងការអនុវត្ត ជំនាញនិយាយនិងជំនាញស្តាប់។ តាមរយៈវិធីសាស្រ្តនៃការប្រើប្រាស់តែភាសាអង់គ្លេសនេះ គឺជួយឱ្យសិស្សអាចរៀនគិតពីអ្វីគ្រប់យ៉ាងជាភាសាអង់គ្លេសមានការអភិវឌ្ឍក្នុងការដោះស្រាយបញ្ហា ធ្វើឱ្យរីកចម្រើនក្នុងជំនាញស្តាប់ ធ្វើឱ្យពួកគេមានការប្រាស្រ័យទាក់ទងគ្នាកាន់តែងាយស្រួល ហើយវាកាន់តែមានភាពងាយស្រួលក្នុងការគ្រប់គ្រងថ្នាក់រៀនថែមទៀតផង (Ollerton, 2022)។ Buckley (2021) បានបង្ហាញនូវសារៈសំខាន់មួយចំនួននៃការប្រើប្រាស់តែភាសាអង់គ្លេសក្នុងថ្នាក់ភាសាអង់គ្លេសដោយមិនមានរួមបញ្ចូលភាសាកំណើតឡើយ៖

- វាជាបរិស្ថានមួយដ៏ត្រឹមត្រូវ៖ សិស្សគឺអាចស្ថិតនៅក្នុងបរិបទមួយដែលពួកគេអាចប្រើបានតែភាសាអង់គ្លេសប៉ុណ្ណោះ វាជាភាសាតែមួយគត់ដែលពួកគេត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុង

ថ្នាក់រៀន។ វាប្រៀបដូចជាសិស្សដែលបានចូលរៀនថ្នាក់តែក្ងាន់ដូ គឺត្រូវរៀនតែតែក្ងាន់ដូតែប៉ុណ្ណោះពេញមួយមេរៀន ដោយពួកគេមិនអាចបែងចែកម៉ោងពាក់កណ្តាលរបស់ពួកគេទៅរៀនកីឡាយូដូផងបានទេ។

- ជាការឆ្លុះបញ្ចាំងជីវិតជាក់ស្តែង៖ សិស្សកំពុងប្រើភាសាអង់គ្លេសទៅតាមតម្រូវការជាក់ស្តែងដែលគេចង់បាន ដូចជាសុំរបស់ដែលពួកគេត្រូវការ និយាយអ្វីផ្សេងៗ និងធ្វើឱ្យការប្រើប្រាស់ភាសាកាន់តែច្បាស់ទៅតាមបរិបទនៃជីវិតពិតរបស់ពួកគេ។
- គ្មានការរំខាន៖ នៅពេលសិស្សមិនអនុញ្ញាតឱ្យប្រើភាសាកំណើត ពួកគេមិនអាចនិយាយឬជជែកជាមួយមិត្តភក្តិ ដែលនាំឱ្យបង្កជាការរំខានដល់ការបង្រៀន និងរៀនបានឡើយ។
- ធ្វើឱ្យសិស្សកាន់តែផ្តោតអារម្មណ៍៖ សិស្សមិនមានពេលជជែកគ្នាដោយប្រើភាសាកំណើតរបស់ពួកគេទេ។ ដូច្នេះពួកគេផ្តោតអារម្មណ៍ទៅលើតែមេរៀន បើសិស្សម្នាក់និយាយជាភាសាអង់គ្លេស សិស្សដទៃទៀតជាអ្នកស្តាប់។
- បង្កើននូវទំនុកចិត្ត៖ សិស្សកាន់តែមានជំនឿជាក់លើខ្លួនឯង នៅពេលពួកគេអាចប្រើភាសាអង់គ្លេសបានខ្លះ ដូចជាសួរឬឆ្លើយសំណួរងាយៗជាភាសាអង់គ្លេស។
- ពង្រឹងជំនាញនៃការនិយាយ៖ គោលការណ៍ប្រើតែភាសាអង់គ្លេសនៅក្នុងថ្នាក់ជំរុញសិស្សឱ្យកាន់តែអនុវត្តការនិយាយកាន់តែបានច្រើន។

ទន្ទឹមនឹងមានគុណសម្បត្តិ វាក៏បានផ្តល់នូវគុណវិបត្តិផងដែរក្នុងការបង្រៀន និងរៀនដោយប្រើតែគោលការណ៍ភាសាអង់គ្លេសនេះ ដោយអ្នកសិក្សាភាសាអង់គ្លេសអាចព្យាយាមរៀនចំណុចសាមញ្ញៗជាភាសាអង់គ្លេស ប៉ុន្តែការសិក្សាស្រាវជ្រាវជាច្រើនបានគាំទ្រការយល់ដឹងដែលសិស្សអាចទទួលបានលឿននៅពេលដំបូង ប្រសិនបើភាសាកំណើតរបស់ពួកគេត្រូវបានប្រើប្រាស់នៅក្នុងការណែនាំមេរៀន។ ក្នុងនោះ Moon (2000) ក៏បានបង្ហាញឱ្យឃើញពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់តែភាសាអង់គ្លេសនៅក្នុងការបង្រៀន និងរៀនដែលត្រូវបានដកស្រង់ចេញពីសៀវភៅ «Children Learning English»។

**តារាង ២.១៖ បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ភាសាអង់គ្លេស**

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| - បង្កើនបរិមាណនៃការយល់ដឹងភាសាអង់គ្លេសរបស់សិស្ស។ | - ធ្វើឱ្យចំណាយពេលច្រើនដើម្បីពន្យល់មេរៀនបន្ថែមជាមួយការប្រើប្រាស់កាយវិការ។ សិស្សដែលអន្ទះសារចង់ធ្វើសកម្មភាពអាចទៅជាគ្មានចំណាប់អារម្មណ៍ ឬអាចជាគ្មានការផ្តោតអារម្មណ៍លើមេរៀនវិញ។ |
| - អភិវឌ្ឍភាពជឿជាក់របស់សិស្សក្នុងការរៀនភាសាអង់គ្លេស។ | - សិស្សដែលរៀនខ្សោយ ឬរៀនយឺតអាចនឹងខ្វះនូវទំនុកចិត្តជឿថាពួកគេអាចរៀនតាមរយៈការប្រើប្រាស់ភាសាអង់គ្លេសបាន ពួកគេអាចភ័យខ្លាច ឬធ្វើឱ្យពួកគេលែងចង់រៀនមុខវិជ្ជាភាសាអង់គ្លេស។ |
| - ផ្តល់នូវហេតុផលពិតសម្រាប់ប្រើប្រាស់ភាសាអង់គ្លេសដើម្បីទំនាក់ទំនង (ផ្តល់ការណែនាំ ទទួលព័ត៌មានត្រឡប់ពីសិស្សវិញ)។ | - សមត្ថភាពភាសាអង់គ្លេសរបស់គ្រូអាចមានកំណត់ឬភាពស្ទាត់ជំនាញមិនគ្រប់គ្រាន់ក្នុងការប្រើប្រាស់ភាសា ដូច្នេះគ្រូអាចផ្តល់ឱ្យសិស្សនូវគំរូដែលមិនត្រឹមត្រូវ។ |
| - ធ្វើឱ្យថ្នាក់រៀនមានការប្រើប្រាស់ភាសាអង់គ្លេសបានច្រើន។ | - អាចពិបាកក្នុងការធ្វើការឆ្លុះបញ្ចាំងទៅលើការបង្រៀន ឬពិភាក្សាអំពីគំនិតរបស់សិស្សជាភាសាអង់គ្លេស ពីព្រោះភាសាអង់គ្លេសរបស់សិស្សមានដែនកំណត់ផងដែរ។ |

| | |
|---|---|
| - លើកទឹកចិត្តសិស្សឱ្យចង់រៀនភាសាអង់គ្លេស | - សម្រាប់សិស្សដែលមិនមានការជំរុញខ្ពស់ អាចត្រូវខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីយល់។ |
| - អភិវឌ្ឍភាពស្ទាត់ជំនាញរបស់សិស្សឱ្យកាន់តែល្អប្រសើរ នៅពេលសិស្សត្រូវបានលើកទឹកចិត្តឱ្យគិតជាភាសាអង់គ្លេសចាប់តាំងពីដើមដំបូងនៃមេរៀន។ | - វាអាចចំណាយពេលយូរដើម្បីគ្របដណ្តប់វគ្គសិក្សាទាំងមូល។ |

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ «**ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**» មានគោលបំណងសិក្សាស្វែងយល់ និងកំណត់ពីកម្រិតនៃការប្រើប្រាស់ភាសាកំណើតដែលជាភាសាខ្មែរ នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម។ ការសិក្សាស្រាវជ្រាវប្រធានបទខាងនេះ គឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរពីរប្រភេទ តាមបែបបរិមាណវិស័យដោយបន្សុំគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលបានលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ និងកម្មវិធីសិក្សា ព្រមទាំងការសរសេរនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់។ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងអាចឡើងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី០៥-០៦ ខែវិច្ឆកា ឆ្នាំ២០២២ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅវិទ្យាល័យចំនួន០៥ និងអនុវិទ្យាល័យចំនួន០៧ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម និងក្រុមគោលដៅបំពេញកម្រងសំណួរមាន២ប្រភេទ គឺគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងសិស្សានុសិស្សពីថ្នាក់ទី៧ ដល់ទី១២។

## ៣.២ ការប្រមូលទិន្នន័យ

ទិន្នន័យដែលទទួលបានសម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺបានតាមរយៈការរៀបចំឱ្យអ្នកចូលរួមបំពេញកម្រងសំណួរដោយផ្ទាល់។ បន្ទាប់ពីទទួលបានលិខិតឧទ្ទេសនាម លេខ២៤៦៦ អយក.ឧទន ចុះថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចាត់តាំងគ្រូណែនាំគោល និងគ្រូណែនាំរងសម្រាប់ការសរសេរនិក្ខេបបទ របស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ឆ្នាំសិក្សា ២០២០-២០២២ ដែលទទួលបានការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ និងលិខិតដែលទទួលបាន

ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម លេខ៣៨៥ អយក៥.កច ចុះថ្ងៃទី១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការ ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យ អ្នកស្រាវជ្រាវក៏បានចាប់ផ្តើមធ្វើការចុះប្រមូលទិន្នន័យ។ ដំណើរការចុះប្រមូលទិន្នន័យអ្នកសិក្សាស្រាវជ្រាវ បានរៀបចំផែនការដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅដោយផ្ទាល់ ហើយបានជួបពិភាក្សាជាមួយលោកនាយក និងនាយិកាសាលា ក្នុងគោលបំណងសុំការអនុញ្ញាតពីលោកនាយក-នាយិកា សហការ ដើម្បីសម្រួលដល់ដំណើរការនៃការប្រមូលទិន្នន័យ។ ក្រោយពីនាយក-នាយិកាសាលាបានពិនិត្យលិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា និងលិខិតអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយគាត់ក៏បានកំណត់ពេលវេលា និងអនុញ្ញាតឱ្យរៀបចំការប្រមូលទិន្នន័យទៅតាមផែនការដែលបានឯកភាពគ្នា ដោយការប្រមូលធ្វើឡើងចាប់ពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។ ខ្ញុំបាទបានចុះទៅតាមសាលាគោលដៅទៅតាមកាលបរិច្ឆេទដែលបានឯកភាពជាមួយលោកនាយក-នាយិកានៃវិទ្យាល័យនិងអនុវិទ្យាល័យនីមួយៗ ដោយយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងសហការជាមួយក្រុមគោលដៅទាំងអស់ដើម្បីទទួលបានព័ត៌មានមួយអាចគួរឱ្យជឿទុកចិត្តបានសម្រាប់យកទៅវិភាគក្នុងការសិក្សាស្រាវជ្រាវ។ សម្រាប់អ្នកពាក់ព័ន្ធក្នុងការបំពេញកម្រងសំណួរខ្ញុំបានធ្វើការណែនាំ និងពន្យល់ពីគោលបំណងនៃសំណួរ និងរបៀបនៃការឆ្លើយបំពេញកម្រងសំណួរយ៉ាងច្បាស់លាស់។ ការឆ្លើយកម្រងសំណួរមានរយៈប្រមាណពី ៣០នាទី ទៅ៤០នាទី លោកគ្រូ-អ្នកគ្រូនិងសិស្សានុសិស្សក៏បានប្រគល់កម្រងសំណួរត្រឡប់មកវិញ។ ក្នុងអំឡុងពេលចុះប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅនីមួយៗ ខ្ញុំក៏បានជម្រាបអ្នកចូលរួមពីគោលបំណងនៃការចុះសិក្សាស្រាវជ្រាវ ក្រមសីលធម៌នៃការស្រាវជ្រាវ និងអំពីសារៈសំខាន់ដែលទទួលបានពីការចូលរួមរបស់ពួកគាត់ផងដែរ។

### ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ **«ការរួមបញ្ចូលភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម»** អ្នកសិក្សាស្រាវជ្រាវ ប្រើប្រាស់កម្រងសំណួរ

ចំនួនពីរប្រភេទក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ពីលោកគ្រូ-អ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងសិស្សានុសិស្សពីថ្នាក់ទី៧-១២ នៅក្នុងចំណោមសាលាកម្រិតវិទ្យាល័យ និងអនុវិទ្យាល័យសរុបចំនួន១២ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម។ ក្នុងការរៀបចំចងក្រងកម្រងសំណួរ អ្នកសិក្សាស្រាវជ្រាវបានធ្វើការរៀបចំ និងកែសម្រួលកម្រងសំណួរចេញពីការសិក្សាស្រាវជ្រាវរបស់ Pardede, P. (2018); Afzal, S. (2013) និង Mazdayasna, G., & Fazilatfar, A. M. (2010) ដោយមានការកែសម្រួលពាក្យពេចន៍និងចំណុចខ្លះដើម្បីធ្វើឱ្យកម្រងសំណួរនេះ ឆ្លើយតបទៅនឹងប្រធានបទខាងលើ។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញដែលបានប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធ ទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និងគូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់សូចនាករ វាយតម្លៃទៅលើកម្រិត នៃការយល់ឃើញរបស់គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សនៅកម្រិតថ្នាក់ទី៧-១២ ទៅលើការរួមបញ្ចូលភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មានចំនួន៥កម្រិត ពីទាបបំផុត (១) ទៅខ្ពស់បំផុត (៥) ដែលមានកម្រិតចង្អុលបង្ហាញដូចខាងក្រោម៖

កម្រិត ១ គឺ មិនយល់ស្របទាល់តែសោះ

កម្រិត ២ គឺ មិនយល់ស្រប

កម្រិត ៣ គឺ ពុំមានយោបល់

កម្រិត ៤ គឺ យល់ស្រប

កម្រិត ៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗគឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

១.00 ដល់ ១.៨០ មានន័យថា ខ្សោយខ្លាំង

១.៨១ ដល់ ២.៦០ មានន័យថា ខ្សោយ

២.៦១ ដល់ ៣.៤០ មានន័យថា មធ្យម

៣.៤១ ដល់ ៤.២០ មានន័យថា ល្អ

៤.២១ ដល់ ៥.00 មានន័យថា ល្អណាស់

**៣.៣.២ កម្រងសំណួរ**

គោលបំណងនៃកម្រងសំណួរនេះគឺដើម្បីសិក្សាស្វែងយល់ពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងសិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ និងកម្រិតនៃការប្រើប្រាស់ភាសាខ្មែរដែលជាភាសាកំណើត នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស នៅក្នុងខេត្តកំពង់ចាម។ ទិន្នន័យដែលប្រមូលបានគឺប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

៣.៣.២.១- កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរសម្រាប់គ្រូបង្រៀន ត្រូវបានប្រើប្រាស់សម្រាប់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសពីថ្នាក់ទី៧ ដល់ទី១២ ដែលចែកចេញជា ពីរផ្នែកគឺ៖

ផ្នែកទី១៖ ព័ត៌មានប្រជាសាស្ត្រ

មាន៧សំណួរ ដែលទាក់ទងទៅនឹង ឯកទេស កម្រិតនៃការបង្រៀន អង្គភាពបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍នៃការបង្រៀន។

ផ្នែកទី២៖ ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនក្នុងការប្រើប្រាស់ភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា

នៅក្នុងផ្នែកនេះ មានសមាសភាគចំនួន ០៦ គឺការយល់ឃើញរបស់គ្រូលើការប្រើប្រាសភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស (១២សំណួរ) ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការជួយសិស្សរៀនបំណិនភាសា (០៤សំណួរ) ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសា (០២សំណួរ) ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់របស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស (០២សំណួរ) ការយល់ឃើញរបស់គ្រូចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារៈសម្រាប់រៀន (០៣សំណួរ) រួមជាមួយនិងកម្រិតនៃការប្រើប្រាស់និងយល់ដឹងភាសាអង់គ្លេសនិងភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស (០៣សំណួរ)។ កម្រងសំណួរទាំងអស់សម្រាប់ប្រើជាឧបករណ៍វាស់វែងនៃការយល់ឃើញរបស់គ្រូបង្រៀន ទៅលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។

៣.៣.២.២- កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរសិស្ស គឺប្រើសម្រាប់ប្រមូលទិន្នន័យពីសិស្សដែលកំពុងរៀនពីថ្នាក់ទី៧-១២ អំពីការយល់ឃើញទៅលើការរួមបញ្ចូលភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសដែលចែកចេញជាពីរផ្នែកៈ

ផ្នែកទី១៖ ព័ត៌មានប្រជាសាស្ត្រ

មាន៤ សំណួរ ទាក់ទងទៅនឹងព័ត៌មានប្រជាសាស្ត្រនេះ មានដូចជា កម្រិតថ្នាក់រៀន រៀននៅវិទ្យាល័យ/អនុវិទ្យាល័យ ភេទ និងអាយុ។

ផ្នែកទី២៖ ទស្សនៈយល់ឃើញរបស់សិស្សទៅលើការប្រើភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា

នៅក្នុងផ្នែកនេះមានសមាសភាគចំនួន ០៦ គឺការយល់ឃើញរបស់សិស្សទាក់ទងនឹងការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេស (១២សំណួរ) ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនភាសាអង់គ្លេស (០៤សំណួរ) ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសាភាសាអង់គ្លេស (០២សំណួរ) ការយល់ឃើញរបស់សិស្សលើការ

ប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសា (០២សំណួរ) ការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរទៅលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស (០៣សំណួរ) និងកម្រិតនៃការប្រើប្រាស់ យល់ដឹងភាសាអង់គ្លេសនិងភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស(០៣សំណួរ)។ កម្រងសំណួរទាំងអស់សម្រាប់ប្រើជាឧបករណ៍វាស់វែងនៃការយល់ឃើញរបស់សិស្ស ទៅលើការប្រើប្រាស់ភាសាខ្មែរដែលជាភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរធ្វើឡើងនៅក្នុងវិទ្យាល័យចំនួន ០៥និងអនុវិទ្យាល័យចំនួន ០៧ នៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ដែលមានចំនួនសំណាកសរុប ២៩២នាក់ ក្នុងនោះ លោកគ្រូ-អ្នកគ្រូចំនួន ៤២នាក់ និងសិស្សានុសិស្សចំនួន ២៥០នាក់។ ខាងក្រោមនេះ ជាតារាងលំអិតនៃការជ្រើសរើសរើសភាគសំណាក ដោយប្រើវិធី Purposive Sampling (ជ្រើសរើសសំណាកតាមគោលបំណងរបស់អ្នកស្រាវជ្រាវ)។

**តារាង ៣.១ ភាគសំណាកនៃការស្រាវជ្រាវ**

| ល.រ | ឈ្មោះសាលា/ចំនួនសំណាក | ចំនួនគ្រូ | | ចំនួនសិស្ស | | | | | | ចំនួនសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ទុតិយភូមិ | បឋមភូមិ | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ | ថ្នាក់ទី១០ | ថ្នាក់ទី១១ | ថ្នាក់ទី១២ | |
| ១ | វិ.ហ៊ុនសែនជើងធ្នូក | ០៣ នាក់ | ០៤ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ៤៣ នាក់ |
| ២ | វិ.សតជ.ហ៊ុនសែនសង្កើប | ០៤ នាក់ | ០២ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ៤២ នាក់ |
| ៣ | វិ.សតជ.ហ៊ុនសែនបាធាយ | ០៣ នាក់ | ០២ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ៤១ នាក់ |
| ៤ | វិ.ហោណាំហុងព្រៃញា | ០៣ នាក់ | ០២ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ៤១ នាក់ |
| ៥ | វិ.សតជ.ហ៊ុនសែនសណ្ដោក | ០២ នាក់ | ០៤ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ០៦ នាក់ | ៤២ នាក់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦ | អនុវិទ្យាល័យ ដាលា | ០០ នាក់ | ០២ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១២ នាក់ |
| ៧ | អនុវិទ្យាល័យ ច្បារអំពៅ | ០០ នាក់ | ០២ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១២ នាក់ |
| ៨ | អនុវិទ្យាល័យ សិរីចំប៉ាមេត្រីង | ០០ នាក់ | ០១ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១១ នាក់ |
| ៩ | អនុវិទ្យាល័យ ជើងព្រៃ | ០០ នាក់ | ០២ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១២ នាក់ |
| ១០ | អនុវិទ្យាល័យ ទំនប់ | ០០ នាក់ | ០២ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១២ នាក់ |
| ១១ | អនុវិទ្យាល័យ តាំងក្រសាំង | ០០ នាក់ | ០២ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១២ នាក់ |
| ១២ | អនុវិទ្យាល័យ ត្រប់ | ០០ នាក់ | ០២ នាក់ | ០៣ នាក់ | ០៣ នាក់ | ០៤ នាក់ | ០០ នាក់ | ០០ នាក់ | ០០ នាក់ | ១២ នាក់ |
| **សរុបចំនួនសំណាក** | | **១៥ នាក់** | **២៧ នាក់** | **៥១ នាក់** | **៥១ នាក់** | **៥៨ នាក់** | **៣០ នាក់** | **៣០ នាក់** | **៣០ នាក់** | **២៩២ នាក់** |

## ៣.៥ ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានប្រើវិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់ជាកម្រិតនៃចំនួនភាគរយសម្រាប់ស្វែករកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវបានប្រើកម្មវិធីវិភាគទិន្នន័យតាមកម្មវិធី SPSS និងប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បីសង់ក្រាបដែលប្រមូលបានពីកម្រងសំណួរដែលបានចុះប្រមូលផ្ទាល់។ ការវិភាគនេះនឹងផ្តោតទៅលើព័ត៌មានទូទៅរបស់គ្រូ-សិស្សដែលបានចូលរួមក្នុងការសិក្សា ភេទ កម្រិតនៃការសិក្សា កម្រិតវប្បធម៌ បទពិសោធន៍ការងារ និងទស្សនៈយល់ឃើញជាដើម។

# ជំពូក ៤
# លទ្ធផល និងការពិភាក្សា

# ជំពូក ៤៖ លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយលទ្ធផលនិងពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ លើក្រុមគោលដៅដែលពាក់ព័ន្ធនិងប្រធានបទស្រាវជ្រាវដែលរួមមាន៖ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស នៅកម្រិតវិទ្យាល័យ និងអនុវិទ្យាល័យក្នុងស្រុកបាធាយ ខេត្តកំពង់ចាម។ លទ្ធផលដែលទទួលបាននឹងត្រូវបានយកមកពិភាក្សាលើចំណុចសំខាន់នានា ដោយផ្តោតទៅលើការយល់ឃើញរបស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងការយល់ឃើញរបស់សិស្សានុសិស្ស លើការរួមបញ្ចូលភាសាកំណើត (ភាសាខ្មែរ) នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។ បន្ថែមទៅទៀត ការសិក្សាស្រាវជ្រាវនេះ និងបង្ហាញឱ្យឃើញពីកម្រិតនៃការប្រើប្រាស់ភាសាកំណើតរបស់គ្រូបង្រៀន និងសិស្សនៅក្នុងថ្នាក់ភាសាអង់គ្លេស។

## ៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ ស្តីពីព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន និងសិស្សានុសិស្ស

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានកំណត់យកវិទ្យាល័យចំនួន០៥ និងអនុវិទ្យាល័យចំនួន០៧ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាមរួមមាន៖ វិទ្យាល័យហ៊ុនសែនជើងធ្នុក វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសង្កើប វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនបាធាយ វិទ្យាល័យហោណាំហុងព្រៃញា វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសណ្តែក រួមជាមួយអនុវិទ្យាល័យជាលា អនុវិទ្យាល័យច្បារអំពៅ អនុវិទ្យាល័យសិរីចំប៉ាមេត្រីង អនុវិទ្យាល័យជើងព្រៃ អនុវិទ្យាល័យទំនប់ អនុវិទ្យាល័យតាំងក្រសាំង និងអនុវិទ្យាល័យត្រប់។ ក្នុងផ្នែកនេះដែរ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញព័ត៌មានទូទៅរបស់គ្រូបង្រៀន និងសិស្សានុសិស្សដែលជាភាគសំណាកនៅក្នុងការសិក្សាស្រាវជ្រាវ ហើយបានផ្តោតលើព័ត៌មានសំខាន់ៗដូចតទៅ៖ អំពីគ្រូបង្រៀនលើ មុខវិជ្ជាឯកទេស កម្រិតថ្នាក់បង្រៀន ទីកន្លែងបម្រើការងារ ភេទ ក្រុមអាយុ កម្រិតវប្បធម៌ និងបទពិសោធន៍បម្រើការងារ និងព័ត៌មានអំពីសិស្ស កម្រិតថ្នាក់ ទីកន្លែងសិក្សា ភេទ និងអាយុ។

### ៤.១.១ ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន

តាមរយៈទិន្នន័យក្នុងឧបសម្ព័ន្ធ (ខ) បង្ហាញថាគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិចំនួន ២៧នាក់ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ១៥នាក់ បានចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវនេះដែលសរុបមានចំនួន ៤២នាក់ ស្រី១៤នាក់ ដោយក្នុងនោះមានគ្រូបង្រៀនមកពី វិទ្យាល័យហ៊ុនសែនជើងធ្នូកចំនួន ០៧នាក់ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសង្កើបចំនួន ០៦នាក់ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនបាជាយ ចំនួន០៥នាក់ វិទ្យាល័យហោណាំហុងព្រៃញាចំនួន ០៥នាក់ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសណ្តែក មានចំនួន០៦នាក់ អនុវិទ្យាល័យជាលា ចំនួន០២នាក់ អនុវិទ្យាល័យច្បារអំពៅ ចំនួន០២នាក់ អនុវិទ្យាល័យសិរីចំប៉ាមេព្រីងចំនួន ០១នាក់ អនុវិទ្យាល័យជើងព្រៃ ចំនួន០២នាក់ អនុវិទ្យាល័យទំនប់ ចំនួន០២នាក់ អនុវិទ្យាល័យតាំងក្រសាំង ចំនួន០២នាក់ និងអនុវិទ្យាល័យគ្រប់ ចំនួន០២នាក់។

- មុខវិជ្ជាឯកទេស៖ ដោយសារកត្តាខ្វះគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងកម្រិតទុតិយភូមិ ដូច្នេះទើបមានគ្រូបង្រៀនមុខវិជ្ជាផ្សេងៗទៀតបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដែលសាលានីមួយៗកំពុងជួបប្រទះ។ ដោយក្នុងនោះគ្រូបង្រៀនដែលមានឯកទេសភាសាអង់គ្លេសមានចំនួន ២៣ (៥៤.៨%) ឯកទេសប្រវត្តិវិទ្យាមានចំនួន ០១នាក់ (២.៤០%) ឯកទេសភាសាខ្មែរមានចំនួន ០២នាក់ (៤.៨០%) ឯកទេសភាសាខ្មែរ-អង់គ្លេសមានចំនួន ០៩នាក់ (២១.៤%) ឯកទេសអប់រំកាយ និងកីឡាមានចំនួន០២នាក់ (៤.៨០%) និងគ្រូបង្រៀនកម្រិតបឋមសិក្សាមានចំនួន ០៥នាក់ (១១.៩%)។

- ក្រុមអាយុ៖ គ្រូបង្រៀនដែលមានអាយុចាប់ពី ២០-២៥ឆ្នាំ មានចំនួន ០៣នាក់ (៧.១០%) អាយុចន្លោះពី ២៦-៣០ឆ្នាំ មានចំនួន ១០នាក់ (២៣.៨%) អាយុពី ៣១-៣៥ឆ្នាំ មានចំនួន ០៦នាក់ (១៤.៣%) អាយុពី ៣៦-៤០ឆ្នាំ មានចំនួន ១៣នាក់ (១៣.០%) និងអាយុលើសទី ៤០ឆ្នាំ មានចំនួន ១០នាក់ (២៣.៨%)។

- កម្រិតវប្បធម៌៖ គ្រូបង្រៀនដែលបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន ១៥នាក់ (៣៥.៧%) មានបរិញ្ញាបត្រមានចំនួន ២០នាក់ (៤៧.៦%) និងគ្រូបង្រៀនដែលបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ មាន ចំនួន ០៧នាក់ (១៦.៧%)។

- បទពិសោធន៍បង្រៀន៖ បង្រៀនចាប់ពី ១-៣ឆ្នាំ មានចំនួន ០៥នាក់ (១១.៩%) បង្រៀនចាប់ពី ៤-៦ ឆ្នាំ មានចំនួន ១២នាក់ (២៨.៦%) បង្រៀនចាប់ពី ៧-១០ឆ្នាំ មានចំនួន ០៥នាក់ (១១.៩%) និង បង្រៀនលើសពី ១០ឆ្នាំ មានចំនួន ២០នាក់ (៤៧.៦%)។

### ៤.១.២ ព័ត៌មានប្រជាសាស្ត្ររបស់សិស្ស

តាមទិន្នន័យក្នុងឧបសម្ព័ន្ធ (ឃ) បង្ហាញថាសិស្សានុសិស្ស ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានចំនួនសរុប ២៥០នាក់ ស្រី ១៦០នាក់ ដោយក្នុងនោះមកពី វិទ្យាល័យហ៊ុនសែនជើងឆ្នុក ចំនួន ៣៦នាក់ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសង្កើប មានចំនួន ៣៦នាក់ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនបាធាយចំនួន ៣៦នាក់ វិទ្យាល័យហោណាំហុងព្រៃញា មានចំនួន ៣៦នាក់ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសណ្តែក មានចំនួន៣៦នាក់ អនុវិទ្យាល័យជាលា ចំនួន១០នាក់ អនុវិទ្យាល័យច្បារអំពៅ ចំនួន១០នាក់ អនុវិទ្យាល័យសិរីចំប៉ាមេព្រីង ចំនួន ១០នាក់ អនុវិទ្យាល័យជើងព្រៃ ចំនួន១០នាក់ អនុវិទ្យាល័យទំនប់ ចំនួន១០នាក់ អនុវិទ្យាល័យតាំងក្រសាំង ចំនួន១០នាក់ និងអនុវិទ្យាល័យគ្រប់ ចំនួន១០នាក់។

- កម្រិតថ្នាក់៖ សិស្សថ្នាក់ទី៧ មានចំនួន ៥១នាក់ (២០.៤%) ទី៨ មានចំនួន ៥១នាក់(២០.៤%) ទី៩ មានចំនួន ៥៨នាក់ (២៣.២%) ថ្នាក់ទី១០ មានចំនួន៣០នាក់ (១២.០%) ថ្នាក់ទី១១ មានចំនួន៣០ នាក់ (១២.០%) និងថ្នាក់ទី១២មានចំនួន ៣០នាក់ (១២.០%)។

- ក្រុមអាយុ៖ សិស្សដែលមានអាយុ ១១ឆ្នាំមានចំនួន ០២នាក់ (០.៨០%) អាយុ១២ឆ្នាំ មានចំនួន ១៩ នាក់ (៧.៦០%) អាយុ១៣ឆ្នាំ មានចំនួន ៣៥នាក់ (១៤.០%) អាយុ១៤ឆ្នាំ មានចំនួន ៥២នាក់ (២០.៨%) អាយុ១៥ឆ្នាំ មានចំនួន ៦០នាក់ (២៤.០%) អាយុ១៦ឆ្នាំ មានចំនួន ៣៤នាក់ (១៣.៦%)

អាយុ១៧ឆ្នាំ មានចំនួន ២៩នាក់ (១១.៦%) អាយុ១៨ឆ្នាំ មានចំនួន ១៦នាក់ (៦.៤០%) និងអាយុ២០ ឆ្នាំ មានចំនួន ០៣នាក់ (១.២០%)។

## ៤.២ ទិន្នន័យឆ្លើយតបលើការប្រើប្រាស់ភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ

អ្នកសិក្សាស្រាវជ្រាវនេះនឹងធ្វើការវិភាគទៅលើមធ្យមភាគ ភាគរយ និងកម្រិតវាស់វែងនៃសូចនាករនីមួយៗរបស់គ្រូបង្រៀន និងសិស្សានុសិស្សទៅលើការប្រើប្រាស់ភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាដែលមាននៅក្នុងកម្រងសំណួរសម្រាប់គ្រូបង្រៀន និងសិស្ស។

### ៤.២.១ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការប្រើប្រាស់ភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា

ក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវទទួលបានការឆ្លើយតបពីគ្រូបង្រៀនតាមរយៈកម្រងសំណួរទៅលើចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងទៅនឹងការយល់ឃើញ និងកម្រិតនៃការប្រើប្រាស់ភាសាខ្មែរនៅក្នុងការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស។ ចំណុចទាំងនោះរួមមានដូចជា ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស ការប្រើប្រាស់ភាសាខ្មែរនៅក្នុងការជួយសិស្សរៀនបំណិនភាសា ការប្រើប្រាស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសា ការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស ការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស និងកម្រិតនៃការប្រើប្រាស់និងយល់ដឹងភាសាអង់គ្លេសនិងភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។

**តារាង ៤.១៖ ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំចូលចិត្តប្រើទាំងភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងការបង្រៀនភាសាអង់គ្លេស | ៤.០៤ | ០.៥៨ | ល្អ |

| | | | | |
|---|---|---|---|---|
| ២ | ខ្ញុំចូលចិត្តស្នើឱ្យសិស្សរបស់ខ្ញុំបកប្រែពាក្យឬប្រយោគជាភាសាខ្មែរដើម្បីពិនិត្យមើលការយល់ដឹងរបស់ពួកគេ | ៣.៧៣ | ០.៨៨ | ល្អ |
| ៣ | ការប្រើភាសាខ្មែរនៅក្នុងថ្នាក់ភាសាអង់គ្លេស គឺកាត់បន្ថយភាពភ័យខ្លាចរបស់សិស្ស | ៣.៥២ | ១.០៨ | ល្អ |
| ៤ | ខ្ញុំយល់ឃើញថាសិស្សរបស់ខ្ញុំមានអារម្មណ៍ភ័យខ្លាចនៅពេលពួកគេមិនយល់អ្វីដែលខ្ញុំកំពុងនិយាយជាភាសាអង់គ្លេស | ៣.៦១ | ០.៩៣ | ល្អ |
| ៥ | ខ្ញុំប្រើភាសាខ្មែរ គឺដើម្បីគ្រប់គ្រងថ្នាក់រៀន (ណែនាំមេរៀន បែងចែកកិច្ចការឱ្យសិស្សធ្វើការងារជាក្រុម ឬជាបុគ្គលៗ...) | ៣.៨៣ | ០.៩៣ | ល្អ |
| ៦ | ខ្ញុំមិនចូលចិត្តប្រើភាសាខ្មែរនៅក្នុងថ្នាក់រៀនទេ ពីព្រោះវាធ្វើឱ្យសិស្សគិតអ្វីមិនបានច្រើនជាភាសាអង់គ្លេស | ២.៧៦ | ១.០៧ | មធ្យម |
| ៧ | ខ្ញុំចូលចិត្តប្រើភាសាខ្មែរដើម្បីពន្យល់គំនិតឬចំណុចណាដែលស្មុគស្មាញ | ៤.២១ | ០.៥១ | ល្អណាស់ |
| ៨ | ខ្ញុំប្រើភាសាខ្មែរគឺដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅកាន់សិស្ស | ៣.៦៦ | ០.៧៥ | ល្អ |
| ៩ | ជាការល្អប្រសើរចំពោះការប្រើប្រាស់តែភាសាអង់គ្លេសប៉ុណ្ណោះនៅក្នុងថ្នាក់រៀនភាសាអង់គ្លេស | ៣.០៧ | ១.០៩ | មធ្យម |
| ១០ | ជាការល្អប្រសើរចំពោះការប្រើភាសាអង់គ្លេសសម្រាប់ការប្រាស្រ័យទាក់ទងក្នុងការបង្រៀន និងរៀន ហើយប្រើភាសាខ្មែរសម្រាប់តែចំណុចណាដែលស្មុគស្មាញតែប៉ុណ្ណោះ | ៤.១៤ | ០.៦០ | ល្អ |

| | | | | |
|---|---|---|---|---|
| ១១ | ការប្រើភាសាខ្មែរជួយសិស្សឱ្យបង្ហាញអារម្មណ៍ និងគំនិតរបស់ពួកគេនៅពេលពួកគេមិនអាចពន្យល់បានជាភាសាអង់គ្លេស | ៤.០៤ | ០.៤៣ | ល្អ |
| ១២ | របៀបតែមួយគត់នៃការរៀនពាក្យភាសាអង់គ្លេសគឺត្រូវដឹងអត្ថន័យនៃពាក្យជាភាសាខ្មែរ | ៣.២៣ | ១.០៥ | មធ្យម |
| **សរុប** | | **៣.៦៥** | **០.៤៥** | **ល្អ** |

តាមតារាងខាងលើ បានបង្ហាញថា សមាសភាគទាំង១២ នៃទស្សនៈរបស់គ្រូបង្រៀនលើការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេសនៅតាមសាលាមធ្យមសិក្សាគឺមានតម្លៃមធ្យមភាគខុសៗគ្នា ដែលក្នុងនោះសមាសភាគចំនួន០៨ មានកម្រិតល្អ សមាសភាគចំនួន០៣ មានកម្រិតមធ្យម និងមានតែសមាសភាគចំនួន០១ ប៉ុណ្ណោះដែលទទួលបាន កម្រិតល្អណាស់។ ចំណុចដែលទទួលបានលំដាប់មធ្យមភាគខ្ពស់ជាច់គេក្នុងកម្រិតល្អណាស់គឺ គ្រូបង្រៀនចូលចិត្តប្រើភាសាខ្មែរដើម្បីពន្យល់គំនិតឬចំណុចណាដែលស្មុគស្មាញ ដែលមានមធ្យមភាគ = ៤.២១ ហើយសមាសភាគ ចំនួន០៨ ទៀតដែលស្ថិតក្នុងកម្រិតល្អ គឺមានមធ្យមភាគចន្លោះពី ៣.៥២ ដល់ ៤.១៤។ ទន្ទឹមនឹងនោះផងដែរ ចំពោះផ្នែកដែលទទួលបានកម្រិតមធ្យមមានចំនួន០៣ នៅក្នុងចំណោម១២ចំណុចនេះ គឺរបៀបតែមួយគត់នៃការរៀនពាក្យភាសាអង់គ្លេសគឺត្រូវដឹងអត្ថន័យពាក្យជាភាសាខ្មែរ (មធ្យមភាគ= ៣.៦៥) ចំណុចនេះបានបញ្ជាក់ឱ្យឃើញថាការយល់ឃើញរបស់គ្រូបង្រៀនចំពោះការរៀនវាក្យស័ព្ទភាសាអង់គ្លេសគឺមានវិធីសាស្ត្រជាច្រើន ដោយមិនផ្តោតលើតែការបកប្រែពាក្យទាំងនោះជាភាសាខ្មែរនោះទេ។ សម្រាប់ចំណុចទី២ ដែលទទួលបានកម្រិតមធ្យម គឺជាការល្អប្រសើរចំពោះការប្រើប្រាស់តែភាសាអង់គ្លេសប៉ុណ្ណោះនៅក្នុងថ្នាក់រៀនភាសាអង់គ្លេស (មធ្យមភាគ= ៣.០៧) និងចំណុចទី៣ គឺគ្រូបង្រៀនមិនចូលចិត្តប្រើភាសាខ្មែរនៅក្នុងថ្នាក់រៀនទេ ពីព្រោះវាធ្វើឱ្យសិស្សគិតអ្វីមិនបានច្រើនជាភាសាអង់គ្លេស (មធ្យមភាគ = ២.៧៦)។ ចំណុចទី២ និងទី៣នេះ គឺបានឆ្លើយតបគ្នាទៅវិញទៅមក ដែលមានន័យថា តាមទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមុខវិជ្ជាភាសា

អង់គ្លេស គឺពួកគាត់មិនប្រើប្រាស់តែភាសាអង់គ្លេសនៅក្នុងការបង្រៀននោះទេ គឺពួកគាត់ក៏បានបញ្ចូលភាសាខ្មែរដែលជាភាសាកំណើតរបស់សិស្សផងដែរ ដែលការប្រើប្រាស់ភាសាខ្មែរនេះជួយសិស្សឱ្យប្រមូលជាតុចូលបានច្រើនជាភាសាអង់គ្លេស។

**តារាង ៤.២៖ ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការជួយសិស្សរៀនបំណិនភាសា**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញស្តាប់ | ៣.១៦ | ១.១២ | មធ្យម |
| ២ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញនិយាយ | ៣.៣០ | ១.០៩ | មធ្យម |
| ៣ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញអាន | ៣.៧១ | ០.៩៩ | ល្អ |
| ៤ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញសរសេរ | ៣.៩០ | ០.៩៣ | ល្អ |
| **សរុប** | | **៣.៥២** | **០.៣៤** | **ល្អ** |

យោងតាមតារាង ៤.២ បានបង្ហាញថា សមាសភាគទាំង០៤ នៃការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការជួយសិស្សរៀនបំណិនភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាមានកម្រិតខុសៗគ្នា ដោយក្នុងនោះចំណុចដែលទទួលបានកម្រិតល្អមានចំនួន០២ គឺការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញសរសេរ (មធ្យមភាគ= ៣.៩០) និងការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញអាន (មធ្យមភាគ=៣.៧១)។ ចំណែកសមាសភាគចំនួន០២ទៀត ទទួលបានកម្រិតមធ្យម គឺការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញនិយាយ (មធ្យមភាគ=៣.៣០) និងការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញស្តាប់ (មធ្យមភាគ=៣.១៦)។ យោងតាមទិន្នន័យខាងលើបានបង្ហាញថា គ្រូបង្រៀនភាសាអង់គ្លេសយល់ឃើញថាការប្រើប្រាស់ភាសាខ្មែរ គឺជួយសិស្សក្នុងការរៀនជំនាញអាន និងជំនាញសរសេរបានល្អប្រសើរ ចំណែកជំនាញស្តាប់ និងជំនាញនិយាយវិញការប្រើប្រាស់ភាសាខ្មែរពុំសូវមានប្រសិទ្ធភាពនោះទេ។

**តារាង ៤.៣៖ ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសា**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការប្រើប្រាស់ភាសាខ្មែរជួយសិស្សក្នុងការរៀនវាក្យស័ព្ទភាសាអង់គ្លេស | ៤.០២ | ០.៥៦ | ល្អ |
| ២ | ការប្រើប្រាស់ភាសាខ្មែរជួយសិស្សក្នុងការរៀនវេយ្យាករណ៍ភាសាអង់គ្លេស | ៤.០៤ | ០.៥៨ | ល្អ |
| **សរុប** | | **៤.០៣** | **០.០១** | **ល្អ** |

តាមទិន្នន័យតារាង ៤.៣ បានបង្ហាញពីមធ្យមភាគសរុប នៃការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសាអង់គ្លេស គឺទទួលបានកម្រិតល្អ (មធ្យមភាគ = ៤.០៣)។ ចំណុចទី១ ការប្រើប្រាស់ភាសាខ្មែរជួយសិស្សក្នុងការរៀនវាក្យស័ព្ទភាសាអង់គ្លេស ទទួលបានកម្រិតល្អ (មធ្យមភាគ = ៤.០២) និងចំណុចទី២ ការប្រើប្រាស់ភាសាខ្មែរជួយសិស្សក្នុងការរៀនវេយ្យាករណ៍ភាសាអង់គ្លេស (មធ្យមភាគ = ៤.០៤)។ ទិន្នន័យខាងលើនេះបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនយល់ស្របចំពោះសារៈសំខាន់នៃការប្រើប្រាស់ភាសាខ្មែរក្នុងការបង្រៀនវាក្យស័ព្ទ និងវេយ្យាករណ៍ភាសាអង់គ្លេស។

**តារាង ៤.៤៖ ការយល់ឃើញរបស់គ្រូទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការប្រើប្រាស់ភាសាខ្មែរជួយសិស្សក្នុងការធ្វើការងារជាក្រុម | ៣.៣៨ | ០.៩៣ | មធ្យម |
| ២ | សិស្សគួរតែបានអនុញ្ញាតឱ្យឆ្លើយតបដោយប្រើភាសាខ្មែរ | ៣.២៨ | ១.១៥ | មធ្យម |
| **សរុប** | | **៣.៣៣** | **០.០៦** | **មធ្យម** |

តារាង ៤.៤ បានបង្ហាញឱ្យឃើញពីការយល់ឃើញរបស់គ្រូទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេសរវាងគ្រូ-សិស្ស និងរវាងសិស្ស-សិស្ស ក្នុងកិច្ចដំណើរការនៃការបង្រៀននិងរៀនដោយសមាសភាគទាំងពីរនេះ សរុបគឺទទួលបានកម្រិតមធ្យម (មធ្យមភាគ = ៣.៣៣) ដែលក្នុងនោះចំណុចទី១ គឺការប្រើប្រាស់ភាសាខ្មែរជួយសិស្សក្នុងការធ្វើការងារជាក្រុម គឺទទួលបានកម្រិតមធ្យមផងដែរ (មធ្យភាគ = ៣.៣៨) និងចំណុចមួយទៀត សិស្សគួរតែបានអនុញ្ញាតឱ្យឆ្លើយតបដោយប្រើភាសាខ្មែរទទួលបានកម្រិតមធ្យម (មធ្យមភាគ = ៣.២៨)។ តាមទិន្នន័យខាងលើបានបង្ហាញថា តាមទស្សនៈយល់ឃើញរបស់គ្រូបង្រៀន យល់ថាភាសាខ្មែរបានចូលរួមចំណែកនៅក្នុងកម្រិតមធ្យមសម្រាប់ការធ្វើការងារជាក្រុមរបស់សិស្ស ហើយគ្រូយល់ថាសិស្សគួរអនុញ្ញាតឱ្យឆ្លើយតបដោយប្រើប្រាស់ភាសាខ្មែរនៅក្នុងកម្រិតមធ្យមផងដែរ។

**តារាង ៤.៥៖ ការយល់ឃើញរបស់គ្រូចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀន**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការកត់ត្រាចំណាំជាភាសាខ្មែរធ្វើឱ្យសិស្សរៀនបានច្បាស់ល្អ | ៣.៤២ | ០.៩៦ | ល្អ |
| ២ | ការប្រើប្រាស់វចនានុក្រម ភាសាអង់គ្លេស-ខ្មែរ និងខ្មែរ-អង់គ្លេស គឺមានប្រយោជន៍សម្រាប់សិស្សជាងការប្រើវចនានុក្រមតែមួយភាសា (អង់គ្លេស-អង់គ្លេស) | ៣.៧៣ | ០.៩៣ | ល្អ |
| ៣ | ការបង្ហាញឱ្យឃើញនូវភាពខុសគ្នា និងដូចគ្នារវាងភាសាអង់គ្លេស និងភាសាខ្មែរ ជួយសិស្សក្នុងការរៀនភាសាអង់គ្លេស | ៣.៨០ | ០.៥៥ | ល្អ |
| **សរុប** | | **៣.៦៥** | **០.២០** | **ល្អ** |

យោងតាមតារាង ៤.៥ បានបង្ហាញពីសមាសភាគទាំងបីនៃការយល់ឃើញរបស់គ្រូចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស ដោយក្នុងនោះទទួលបានមធ្យមភាគសរុបគឺកម្រិតល្អ (មធ្យមភាគ = ៣.៦៥)។ ចំណុចនីមួយៗនៅក្នុងផ្នែកនេះទទួលបានកម្រិតល្អ ដែលមានមធ្យមភាគចន្លោះពី ៣.៤២ ដល់ ៣.៨០។ តាមរយៈទិន្នន័យនេះបានបង្ហាញឱ្យឃើញពីទស្សនៈរបស់គ្រូបង្រៀនភាសាអង់គ្លេស ចំពោះការប្រើប្រាស់ភាសាខ្មែរក្នុងការកត់ត្រាមេរៀនរបស់សិស្សគឺធ្វើឱ្យពួកគេរៀនបានល្អ ហើយក៏បង្ហាញឱ្យឃើញថាការប្រើប្រាស់វចនានុក្រមពីរភាសា(អង់គ្លេស-ខ្មែរ និង ខ្មែរ-អង់គ្លេស) គឺពិតជាមានលក្ខណៈល្អប្រសើរជាងវចនានុក្រមតែមួយភាសា ដែលប្រៀបបានដូចជាឧបករណ៍មួយជួយសម្រួលដល់ការរៀនភាសាអង់គ្លេសរបស់សិស្សឱ្យកាន់តែមានប្រសិទ្ធខ្ពស់។ ក្នុងនោះការបង្ហាញឱ្យឃើញនូវភាពខុសគ្នា និងដូចគ្នារវាងភាសាអង់គ្លេស និងភាសាខ្មែរ គឺជួយផ្តល់នូវភាពងាយស្រួលដល់សិស្សក្នុងការរៀនភាសាអង់គ្លេសផងដែរ។

**តារាង ៤.៦៖ ទិន្នន័យសរុប ការយល់ឃើញរបស់គ្រូបង្រៀនលើការប្រើប្រាស់ភាសាខ្មែរក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាសភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស | ៣.៦៥ | ០.៤៥ | ល្អ |
| ២ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការជួយសិស្សរៀនបំណិនភាសា | ៣.៥២ | ០.៣៤ | ល្អ |
| ៣ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់របស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសា | ៤.០៣ | ០.០១ | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស | ៣.៣៣ | ០.០៦ | មធ្យម |
| ៥ | ការយល់ឃើញរបស់គ្រូចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារៈសម្រាប់រៀន | ៣.៦៥ | ០.២០ | ល្អ |
| **សរុប** | | **៣.៦៣** | **០.២៥** | **ល្អ** |

តារាងទិន្នន័យ ៤.៦ បានបង្ហាញឱ្យឃើញពីមធ្យមភាគសរុប លើការយល់ឃើញរបស់គ្រូបង្រៀនចំពោះការប្រើប្រាស់ភាសាខ្មែរក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ដែលមានមធ្យមភាគសរុប ៣.៦៣ ហើយទទួលបានកម្រិតល្អ។ ក្នុងនោះសមាសភាគចំនួន ០១ ដែលទទួលបានមធ្យមភាគខ្ពស់ជាងគេ គឺការយល់ឃើញរបស់គ្រូលើការប្រើប្រាស់របស់ភាសាខ្មែរក្នុងការជួយសិស្សរៀនសមាសភាគភាសា (មធ្យមភាគ=៤.០៣) និងសមាសភាគបន្ទាប់គឺ ការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស និងការយល់ឃើញរបស់គ្រូចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀន (មធ្យមភាគ = ៣.៦៥)។ ក្នុងនោះផងដែរ មានសមាសភាគចំនួនមួយដែលទទួលបានកម្រិតមធ្យម គឺការយល់ឃើញរបស់គ្រូលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស (មធ្យមភាគ = ៣.៣៣)។ តាមទស្សនៈរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាយល់ថា ភាសាខ្មែរបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ ក្នុងនោះគ្រូបង្រៀនចូលចិត្តប្រើទាំងភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន ហើយការប្រើប្រាស់ភាសាខ្មែរនេះគឺ ដើម្បីពន្យល់ចំណុចពិបាកៗនៅក្នុងមេរៀន ផ្តល់ព័ត៌មានត្រឡប់ទៅកាន់សិស្ស និងដើម្បីគ្រប់គ្រងថ្នាក់រៀនជាដើម។ គ្រូបង្រៀនយល់ថាការប្រើប្រាស់ភាសាខ្មែរ បានជួយកាត់បន្ថយភាពភ័យខ្លាចរបស់សិស្សនៅពេលពួកគេរៀនភាសាអង់គ្លេសផងដែរ។ មិនត្រឹមតែប៉ុណ្ណោះទេ គ្រូបង្រៀនយល់ថា ការប្រើភាសាខ្មែរបានជួយសិស្សក្នុងការរៀនបំណិននៅក្នុងភាសាអង់គ្លេសជាពិសេស គឺជំនាញអាន និងសរសេរ។ ការប្រើប្រាស់ភាសាកំណើតនេះ ក៏ជួយសិស្សក្នុងការរៀនសមាសភាគភាសាអង់គ្លេស ដែលមានដូចជាការរៀនវាក្យស័ព្ទ និងការរៀន

វេយ្យាករណ៍ជាដើម ហើយផ្តល់ឱ្យសិស្សនូវការយល់ដឹងផ្នែកសម្ភារសម្រាប់រៀនទៀតផង។ ទោះបីជាយ៉ាងក៏ដោយ គ្រូបង្រៀនមិនសូវគាំទ្រឱ្យមានការប្រើប្រាស់ភាសាខ្មែរច្រើនពេកទេ នៅក្នុងអន្តរកម្មថ្នាក់រៀន គឺសម្រាប់ការធ្វើការងារក្រុម និងការឆ្លើយតបរបស់សិស្ស។

**ក្រាប ៤.១៖ រង្វាយតម្លៃរបស់គ្រូបង្រៀនលើកម្រិតនៃការយល់ដឹងភាសាអង់គ្លេសរបស់សិស្ស**




យោងតាមទិន្នន័យក្រាប ៤.១ បានបង្ហាញពីកម្រិតភាគរយនៃការយល់ភាសាអង់គ្លេសរបស់សិស្ស នៅពេលដែលគ្រូបង្រៀនបានប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។ ក្នុងនោះសិស្សដែលបានយល់ដឹងក្នុងកម្រិតចន្លោះពី ០-១៩% មានចំនួន ៩.៥០% ហើយសិស្សដែលយល់ដឹងក្នុងកម្រិតចន្លោះពី ២០-៣០% មានចំនួន ២៣.៨%។ ចំណែកកម្រិតចន្លោះដែលមានភាគរយខ្ពស់ជាងគេគឺចន្លោះពី ៤០-៥៩% ដោយទទួលបានចំនួន ៤២.៩% ហើយកម្រិតដែលទទួលបានភាគរយទាបជាងគេ (២.៤០%) គឺចន្លោះពី ៨០-១០០%។ យោងតាមការវង្វាយតម្លៃនេះបានបញ្ជាក់ឱ្យឃើញថា កម្រិតសមត្ថភាពនៃការយល់ដឹងភាសាអង់គ្លេសរបស់សិស្សនៅមធ្យមសិក្សាភាគច្រើនគឺអាចយល់បាននៅក្នុងកម្រិតមធ្យម (៤០-៥៩%) នៅពេលដែលគ្រូរបស់ពួកគេប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។

ក្រាប ៤.២ ៖ កម្រិតនៃការប្រើភាសាអង់គ្លេស និងភាសាខ្មែររបស់គ្រូបង្រៀននៅក្នុងថ្នាក់ភាសាអង់គ្លេស




តាមទិន្នន័យនៃក្រាប ៤.២ បានបង្ហាញពីកម្រិតភាគរយខុសៗគ្នានៃការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែររបស់គ្រូបង្រៀននៅក្នុងថ្នាក់រៀនភាសាអង់គ្លេស។ យើងអាចឃើញថា កម្រិតនៃការប្រើប្រាស់ដែលមានភាគរយខ្ពស់ជាងគេគឺ ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% និង ភាសាខ្មែរ ៤០-៥៩% មានចំនួន ៥៧.១% ហើយការប្រើប្រាស់ភាសាអង់គ្លេស ចន្លោះពី ២០-៣៩% និងភាសាខ្មែរពី ៦០-៧០% មានចំនួន ២៣.៨% បន្ទាប់មកទៀតគឺ ការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ៦០-៧០% និងភាសាខ្មែរពី ២០-៣០% មានចំនួន១៤.៣%។ ក្នុងនោះផងដែរ ភាគរយដែលទាបជាងគេ គឺការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ០-១៩% និងភាសាខ្មែរ ៨០-១០០% និងការប្រើប្រាស់ភាសាអង់គ្លេសពី ៨០-១០០% និងភាសាខ្មែរ ០-១៩% មានចំនួន ២.៤០% តែប៉ុណ្ណោះ។ លទ្ធផលនៃទិន្នន័យនេះបង្ហាញថា មានគ្រូបង្រៀនតិចតួចណាស់ដែលបានប្រើតែភាសាខ្មែរ ឬតែភាសាអង់គ្លេសក្នុងការបង្រៀន។ ផ្ទុយទៅវិញយើងឃើញថា គ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាភាគច្រើន (៨០.៩%) បានប្រើប្រាស់ភាសាខ្មែរ ក្នុងកម្រិតពីមធ្យមទៅបង្គួរ និងភាសាអង់គ្លេសពីកម្រិតតិចទៅមធ្យមដែលមានន័យថា គ្រូបង្រៀនមិនប្រើប្រាស់តែភាសាអង់គ្លេស ឬតែភាសាខ្មែរច្រើនលើសលុបនៅក្នុងការបង្រៀននោះទេ។ សរុបមក គឺពួកគាត់បានធ្វើការរួមបញ្ចូលភាសាខ្មែរដែលជាភាសាកំណើតរបស់សិស្សនៅក្នុងការបង្រៀនភាសាអង់គ្លេស។

ក្រាប ៤.៣៖ ការយល់ឃើញរបស់គ្រូបង្រៀនទៅលើកម្រិតនៃការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស




យោងតាមក្រាប ៤.៣ បានបង្ហាញឱ្យឃើញពីទស្សនៈផ្សេងៗគ្នារបស់គ្រូបង្រៀនទៅលើកម្រិតភាគរយនៃភាសាខ្មែរដែលគួរត្រូវបានប្រើប្រាស់នៅក្នុងថ្នាក់រៀនភាសាអង់គ្លេស។ ទិន្នន័យនេះបានបង្ហាញថា កម្រិតភាគរយដែលខ្ពស់ជាងគេបំផុត តាមរយៈការយល់ឃើញរបស់គ្រូបង្រៀន គឺភាសាខ្មែរគួរប្រើប្រាស់នៅក្នុងការបង្រៀនភាសាអង់គ្លេសនៅកម្រិតចន្លោះពី ២០-៣៩% មានចំនួន ៥២.៤% ដែលមានន័យថា ភាសាខ្មែរគួរប្រើប្រាស់ក្នុងកម្រិតមួយឱ្យបានតិចជាងភាសាអង់គ្លេសនៅក្នុងការបង្រៀននិងរៀន។ ក្នុងនោះផងដែរ គ្រូបង្រៀនដែលយល់ថាភាសាខ្មែរគួរប្រើនៅកម្រិតពី ៤០-៥៩% មានចំនួន ២៨.៦%។ ចំណែកគ្រូចំនួន ១៤.៣% យល់ថាភាសាខ្មែរគួរប្រើប្រាស់ឱ្យបានច្រើនជាងភាសាអង់គ្លេស គឺនៅក្នុងកម្រិតចន្លោះពី ៦០-៧៩%។ តាមរយៈទិន្នន័យនេះក៏បានបង្ហាញផងដែរ ពីកម្រិតដែលទាបជាងគេបំផុតគឺចន្លោះពី ០-១៩% និងកម្រិតខ្ពស់ជាងគេបំផុតគឺ ៨០-១០០% នៃការយល់ឃើញរបស់គ្រូបង្រៀនក្នុងការប្រើប្រាស់ភាសាខ្មែរ ដោយចំណុចទាំងពីរនេះទទួលបានការយល់ស្របចំនួន ២.៤០%។ ជារួមយើងឃើញថា គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើន (៨១.០%) យល់ថាភាសាខ្មែរគួរប្រើប្រាស់ពីកម្រិតតិចទៅមធ្យម (២០-៥៩%) នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។

## ក្រាប ៤.៤៖ ទំនាក់ទំនងរវាងកម្រិតនៃការបង្រៀននិងការប្រើភាសាអង់គ្លេស-ខ្មែរ




តាមរយៈក្រាប ៤.៤ បានបង្ហាញឱ្យឃើញពីកម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស-ខ្មែររបស់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិ លើមុខវិជ្ជាភាសាអង់គ្លេស ដោយក្នុងនោះយើងឃើញថា គ្រូបង្រៀនទាំងពីរកម្រិតនេះភាគច្រើនប្រើភាសាអង់គ្លេសនៅចន្លោះ ៤០-៥០% និងភាសាខ្មែរពី ៤០-៥០% ដូចគ្នា។ ក្នុងនោះគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិប្រើភាសាអង់គ្លេសនៅចន្លោះ ៤០-៥០% និងភាសាខ្មែរពី ៤០-៥០% មានចំនួន ៥៣.៣% ហើយគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិដែលប្រើភាសាអង់គ្លេស-ខ្មែរនៅក្នុងកម្រិតដូចគ្នានេះផងដែរមានចំនួន ៥៩.៣%។ នៅក្នុងទិន្នន័យនេះក៏បានបង្ហាញថាមានគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៣.៣% និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិចំនួន ១៨.៥% បានប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ២០-៣៩% និងភាសាខ្មែរចន្លោះពី ៦០-៧៩% ចំណុចនេះបង្ហាញឱ្យឃើញថាកម្រិតមធ្យមសិក្សាទុតិយភូមិមានការប្រើប្រាស់ភាសាខ្មែរច្រើនជាង គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិបន្តិច។ ចំណែកឯការប្រើភាសាអង់គ្លេសចន្លោះពី ៦០-៧៩% និងភាសាខ្មែរចន្លោះពី ២០-៣៩% វិញមានគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ចំនួន ១៣.៣% និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិចំនួន ១៤.៨%។ សរុបមកយើងឃើញថា ការប្រើប្រាស់ភាសាអង់គ្លេស-ខ្មែររបស់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិភាគច្រើនមានកម្រិតប្រហាក់ប្រហែលគ្នា។

ក្រាប ៤.៥៖ ទំនាក់ទំនងរវាង បទពិសោធនៃការបង្រៀនភាសាអង់គ្លេស និងការប្រើប្រាស់ភាសាអង់គ្លេស-ភាសាខ្មែរ




តាមទិន្នន័យនៃក្រាបខាងលើបង្ហាញឱ្យឃើញពីការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរដោយផ្អែកទៅតាមបទពិសោធនៃកាបង្រៀនភាសាអង់គ្លេស ដែលក្នុងនោះគ្រូបង្រៀនដែលមានបទពិសោធពី ១-៣ ឆ្នាំទាំងអស់បានប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរចន្លោះពី ៤០-៥៩% ហើយគ្រូបង្រៀនដែលមានបទពិសោធពី ៤-៦ឆ្នាំ ចំនួន៥៨.៣% ក៏បានប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរនៅក្នុងកម្រិតភាគរយដូចគ្នានេះផងដែរ។ ទិន្នន័យនេះក៏បានបង្ហាញផងដែរថា គ្រូបង្រៀនដែលមានបទពិសោធពី ៤-៦ ឆ្នាំចំនួន ២៥.០% បានប្រើប្រាស់ភាសាអង់គ្លេសពី ៦០-៧៩% និងភាសាខ្មែរពី ២០-៣៩%។ សម្រាប់គ្រូដែលមានបទពិសោធពី ៧-១០ឆ្នាំ ចំនួន ៤០.០% បានប្រើប្រាស់ភាសាអង់គ្លេសពី ២០-៣៩% និងភាសាខ្មែរ ៦០-៧៩% ហើយចំនួន៤០.០% បានប្រើប្រាស់ភាសាអង់គ្លេសនិងភាសាខ្មែរពី ៤០-៥៩% និងចំនួន ២០.០% បានប្រើប្រាស់ភាសាអង់គ្លេសពី ៦០-៧០% និងភាសាខ្មែរ ២០-៣៩%។ សម្រាប់គ្រូបង្រៀនដែលមានបទពិសោធលើសពី ១០ឆ្នាំ ចំនួន៣៥.០% បានប្រើប្រាស់ភាសាអង់គ្លេសពី ២០-៣៩% និងភាសាខ្មែរពី ៦០-៧៩% ហើយចំនួន៥០.០% បានប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរពី ៤០-៥៩% និងចំនួន១០.០% បានប្រើភាសាអង់គ្លេសពី ៦០-៧៩% និងភាសាខ្មែរពី ២០-៣៩%។ ទិន្នន័យនេះបញ្ជាក់ថាគ្រូបង្រៀនទាំងពីរកម្រិតភាគច្រើនប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរនៅកម្រិតមធ្យម។

### ៤.២.២ ទិន្នន័យឆ្លើយតបរបស់សិស្សលើការប្រើភាសាកំណើតនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា

ក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវទទួលបានការឆ្លើយតបពីសិស្សានុសិស្សតាមរយៈកម្រងសំណួរទៅលើចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងទៅនឹងការយល់ឃើញ ហើយនិងកម្រិតនៃការប្រើប្រាស់ភាសាកំណើតនៅក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេស។ ចំណុចទាំងនោះរួមមានដូចជា ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេស ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនភាសាអង់គ្លេស ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសា ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសា ការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរទៅលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស និងកម្រិតនៃការប្រើប្រាស់និងយល់ដឹងភាសាអង់គ្លេស និងភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។

**តារាង ៤.៧៖ ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេស**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំចង់ឱ្យគ្រូរបស់ខ្ញុំប្រើទាំងភាសាខ្មែរនិងភាសាអង់គ្លេសនៅក្នុងការបង្រៀនភាសាអង់គ្លេស | ៤.១១ | ០.៦៣ | ល្អ |
| ២ | ខ្ញុំចូលចិត្តបកប្រែពាក្យឬប្រយោគជាភាសាខ្មែរដើម្បីពិនិត្យមើលការយល់ដឹងរបស់ខ្ញុំ | ៤.១៤ | ០.៦៨ | ល្អ |
| ៣ | ការប្រើភាសាខ្មែរនៅក្នុងថ្នាក់រៀនភាសាអង់គ្លេសគឺកាត់បន្ថយភាពភ័យខ្លាចរបស់ខ្ញុំ | ៣.៥៧ | ១.០៦ | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | ខ្ញុំមានអារម្មណ៍ភ័យខ្លាចនៅពេលខ្ញុំមិនយល់អ្វីដែលគ្រូរបស់ខ្ញុំកំពុងនិយាយជាភាសាអង់គ្លេស | ៣.៣៧ | ១.១៤ | មធ្យម |
| ៥ | ខ្ញុំចង់ឱ្យគ្រូរបស់ខ្ញុំប្រើភាសាខ្មែរដើម្បីគ្រប់គ្រងថ្នាក់រៀន (ណែនាំមេរៀន បែងចែកកិច្ចការឱ្យសិស្សធ្វើការងារជាក្រុម ជាបុគ្គលៗ...) | ៣.៩២ | ០.៨៩ | ល្អ |
| ៦ | ខ្ញុំមិនចូលចិត្តប្រើភាសាខ្មែរនៅក្នុងថ្នាក់រៀនទេ ពីព្រោះវាធ្វើឱ្យខ្ញុំគិតអ្វីមិនបានច្រើនជាភាសាអង់គ្លេស | ២.៤០ | ១.០៦ | ខ្សោយ |
| ៧ | ខ្ញុំចង់ឱ្យគ្រូរបស់ខ្ញុំប្រើភាសាខ្មែរដើម្បីពន្យល់គំនិតឬចំណុចណាដែលស្មុគស្មាញ | ៤.២៤ | ០.៦៧ | ល្អណាស់ |
| ៨ | គ្រូរបស់ខ្ញុំប្រើភាសាខ្មែរគឺដើម្បីផ្តល់ព័ត៌មានត្រឡប់មកកាន់សិស្ស (កែកិច្ចការផ្ទះ...) | ៣.៩៤ | ០.៧៣ | ល្អ |
| ៩ | ជាការល្អប្រសើរចំពោះការប្រើប្រាស់តែភាសាអង់គ្លេសប៉ុណ្ណោះក្នុងថ្នាក់ភាសាអង់គ្លេស | ២.៦៤ | ១.១៤ | មធ្យម |
| ១០ | ជាការល្អប្រសើរចំពោះការប្រើភាសាអង់គ្លេសសម្រាប់ការប្រាស្រ័យទាក់ទងក្នុងការបង្រៀន និងរៀន ហើយប្រើភាសាខ្មែរសម្រាប់តែចំណុចណាដែលស្មុគស្មាញតែប៉ុណ្ណោះ | ៣.៩៣ | ០.៩៦ | ល្អ |
| ១១ | ការប្រើភាសាខ្មែរជួយឱ្យខ្ញុំបង្ហាញអារម្មណ៍និងគំនិតរបស់ខ្ញុំនៅពេលខ្ញុំមិនអាចពន្យល់បានជាភាសាអង់គ្លេស | ៤.០៦ | ០.៧៣ | ល្អ |

| | | | | |
|---|---|---|---|---|
| ១២ | របៀបតែមួយគត់នៃការរៀនពាក្យភាសាអង់គ្លេសគឺត្រូវដឹងអត្ថន័យពាក្យជាភាសាខ្មែរ | ៣.៩១ | ០.៩៨ | ល្អ |
| **សរុប** | | **៣.៦៩** | **០.៥៩** | **ល្អ** |

តាមរយៈទិន្នន័យតារាង ៤.៧ បានបង្ហាញពីសមាសភាគទាំង១២ នៃការយល់ឃើញរបស់សិស្ស ទាក់ទងនឹងការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេសនៅតាមសាលាកម្រិតមធ្យមសិក្សា ដែលមាន សមាសភាគចំនួន០៨ ទទួលបានកម្រិតល្អ សមាសភាគចំនួន០២ ទទួលបានកម្រិតមធ្យម សមាសភាគ ចំនួន០១ ទទួលបានកម្រិតខ្សោយ និងចំនួន០១ ទទួលបានកម្រិតល្អណាស់។ ចំណុចដែលទទួលបាន មធ្យមភាគខ្ពស់ជាងគេគឺ ខ្ញុំចង់ឱ្យគ្រូរបស់ខ្ញុំប្រើភាសាខ្មែរដើម្បីពន្យល់គំនិតឬចំណុចណាដែលស្មុគស្មាញ (មធ្យមភាគ = ៤.២៤) ដោយទទួលបានកម្រិតល្អណាស់ ហើយមានសមាសភាគចំនួន ០៨ទៀតដែល ទទួលបានកម្រិតល្អ ដែលមានចន្លោះមធ្យមភាគពី ៣.៥៧ ដល់ ៤.១៤។ ក្នុងនោះមាសភាគចំនួន ០២ ដែលទទួលបានកម្រិតចង្អុលបង្ហាញមធ្យម គឺខ្ញុំមានអារម្មណ៍ភ័យខ្លាចនៅពេលខ្ញុំមិនយល់អ្វីដែលគ្រូរបស់ ខ្ញុំកំពុងនិយាយជាភាសាអង់គ្លេស (មធ្យមភាគ = ៣.៣៧) និងចំណុចមួយទៀតគឺ ជាការល្អប្រសើរចំពោះ ការប្រើប្រាស់តែភាសាអង់គ្លេសប៉ុណ្ណោះក្នុងថ្នាក់ភាសាអង់គ្លេស (មធ្យមភាគ = ២.៦៤) ហើយចំណុច ដែលទទួលបានកម្រិតខ្សោយ គឺខ្ញុំមិនចូលចិត្តប្រើភាសាខ្មែរនៅក្នុងថ្នាក់រៀនទេ ពីព្រោះវាធ្វើឱ្យខ្ញុំគិតអ្វីមិន បានច្រើនជាភាសាអង់គ្លេស (មធ្យមភាគ = ២.៤០)។ តាមទិន្នន័យខាងលើនេះបង្ហាញឱ្យឃើញថាសិស្ស ចង់ឱ្យគ្រូបង្រៀនរបស់ពួកគេប្រើប្រាស់ភាសាខ្មែរ ដើម្បីពន្យល់គំនិតឬចំណុចណាដែលស្មុគស្មាញនៅក្នុង មេរៀន ផ្តល់ព័ត៌មានត្រឡប់ ហើយពួកគេចូលចិត្តប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេស ពីព្រោះវាធ្វើ ឲ្យពួកគេប្រមូលគំនិតបានច្រើនជាភាសាអង់គ្លេស។ ផ្ទុយទៅវិញសិស្សានុសិស្សមិនយល់ស្របក្នុងការប្រើ ប្រាស់តែភាសាអង់គ្លេសនៅក្នុងការបង្រៀន និងរៀននោះទេ ហើយការប្រើប្រាស់ភាសាខ្មែរក៏បានជួយកាត់ បន្ថយភាពភ័យខ្លាចរបស់ពួកគេ នៅពេលរៀនភាសាអង់គ្លេសផងដែរ។

តារាង ៤.៨៖ ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនភាសាអង់គ្លេស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញស្តាប់ | ៣.៨២ | ០.៧៣ | ល្អ |
| ២ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញនិយាយ | ៣.៧០ | ០.៩០ | ល្អ |
| ៣ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញអាន | ៣.៧៣ | ០.៩៨ | ល្អ |
| ៤ | ការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញសរសេរ | ៣.៦៨ | ០.៧២ | ល្អ |
| **សរុប** | | **៣.៧៨** | **០.០៧** | **ល្អ** |

តាមតារាងទិន្នន័យខាងលើ បានបង្ហាញពីសមាសភាគចំនួន០៤ នៃការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនបំណិនភាសាអង់គ្លេស ដែលសមាសភាគទាំង ០៤ខាងលើ ទទួលបានកម្រិតល្អទាំងអស់ ដោយមានមធ្យមភាគចន្លោះពី ៣.៦៨ ដល់ ៣.៨២។ យើងឃើញថា ចំណុចនៃការប្រើភាសាខ្មែរគឺជួយក្នុងការរៀនជំនាញស្តាប់ គឺទទួលបានមធ្យមភាគខ្ពស់ជាងគេ (មធ្យមភាគ = ៣.៨២) ហើយចំណុចនៃការប្រើប្រាស់ភាសាខ្មែរគឺជួយក្នុងការរៀនជំនាញនិយាយ និងការប្រើប្រាស់ភាសាខ្មែរគឺជួយក្នុងការរៀនជំនាញអាន គឺមានមធ្យមភាគប្រហាក់ប្រហែលគ្នាគឺ ៣.៧០ និង ៣.៧៣ រៀងគ្នា។ ចំណែកផ្នែកដែលទទួលបានមធ្យមទាបជាងគេនោះ គឺការប្រើប្រាស់ភាសាខ្មែរគឺជួយក្នុងការរៀនជំនាញសរសេរ (មធ្យម = ៣.៦៨)។ ទោះបីមធ្យមភាគទាំង ០៤ មានកម្រិតខុសគ្នាក៏ដោយ យើងឃើញថាចំណុចនីមួយៗទទួលបានកម្រិតចង្អុលបង្ហាញល្អដូចៗគ្នា។ ជារួមទិន្នន័យខាងលើនេះបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា សិស្សមានជំនឿជាក់យ៉ាងខ្លាំងទៅលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនទាំងបួននៃភាសាអង់គ្លេស។ ចំណុចនេះមានលក្ខណៈខុសពីការយល់ឃើញរបស់គ្រូបង្រៀនបន្តិច ដោយគ្រូបង្រៀនយល់ថា ការប្រើប្រាស់ភាសាខ្មែរគឺ ជួយសិស្សបានកម្រិតល្អតែនៅក្នុងបំណិននៃការសេរសេរ និងការអាន ប៉ុន្តែសម្រាប់បំណិននៃការនិយាយ និងការស្តាប់ភាសាខ្មែរជួយក្នុងកម្រិតមធ្យមតែប៉ុណ្ណោះ។

**តារាង ៤.៩៖ ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសា**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការប្រើប្រាស់ភាសាខ្មែរជួយក្នុងការរៀនវាក្យស័ព្ទភាសាអង់គ្លេស | ៤.១៦ | ០.៦៨ | ល្អ |
| ២ | ការប្រើប្រាស់ភាសាខ្មែរជួយក្នុងការរៀនវេយ្យាករណ៍ភាសាអង់គ្លេស | ៤.១០ | ០.៧៤ | ល្អ |
| **សរុប** | | **៤.១៣** | **០.០៤** | **ល្អ** |

តារាង ៤.៩ បានបង្ហាញឱ្យឃើញពីមធ្យមភាគសរុបនៃការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសាអង់គ្លេស ដោយទទួលបានកម្រិតចង្អុលបង្ហាញល្អ (មធ្យមភាគ = ៤.១៣)។ ចំណុចទី១ ការប្រើប្រាស់ភាសាខ្មែរជួយក្នុងការរៀនវាក្យស័ព្ទភាសាអង់គ្លេសមានកម្រិតល្អ (មធ្យមភាគ = ៤.១៦) ហើយចំណុចមួយទៀត គឺការប្រើប្រាស់ភាសាខ្មែរជួយក្នុងការរៀនវេយ្យាករណ៍ភាសាអង់គ្លេស ក៏ទទួលបានកម្រិតល្អផងដែរ (មធ្យមភាគ = ៤.១០)។ តាមរយៈទិន្នន័យនេះបង្ហាញថាសិស្សានុសិស្សជឿជាក់ថាភាសាខ្មែរពិតជាបានចូលរួមចំណែកយ៉ាងខ្លាំងនៅក្នុងការរៀនវាក្យស័ព្ទ និងការរៀនវេយ្យាករណ៍ភាសាអង់គ្លេស។

**តារាង ៤.១០៖ ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសា**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការប្រើប្រាស់ភាសាខ្មែរជួយក្នុងការធ្វើការងារជាក្រុម | ៣.៩៣ | ០.៧៤ | ល្អ |
| ២ | ការប្រើប្រាស់ភាសាខ្មែរធ្វើឱ្យខ្ញុំមានអារម្មណ៍កាន់តែមានទំនុកចិត្តដើម្បីឆ្លើយសំណួរ | ៣.៩៨ | ០.៨៤ | ល្អ |
| **សរុប** | | **៣.៩៥** | **០.០៣** | **ល្អ** |

យោងតាមទិន្នន័យខាងលើ បានបង្ហាញពីការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងអន្តរកម្មថ្នាក់រៀនភាសាអង់គ្លេស ដោយសមាសភាគសរុបទទួលបានកម្រិតល្អ (មធ្យមភាគ = ៣.៩៥)។ ក្នុងនោះចំណុចទី១ ការប្រើប្រាស់ភាសាខ្មែរជួយក្នុងការធ្វើការងារជាក្រុម ទទួលបានកម្រិតល្អ (មធ្យមភាគ = ៣.៩៣) ហើយចំណុចទី២ ការប្រើប្រាស់ភាសាខ្មែរធ្វើឱ្យខ្ញុំមានអារម្មណ៍កាន់តែមានទំនុកចិត្តដើម្បីឆ្លើយសំណួរ ក៏ទទួលបានកម្រិតល្អផងដែរ (មធ្យមភាគ = ៣.៩៨)។ តាមទិន្នន័យនេះ បានបង្ហាញឱ្យឃើញថាសិស្សានុសិស្សយល់ថាភាសាខ្មែរបានរួមចំណែកយ៉ាងខ្លាំងចំពោះអន្តរកម្មថ្នាក់រៀន គឺជួយពួកគេនៅក្នុងការធ្វើការងារជាក្រុម និងធ្វើឲ្យសិស្សកាន់តែមានទំនុកចិត្តក្នុងការឆ្លើយតបនៅពេលគ្រូរបស់ពួកគេសួរសំណួរ។

**តារាង ៤.១១៖ ការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការកត់ត្រាចំណាំជាភាសាខ្មែរធ្វើឱ្យខ្ញុំរៀនភាសាអង់គ្លេសបានច្បាស់ល្អ | ៤.១៦ | ០.៨១ | ល្អ |
| ២ | ចូលចិត្តប្រើវចនានុក្រម អង់គ្លេស-ខ្មែរ និង ខ្មែរ-អង់គ្លេស ជាងវចនានុក្រមតែមួយភាសា (អង់គ្លេស-អង់គ្លេស) | ៣.៨៥ | ០.៨៨ | ល្អ |
| ៣ | ការពន្យល់របស់គ្រូអំពីភាពខុសគ្នាឬដូចគ្នារវាងភាសាអង់គ្លេស និងភាសាខ្មែរគឺមានប្រយោជន៍នៅក្នុងការរៀនភាសាអង់គ្លេស | ៣.៧៦ | ០.៨៣ | ល្អ |
| **សរុប** | | **៣.៩២** | **០.២០** | **ល្អ** |

តាមទិន្នន័យតារាង ៤.១១ បានបង្ហាញឱ្យឃើញពីសមាសភាគទាំងបីនៃការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរទៅលើការយល់ដឹងសម្ភារៈសម្រាប់រៀនភាសាអង់គ្លេស ដោយសរុបផ្នែកទាំងបីនេះគឺទទួលបានកម្រិតល្អ (មធ្យមភាគ = ៣.៩២)។ ចំណុចទី១ ការកត់ត្រាចំណាំជាភាសាខ្មែរធ្វើឱ្យខ្ញុំរៀនបានច្បាស់ល្អ ទទួលបានកម្រិតល្អ (មធ្យមភាគ = ៣.៨៥) ហើយចំណុចទី២ ចូលចិត្តប្រើវចនានុក្រម អង់គ្លេស-ខ្មែរ និង ខ្មែរ-អង់គ្លេស ជាងវចនានុក្រមតែមួយភាសា (អង់គ្លេស-អង់គ្លេស) ទទួលបានកម្រិតល្អផងដែរ (មធ្យមភាគ = ៣.៨៥) និងចំណុចចុងក្រោយគឺ ការពន្យល់របស់គ្រូអំពីភាពខុសគ្នាឬដូចគ្នារវាងភាសាអង់គ្លេសនិងភាសាខ្មែរ គឺមានប្រយោជន៍នៅក្នុងការរៀនភាសាអង់គ្លេស ដោយទទួលបានកម្រិតល្អដូចគ្នា (មធ្យមភាគ = ៣.៧៦)។ សរុបមកសិស្សយល់ថា ការកត់ត្រាជាភាសាខ្មែរជួយពួកគេក្នុងការរៀនភាសាអង់គ្លេសឱ្យកាន់តែច្បាស់ល្អ ហើយការប្រើប្រាស់វចនានុក្រមដែលមានពីរភាសាមានប្រសិទ្ធភាពជាងវចនានុក្រមមួយភាសា។ មិនត្រឹមតែប៉ុណ្ណោះ សិស្សយល់ថាការបង្ហាញឱ្យឃើញពីភាពដូចគ្នា និងខុសគ្នារវាងភាសាខ្មែរនិងភាសាអង់គ្លេស គឺជួយពួកគេឱ្យរៀនភាសាអង់គ្លេសកាន់តែប្រសើរឡើងថែមទៀតផង។

**តារាង ៤.១២៖ ទិន្នន័យសរុប ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការយល់ឃើញរបស់សិស្សទាក់ទងនឹងការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់ភាសាអង់គ្លេស | ៣.៦៩ | ០.៥៩ | ល្អ |
| ២ | ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនភាសាអង់គ្លេស | ៣.៧៨ | ០.០៧ | ល្អ |

| | | | | |
|---|---|---|---|---|
| ៣ | ការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសា | ៤.១៣ | ០.០៤ | ល្អ |
| ៤ | ការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសា | ៣.៩៥ | ០.០៣ | ល្អ |
| ៥ | ការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរទៅលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស | ៣.៩២ | ០.២០ | ល្អ |
| **សរុប** | | **៣.៨៩** | **០.១៦** | **ល្អ** |

ទិន្នន័យខាងលើបង្ហាញពី មធ្យមភាគសរុបតាមផ្នែកទាំង ០៥ នៃការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស (មធ្យមភាគ = ៣.៨៩) ដែលទទួលបានកម្រិតល្អ។ សមាសភាគសរុបទាំង ០៥ទទួលបានកម្រិតល្អទាំងអស់ ដោយក្នុងនោះមាន ចំណុចទី១ គឺការយល់ឃើញរបស់សិស្សទាក់ទងទៅនឹងការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស (មធ្យមភាគ = ៣.៩១) ចំណុចទី២ គឺការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការរៀនបំណិនភាសាអង់គ្លេស (មធ្យមភាគ = ៣.៧៨ ) ចំណុចទី៣ គឺការយល់ឃើញរបស់សិស្សទៅលើការប្រើប្រាស់ភាសាខ្មែរក្នុងការរៀនសមាសភាគភាសា (មធ្យមភាគ = ៤.១៣) ចំណុចទី៤ គឺការយល់ឃើញរបស់សិស្សលើការប្រើប្រាស់ភាសាខ្មែរក្នុងអន្តរកម្មថ្នាក់រៀនភាសា (មធ្យមភាគ = ៣.៩៥) ហើយនិងចំណុចចុងក្រោយ គឺ ការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់ភាសាខ្មែរទៅលើការយល់ដឹងសម្ភារសម្រាប់រៀនភាសាអង់គ្លេស(មធ្យមភាគ = ៣.៩២)។ តាមទិន្នន័យនេះបង្ហាញថា សិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាយល់ថាភាសាខ្មែរបានដើរតួនាទីយ៉ាងសំខាន់ដែលប្រៀបបានដូចជាស្ពានមួយសម្រាប់ផ្សារភ្ជាប់នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ ក្នុងនោះ សិស្សចូលចិត្តឱ្យគ្រូរបស់ពួកគេប្រើប្រាស់ទាំងភាសាខ្មែរនិងអង់គ្លេសនៅក្នុងថ្នាក់ ហើយពួកគេយល់ថាភាសាខ្មែរ គឺជួយពួកគេក្នុងការរៀនបំណិនភាសា សមាសភាគភាសាអង់គ្លេស អន្តរកម្មថ្នាក់រៀន និងធ្វើឱ្យពួកគេមានការយល់ដឹងទៅលើសម្ភារសម្រាប់រៀនទៀតផង។

### ក្រាប ៤.៦៖ កម្រិតនៃការយល់ដឹងភាសាអង់គ្លេសរបស់សិស្សនៅពេលគ្រូប្រើប្រាស់ភាសាអង់គ្លេស




ទិន្នន័យនៃក្រាប ៤.៦ បានបង្ហាញឱ្យឃើញពីកម្រិតយល់ដឹងរបស់សិស្សនៅពេលដែលគ្រូប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។ ក្នុងនោះយើងឃើញថាកម្រិតដែលខ្ពស់ជាងគេគឺ មានសិស្សចំនួន ៣៧.២% ដែលអាចយល់ភាសាអង់គ្លេសពី ៤០-៥០% បន្ទាប់មកគឺ មានសិស្សចំនួន ៣៤.០% ដែលយល់ពីកម្រិត ៦០-៧៩%។ ចំណែកកម្រិតយល់ដឹងភាសាអង់គ្លេសចន្លោះពី ២០-៣៩% មានសិស្សចំនួន ១៧.២% និងមានសិស្សតែ ២.៨០% ប៉ុណ្ណោះដែលអាចយល់ភាសាអង់គ្លេសនៅកម្រិតខ្ពស់គឺពី ៨០-១០០%។ តាមទិន្នន័យបង្ហាញឱ្យឃើញថា សិស្សនៅកម្រិតមធ្យមសិក្សាមានការយល់ដឹងភាសាអង់គ្លេសកម្រិតមធ្យមទៅបង្គួរ តែទោះបីជាយ៉ាងណាក៏ត្រូវមានការយកចិត្តទុកដាក់និងពង្រឹងបន្ថែមទៀតដើម្បីឱ្យការសិក្សារៀនសូត្ររបស់សិស្សកាន់តែប្រសើរ តាមរយៈការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗដែលមានដូចជាក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនជាដើម។

ក្រាប ៤.៧៖ កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែររបស់សិស្សនៅក្នុងថ្នាក់រៀន




តាមទិន្នន័យក្រាប ៤.៧ បានបង្ហាញឱ្យឃើញពីកម្រិតភាគរយខុសៗគ្នានៃការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែររបស់សិស្សនៅក្នុងថ្នាក់រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។ ក្នុងនោះយើងឃើញថាភាគរយដែលមានកម្រិតខ្ពស់ជាងគេគឺ ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% និងភាសាខ្មែរ ៤០-៥៩% ទទួលបាន ៣៤.៤% ហើយការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ២០-៣០% និងភាសាខ្មែរ ៦០-៧៩% ទទួលបាន ៣២.៤%។ បន្ទាប់មកមានសិស្សចំនួន ១៥.៦% ប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ៦០-៧៩% និងភាសាខ្មែរពី ២០-៣៩% និងមានសិស្សចំនួន ១៥.២% បានប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ០-១៩% និងភាសាខ្មែរពី ៨០-១០០% ។ ចំណែកភាគរយដែលមានការប្រើប្រាស់តិចជាងគេគឺភាសាអង់គ្លេសចន្លោះពី ៨០-១០០% និងភាសាខ្មែរពីចន្លោះពី ០-១៩% ដែលទទួលបានចំនួន ២.៤០% ។ ទិន្នន័យខាងលើបង្ហាញថា សិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាភាគច្រើន (៦៦.៨%) បានប្រើភាសាខ្មែរពីកម្រិតមធ្យមទៅច្រើនបង្គួរ ហើយបានប្រើប្រាស់ភាសាអង់គ្លេសពីកម្រិតតិចទៅកម្រិតមធ្យម។ ជារួមលទ្ធផលនេះបានបង្ហាញឱ្យឃើញថាការរៀនមុខវិជ្ជាភាសាអង់គ្លេសមិនអាចដំណើរការទៅបានដោយគ្មានវត្តមាននៃការរួមបញ្ចូលភាសាកំណើតរបស់សិស្សនោះឡើយ។

## ក្រាប ៤.៨ ទំនាក់ទំនងរវាង កម្រិតថ្នាក់នៃការរៀនភាសាអង់គ្លេស និងការប្រើប្រាស់ភាសាអង់គ្លេស-ខ្មែរ




តាមទិន្នន័យក្រាប ៤.៨ បានបង្ហាញឱ្យឃើញពីកម្រិតភាគរយនៃការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែររបស់សិស្សានុសិស្សទាំងប្រាំមួយកម្រិត គឺពីថ្នាក់ទី៧ ដល់ទី១២។ តាមរយៈទិន្នន័យនេះបានបង្ហាញឱ្យឃើញថា សិស្សានុសិស្សភាគច្រើនប្រើប្រាស់អង់គ្លេសចន្លោះពី ២០-៥៩% និងភាសាខ្មែរពី ៤០-៧៩%។ ក្នុងនោះសិស្សថ្នាក់ទី៧ចំនួន ៤៧.១% បានប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% និងភាសាខ្មែរពី ៤០-៥៩% ដូចគ្នា ហើយកម្រិតបន្ទាប់សម្រាប់សិស្សថ្នាក់ទី៧ គឺប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ២០-៣៩% និងភាសាខ្មែរពី ៦០-៧៩%មានចំនួន ២៧.៥%។ ចំពោះថ្នាក់ទី៨ ការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរមានកម្រិតប្រហាក់ប្រហែលទៅនិងថ្នាក់ទី៧ផងដែរ ដោយការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% និងភាសាខ្មែរពី ៤០-៥៩% មានចំនួន ៤៥.១%។ បន្ទាប់មកការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ២០-៣៩% និងភាសាខ្មែរពី ៦០-៧៩% មានចំនួន ២៥.៥% និងកម្រិតបន្ទាប់ពីនេះគឺការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ៦០-៧៩% និងភាសាខ្មែរពី ២០-៣៩% មានចំនួន ២១.៦%។ ចំណែកសិស្សថ្នាក់ទី៩ កម្រិតភាគរយដែលប្រើប្រាស់ច្រើនជាងគេគឺភាសាអង់គ្លេសចន្លោះពី ២០-៣០% និងភាសាខ្មែរពី ៦០-៧៩% មានចំនួន ៤១.៤%។ ក្នុងនោះយើងឃើញថា សិស្សានុសិស្សនៅ

កម្រិតថ្នាក់ទី១០ គឺមិនខុសគ្នាប៉ុន្មានពីថ្នាក់ទី៩ឡើយ ដោយក្នុងនោះការប្រើប្រាស់ភាគច្រើនគឺ ភាសាអង់គ្លេសចន្លោះពី ២០-៣០% និងភាសាខ្មែរពី ៦០-៧៩% មានចំនួន ៤៣.៣% ហើយនៅក្នុងកម្រិតនេះសម្រាប់ថ្នាក់ទី១១ ក៏ជាកម្រិតខ្ពស់ជាងផងដែរ ដែលមានសិស្សចំនួន ៣៣.៣% បានប្រើប្រាស់។ សម្រាប់សិស្សថ្នាក់ទី១២វិញ ការប្រើប្រាស់ដែលមានភាគរយច្រើនជាងគេគឺភាសាអង់គ្លេសពី ០-១៩% និងភាសាខ្មែរចន្លោះពី ៨០-១០០% ដែលមានចំនួន ៥០.០%។ ជារួមយើងឃើញថា សិស្សានុសិស្សនៅកម្រិតថ្នាក់ទី៧ និងទី៨មានការប្រើប្រាស់ភាសាអង់គ្លេសខ្ពស់ជាងកម្រិតផ្សេងៗ។ សម្រាប់ទីសិស្សានុសិស្សថ្នាក់ទី៩ ទី១០ ទី១១ និងទី១២ មានការប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងកម្រិតប្រហាក់ប្រហែលគ្នា ដែលមានន័យថាសិស្សថ្នាក់ទី៧ និងទី៨ បានប្រើប្រាស់ភាសាខ្មែរតិចជាងកម្រិតថ្នាក់ផ្សេងៗទៀត។ ទោះបីជាមានកម្រិតខុសគ្នានៅក្នុងការប្រើប្រាស់ភាសាទាំងពីរនៅតាមកម្រិតថ្នាក់ក៏ដោយ យើងឃើញថាសិស្សានុសិស្សភាគច្រើនបានប្រើប្រាស់ភាសាខ្មែរពីកម្រិតមធ្យមទៅបង្គួរ ហើយភាសាអង់គ្លេសពីកម្រិតតិចតួចទៅមធ្យម។

**ក្រាប ៤.៩ កម្រិតភាគរយនៃការយល់របស់សិស្ស នៅពេលគ្រូបង្រៀនប្រើប្រាស់ភាសាអង់គ្លេសធៀបទៅតាមកម្រិតថ្នាក់**



ទិន្នន័យខាងលើនេះ បានបង្ហាញឱ្យឃើញពីកម្រិតភាគរយនៃការយល់របស់សិស្សានុសិស្ស នៅពេលគ្រូបង្រៀនប្រើប្រាស់ភាសាអង់គ្លេសធៀបទៅតាមកម្រិតថ្នាក់របស់ពួកគេ។ ក្នុងនោះយើងឃើញថាសិស្សថ្នាក់ទី៧ បានយល់ភាសាអង់គ្លេសចន្លោះពី ០-៣៩% មានចំនួន ៣៩.២% និងចន្លោះពី ៤០-៧៩% មានចំនួន ៦០.៧%។ សម្រាប់ថ្នាក់ទី៨ សិស្សានុសិស្សដែលយល់ភាសាអង់គ្លេសកម្រិតពី ៦០-៧៩% មានចំនួន៤៩.០% និងពីកម្រិត ៤០-៥៩% មានចំនួន២៩.៤%។ ចំណែកថ្នាក់ទី៩ គឺមានសិស្សចំនួន ៤៣.១% យល់ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% និងកម្រិតបន្ទាប់គឺ ៦០-៧៩% មានចំនួន ៣៤.៤%។ កម្រិតខ្ពស់សម្រាប់ថ្នាក់ទី១០ គឺចន្លោះពី ៦០-៧៩% មានចំនួន៤០.០% និងចន្លោះពី ៤០-៥៩% មានចំនួន ៣០.០%។ ចំណែកសិស្សថ្នាក់ទី ១១ និងទី១២ សិស្សភាគច្រើនមានការយល់ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% ដោយក្នុងនោះថ្នាក់ទី១១ មានចំនួន ៥០.០% និងថ្នាក់ទី១២ មានចំនួន ៤៦.៦%។ ទិន្នន័យខាងលើបង្ហាញថាសិស្សានុសិស្សភាគច្រើនអាចយល់ភាសាអង់គ្លេសពីកម្រិតមធ្យមទៅបង្គួរ (៤០-៧៩%) នៅពេលដែលគ្រូបង្រៀនរបស់ពួកគេប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។

**ក្រាប ៤.១០៖ ការយល់ឃើញរបស់សិស្សានុសិស្សទៅលើកម្រិតនៃការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស**



តាមក្រាប ៤.១០ បានបង្ហាញឱ្យឃើញពីទស្សនៈផ្សេងៗគ្នារបស់សិស្សានុសិស្សទៅលើកម្រិតនៃការប្រើប្រាស់ភាសាខ្មែរក្នុងថ្នាក់រៀនភាសាអង់គ្លេស។ ទិន្នន័យនេះបង្ហាញថា សិស្សានុសិស្សភាគច្រើនយល់ថាភាសាខ្មែរគួរប្រើនៅចន្លោះ ៤០-៥៩% គឺមានចំនួន ៤៤.០% ហើយនៅចន្លោះពី ២០-៣៩% មានចំនួន ៣១.២%។ ក្នុងនោះមានសិស្សចំនួន ១៥.២% យល់ថាភាសាខ្មែរគួរប្រើនៅចន្លោះពី ៦០-៧៩% និងមានសិស្សចំនួន ៦.៨០% យល់ថាភាសាខ្មែរគួរប្រើនៅចន្លោះពី ០-១៩% ហើយការយល់ថាភាសាខ្មែរគួរប្រើនៅចន្លោះពី ៨០-១០០% មានត្រឹមតែ ២.៨០% ប៉ុណ្ណោះ។ តាមរយៈទិន្នន័យនេះបានបង្ហាញឱ្យឃើញថាសិស្សនៅកម្រិតមធ្យមសិក្សាភាគច្រើន (៧៥.២%) យល់ថាភាសាខ្មែរគួរប្រើពីកម្រិតតិចទៅមធ្យមនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ ជារួមភាសាខ្មែរគួរត្រូវបានប្រើប្រាស់នៅក្នុងកម្រិតមួយឱ្យបានសមស្រប ពីព្រោះការប្រើប្រាស់ភាសាខ្មែរច្រើនពេកធ្វើឲ្យកម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេសបានតិចតួច ដោយសិស្សពឹងផ្អែកទៅលើតែភាសាកំណើតរបស់ពួកគេតែប៉ុណ្ណោះ ដែលកត្តានេះធ្វើឱ្យការអនុវត្តនៃការប្រើប្រាស់ភាសាអង់គ្លេសមិនសូវទទួលបានប្រសិទ្ធភាពខ្លាំងនោះទេ។

## ៤.៣ ការពិភាក្សាលើលទ្ធផល

នៅក្នុងផ្នែកនេះ លទ្ធផលសំខាន់ៗនៃការស្រាវជ្រាវ ត្រូវបានលើកយកមកបង្ហាញម្តងទៀត ដោយធ្វើការប្រៀបធៀបការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សានុសិស្សទៅលើការប្រើប្រាស់ភាសាខ្មែរនៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ក៏ដូចជាកម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរជាក់ស្តែងរបស់គ្រូបង្រៀន និងសិស្សផងដែរ។

### ៤.៣.១ លទ្ធផលនៃការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សលើការប្រើភាសាខ្មែរ

តាមរយៈការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាភាគច្រើនគឺចំនួន ៨១.០% យល់ថាភាសាខ្មែរគួរប្រើនៅចន្លោះពី ២០-៥៩% បើធៀបទៅនិងការយល់ឃើញរបស់សិស្សនៅចន្លោះភាគរយដូចគ្នានេះផងដែរ គឺមានចំនួន ៧៥.២%។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថាគ្រូបង្រៀន និងសិស្សានុសិស្សមានការយល់ឃើញប្រហាក់ប្រហែលគ្នាទៅលើការប្រើភាសាខ្មែរនៅក្នុងកម្រិតពីតិចទៅមធ្យមចំពោះការបង្រៀន និងការរៀនភាសាអង់គ្លេស។ ក្នុងនោះ

គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សភាគច្រើនមិនគាំទ្រទៅលើការប្រើប្រាស់តែភាសាអង់គ្លេសនៅក្នុងការបង្រៀន និងរៀននោះទេ ដោយសារតែការប្រើប្រាស់ភាសាខ្មែរដែលជាភាសាកំណើតរបស់សិស្ស គឺពិតជាជួយពួកគេប្រមូលធាតុចូលបានច្រើននៅពេលកំពុងរៀនក៏ដូចជាពេលអនុវត្តភាសានៃការប្រើប្រាស់ភាសាអង់គ្លេស។ ការរកឃើញនេះក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងការរកឃើញរបស់ Yadav (2014) និង Madriñan (2014) ផងដែរ។ សម្រាប់ជំនាញទាំងបួននៃភាសាអង់គ្លេសវិញ គ្រូបង្រៀនយល់ឃើញថាភាសាខ្មែរគឺជួយសិស្សក្នុងការរៀនជំនាញអាន និងសរសេរ ហើយចំពោះជំនាញស្តាប់ និងនិយាយ សម្រាប់ការប្រើភាសាខ្មែរគឺមិនសូវមានប្រសិទ្ធភាពនោះទេ ហើយការរកឃើញនេះក៏ស្របទៅនឹងការលើកឡើងរបស់ Savage (2021) ផងដែរ។ ចំណុចនេះសម្រាប់ការយល់ឃើញរបស់សិស្ស គឺមានលក្ខណៈខុសពីការយល់ឃើញរបស់គ្រូបង្រៀនបន្តិច ដោយសិស្សានុសិស្សយល់ថាភាសាខ្មែរគឺជួយពួកគេនៅក្នុងការរៀនជំនាញទាំងបួននៃភាសាអង់គ្លេសតែម្តង លទ្ធផលនេះគឺដូចទៅនឹងការរកឃើញរបស់ Nation (2001) និង Xhemaili (2016) ផងដែរ។ បន្ថែមទៅទៀតនោះ គ្រូបង្រៀនយល់ថា សិស្សគួរត្រូវបានអនុញ្ញាតឱ្យឆ្លើយតបដោយប្រើប្រាស់ភាសាខ្មែរនៅក្នុងកម្រិតមធ្យម និងយល់ថាភាសាខ្មែរជួយសិស្សក្នុងការធ្វើការងារជាក្រុមនៅក្នុងកម្រិតមធ្យមផងដែរ។ ចំណែកសិស្សវិញយល់ថាការប្រើប្រាស់ភាសាខ្មែរជួយពួកគេក្នុងការធ្វើការងារជាក្រុមបានល្អប្រសើរ។ សិស្សានុសិស្សយល់ថាពួកគេគួរត្រូវបានអនុញ្ញាតឱ្យឆ្លើយតបជាភាសាខ្មែរ ព្រោះការប្រើភាសាខ្មែរនេះធ្វើឲ្យពួកគេកាន់តែមានទំនុកចិត្តឡើង។ លទ្ធផលខាងលើនេះបានបញ្ជាក់ឱ្យឃើញថា គ្រូបង្រៀនភាសាអង់គ្លេសនិងសិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាបានចាត់ទុកថាភាសាខ្មែរដែលជាភាសាកំណើត គឺដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។

### ៤.៣.២ លទ្ធផលនៃប្រើភាសាអង់គ្លេស និងភាសាខ្មែររបស់គ្រូបង្រៀន និងសិស្ស

ការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើន ៥៧.១% ប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ៤០-៥៩% និងភាសាខ្មែរចន្លោះពី ៤០-៥៩% នៅក្នុងកម្រិតភាគរយនៃការប្រើប្រាស់នេះផងដែរ សិស្សមានចំនួនតែ ៣៤.៤% ប៉ុណ្ណោះ ហើយបន្ទាប់ពីនេះគឺមានសិស្សចំនួន ៣២.៤០% ដែលប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ២០-៣៩% និងភាសាខ្មែរចន្លោះពី ៦០-៧៩%។

ទិន្នន័យនេះបង្ហាញថាគ្រូបង្រៀនមានការប្រើប្រាស់ភាសាអង់គ្លេសច្រើនជាងសិស្ស ហើយភាសាខ្មែរតិចជាងសិស្ស។ ក្នុងនោះ គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ប្រើប្រាស់ភាសាអង់គ្លេសនិងភាសាខ្មែរពី ៤០-៥៩% មានចំនួន ៥៣.៣% ហើយនៅក្នុងកម្រិតភាគរយនៃការប្រើប្រាស់ដូចគ្នានេះផងដែរ គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ មានចំនួន ៥៩.៣%។ ការប្រើប្រាស់ភាសាអង់គ្លេសចន្លោះពី ២០-៣៩% និងភាសាខ្មែរចន្លោះពី ៦០-៧៩% សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន ៣៣.៣% ខ្ពស់ជាងគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិដែលមានត្រឹមតែ ១៨.៥% ប៉ុណ្ណោះ។ យោងតាមទិន្នន័យដោយផ្អែកទៅតាមបទពិសោធនៃការបង្រៀន គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើនប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរចន្លោះពី ៤០-៥៩%។ ចំណែកសិស្សវិញអាចយល់ភាសាអង់គ្លេសនៅក្នុងកម្រិតពី ៤០-៧៩% នៅពេលគ្រូប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។ សិស្សថ្នាក់ទី៧ និងទី៨ភាគច្រើនប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរពី ៤០-៥៩% ហើយថ្នាក់ទី៩ ទី១០ និងទី១១ ភាគច្រើនប្រើប្រាស់ភាសាអង់គ្លេសពី ២០-៣៩% និងភាសាខ្មែរពី ៦០-៧៩% ហើយសិស្សថ្នាក់ទី១២ភាគច្រើនប្រើប្រាស់ភាសាអង់គ្លេសពី ០-១៩% និងភាសាខ្មែរពី ៨០-១០០% និងកម្រិតបន្ទាប់គឺប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរចន្លោះពី ៤០-៥៩%។

សរុបរួមមកយើងឃើញថា គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សយល់ថាភាសាខ្មែរគួរប្រើប្រាស់នៅក្នុងកម្រិតពីតិចទៅមធ្យម ២០-៥៩% នៅក្នុងការបង្រៀន និងរៀននៅក្នុងថ្នាក់ភាសាអង់គ្លេស តែការអនុវត្តជាក់ស្តែងវិញគឺគ្រូបង្រៀន និងសិស្សប្រើប្រាស់ភាសាខ្មែរពីកម្រិតមធ្យមទៅច្រើនបង្គួរគឺ ៤០-៧៩%។ ការសិក្សាស្រាវជ្រាវនេះក៏បានបង្ហាញឱ្យឃើញថា ការប្រើប្រាស់ភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ ពីព្រោះការប្រើប្រាស់ស្ថិតនៅក្នុងកម្រិតតិចទៅមធ្យមប៉ុណ្ណោះហើយវាស្របទៅនឹងការលើកឡើងរបស់ (Kavaliauskiene, 2009) ដោយបង្ហាញថាការប្រើប្រាស់ភាសាកំណើតក្នុងបរិមាណច្រើនឬតិច គឺអាស្រ័យទៅលើភាពប៉ិនប្រសប់ឬស្ទាត់ជំនាញរបស់សិស្សនៅក្នុងភាសាអង់គ្លេស។

# ជំពូក ៥
# សេចក្តីសន្និដ្ឋាន
# និងសំណូមពរ

# ជំពូក ៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

គ្រូបង្រៀនមុខភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាយល់ថាការប្រើប្រាស់ភាសាកំណើត (ភាសាខ្មែរ) គឺមានសារៈសំខាន់សម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេស ហើយពួកគាត់យល់ថាការប្រើប្រាស់តែភាសាអង់គ្លេសនៅក្នុងការបង្រៀន គឺធ្វើឱ្យសិស្សគិតអ្វីមិនបានច្រើនជាភាសាអង់គ្លេសនោះទេ។ ក្នុងនោះការប្រើប្រាស់ភាសាខ្មែរ ក៏បានចូលរួមចំណែកជួយសិស្សក្នុងការរៀនជំនាញអាននិងជំនាញសរសេរភាសាអង់គ្លេសឱ្យកាន់បានល្អប្រសើរឡើង ពីព្រោះការអានត្រូវផ្សារភ្ជាប់ទៅនឹងខ្លឹមសារយ៉ាងសំខាន់ដែលទាមទារឱ្យគ្រូបង្រៀន និងសិស្សត្រូវប្រើប្រាស់ភាសាខ្មែរដើម្បីយល់ខ្លឹមសារនៃអំណានឲ្យតែស៊ីជម្រៅថែមទៀត។ សម្រាប់ជំនាញនៃការសរសេរវិញ គឺមានលក្ខណៈស្មុគស្មាញជាពិសេសគឺការប្រើប្រាស់វាក្យស័ព្ទនិងទម្រង់វេយ្យាករណ៍។ ក្នុងនោះភាសាខ្មែរក៏បានចូលរួមចំណែកជួយសិស្សនៅក្នុងការរៀនវាក្យស័ព្ទ និងវេយ្យាករណ៍ភាសាអង់គ្លេសផងដែរ ដែលប្រៀបបានជាទុនមួយសម្រាប់សិស្សរៀនជំនាញនៃការសរសេរនេះ។ ការសរសេរ គឺត្រូវគោរពទៅតាមក្បួនខ្នាតនៃវេយ្យាករណ៍ ដែលជាហេតុទាមទារឱ្យគ្រូបង្រៀនពន្យល់ឱ្យបានពិស្ដារនិងច្បាស់លាស់។ ហើយបើយើងក្រឡេកមើលទម្រង់វេយ្យាករណ៍ភាសាអង់គ្លេស និងទម្រង់នៃវេយ្យាករណ៍ភាសាខ្មែរ គឺមានលក្ខណៈស្រដៀងគ្នាភាគច្រើន។ ដូច្នេះគ្រូចាំបាច់ណាស់ត្រូវប្រើប្រាស់ភាសាខ្មែរ ដើម្បីជួយឱ្យសិស្សកាន់តែយល់ច្បាស់ ដូចពាក្យមួយបាននិយាយថា «អ្នកអាចនិយាយដោយគ្មានវេយ្យាករណ៍បាន តែអ្នកមិនអាចសរសេរដោយគ្មានវេយ្យាករណ៍បាននោះទេ»។ ទន្ទឹមនឹងនោះផងដែរ គ្រូបង្រៀនយល់ថា ការប្រើប្រាស់ភាសាខ្មែរ មិនសូវមានប្រសិទ្ធភាពលើការធ្វើការងារជាក្រុម ការអនុញ្ញាតឱ្យសិស្សឆ្លើយតប ការអនុវត្តជំនាញស្ដាប់ និងជំនាញនិយាយភាសាអង់គ្លេសនោះទេ។ ដោយគ្រូបានជំរុញសិស្សឱ្យពិភាក្សា និងផ្ដល់យោបល់ឱ្យគ្នាជាភាសាអង់គ្លេសឱ្យបានច្រើន និងព្យាយាមឱ្យពួកគេឆ្លើយតបដោយប្រើភាសាអង់គ្លេសឱ្យបានច្រើនតាមសមត្ថភាពជាក់ស្ដែង ហើយសម្រាប់ជំនាញស្ដាប់ និងនិយាយគឺត្រូវការហ្វឹកហាត់ និងការអនុវត្តជាភាសាអង់គ្លេសឱ្យបានច្រើនទើបមានប្រសិទ្ធភាពខ្ពស់។ ទិន្នន័យនេះក៏បានបង្ហាញឱ្យឃើញពីកម្រិតនៃការយល់ឃើញរបស់គ្រូបង្រៀន និងសិស្សទៅលើការប្រើប្រាស់ភាសាខ្មែរ

ធៀបទៅនឹងការប្រើប្រាស់ជាក់ស្តែងផងដែរ។ ដោយក្នុងនោះគ្រូបង្រៀនចំនួន ៨១.០% និងសិស្សចំនួន ៧៥.២% យល់ថាភាសាខ្មែរគួរប្រើចន្លោះពី ២០-៥៩% ចំណែកឯការប្រើប្រាស់ជាក់ស្តែងវិញ យើងឃើញថាគ្រូបង្រៀនចំនួន ៨០.៩% និងសិស្សចំនួន ៦៦.៨% បានប្រើប្រាស់ភាសាខ្មែរចន្លោះពី ៤០-៧៩%។

តាមរយៈការសិក្សាស្រាវជ្រាវនេះក៏បានបង្ហាញឱ្យឃើញថា នៅតាមសាលាកម្រិតមធ្យមសិក្សាមួយចំនួនមានការខ្វះគ្រូបង្រៀនមុខវិជ្ជាឯកទេសភាសាអង់គ្លេស ដែលនាំឱ្យមានការយកគ្រូមុខវិជ្ជាឯកទេសផ្សេង មានដូចជា គ្រូឯកទេសភាសាខ្មែរ គ្រូឯកទេសប្រវត្តិវិទ្យា គ្រូឯកទេសអប់រំកាយ និងកីឡា រហូតដល់មានការយកគ្រូកម្រិតបឋមសិក្សាមកជួយបង្រៀននៅកម្រិតមធ្យមសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដែលសាលានីមួយៗកំពុងជួបប្រទះ។

## ៥.២ សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ដើម្បីចូលរួមចំណែកលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែប្រសើរឡើងប្រកបដោយប្រសិទ្ធភាពខ្ពស់ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវគំនិតយោបល់ ព្រមទាំងសំណូមពរមួយចំនួនសម្រាប់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

### ក. ក្រសួងអប់រំយុវជន និងកីឡា

- ធ្វើការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សាឱ្យមានគុណភាពខ្ពស់ ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់សិស្សបន្តការសិក្សាឆ្លងភូមិសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព។
- បន្តជ្រើសរើសគ្រូមុខវិជ្ជាភាសាអង់គ្លេសបន្ថែមទៀត ដើម្បីបំពេញការខ្វះខាតគ្រូឬការខ្ចីគ្រូមុខវិជ្ជាឯទេសផ្សេងមកបង្រៀនជំនួស។
- ធ្វើការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស (សៀវភៅសិក្សាគោល) ឱ្យឆ្លើយតបទៅនឹងគោលនយោបាយអប់រំ។
- រៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនភាសាអង់គ្លេស ដើម្បីឱ្យទទួលបានវិធីសាស្ត្របង្រៀនថ្មីឆ្លើយតបទៅនឹងកម្មវិធីសិក្សាជាក់ស្តែង។

- បង្កើនពិន្ទុមុខវិជ្ជាភាសាបរទេសឱ្យដូចមុខវិជ្ជាដទៃទៀតសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីលើកទឹកចិត្តសិស្សានុសិស្សឱ្យខិតខំរៀនសូត្រ។
- ផ្តល់សម្ភារឧបទេសដល់គ្រូបម្រើការឱ្យការបង្រៀនឲ្យបានគ្រប់គ្រាន់ (ឧករណ៍ចាក់ស្តាប់មេរៀន ម៉ាស៊ីនបញ្ចាំងស្លាយ...)។
- ផ្សព្វផ្សាយពីសារៈសំខាន់នៃភាសាបរទេសដល់សិស្សានុសិស្សឱ្យបានយល់ដឹង និងលើកទឹកចិត្តពួកគាត់ឱ្យខិតខំប្រឹងរៀនសូត្រ។

### ខ. មន្ទីរអប់រំ យុវជន និងកីឡា/ក្រុង

- ពិនិត្យតាមដាន និងវាយតម្លៃលើសកម្មភាពនៃការអនុវត្តគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- ជំរុញលើកទឹកចិត្តគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សឱ្យបន្តខិតខំប្រែងធ្វើការ និងសិក្សារៀនសូត្រ។

### គ. សម្រាប់នាយកសាលា

- ណែនាំ និងបែងចែកសៀវភៅសិក្សាគោល និងសម្ភារឧបទ្ទេសសម្រាប់គាំទ្រដល់ការបងៀន។
- លើកទឹកចិត្តបុគ្គលិកសិក្សា និងសិស្សដែលមានស្នាដៃតាមរយៈការផ្តល់ប័ណ្ណសរសើរ ឬរង្វាន់លើកទឹកចិត្តផ្សេងៗ។
- ពង្រឹងបទបញ្ជាផ្ទៃក្នុងរបស់សាលាប្រកបដោយប្រសិទ្ធភាពខ្ពស់។
- សម្របសម្រួលដោយបង្កភាពងាយស្រួលដល់បុគ្គលិកដែលចង់បន្តការសិក្សាបង្កើនគុណវឌ្ឍិ។

### ឃ. សម្រាប់គ្រូបង្រៀន

- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីបានជាពុទ្ធិក្នុងការចែករំលែកចំណេះដឹងដល់សិស្ស ហើយជាពិសេសគឺផ្នែកវិធីសាស្រ្តបង្រៀនភាសាអង់គ្លេស។
- បន្តអភិវឌ្ឍគុណវឌ្ឍិឱ្យសមស្របតាមគោលនយោបាយអប់រំ។
- ពង្រឹងចំណេះដឹងឯកទេសឱ្យកាន់តែល្អប្រសើរឡើង។

- ស្វ័យសិក្សាស្រាវជ្រាវទាក់ទងទៅនឹងជំនាញឯកទេសឱ្យបានស៊ីជម្រៅ។

**ង. សម្រាប់សិស្ស**

- ត្រូវមានវិន័យ និងលើកចិត្តខ្លួនឯងជានិច្ច។
- ស្វ័យសិក្សាស្រាវជ្រាវឱ្យបានច្រើន។
- ពង្រឹងសមត្ថភាពផ្នែកភាសាអង់គ្លេសឱ្យល្អ ដើម្បីត្រៀមខ្លួនបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ឬការចាប់យកជំនាញណាមួយនាពេលអនាគត។

**ច. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត**

អ្នកសិក្សាស្រាវជ្រាវបានសិក្សាស្វែងយល់ពីការយល់ឃើញ និងពីកម្រិតនៃការប្រើប្រាស់ភាសាខ្មែរសម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាក្នុងស្រុកបាធាយ ខេត្តកំពង់ចាមតែប៉ុណ្ណោះ ដូច្នេះអ្នកសិក្សាស្រាវជ្រាវបន្ត គួរពង្រីកសំណាកនៃការស្រាវជ្រាវបន្ថែមទៀតដោយផ្តោតទៅលើ៖

- កម្រិតសមត្ថភាពនៃការប្រើប្រាស់ភាសាអង់គ្លេសរបស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា ឬមធ្យមសិក្សា។
- កម្រិតសមត្ថភាពនៃការប្រើប្រាស់ភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សា។

# ឯកសារយោង

# ឯកសារយោង


ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍. (២០២២). *គោលនយោបាយរដ្ឋាភិបាលកម្ពុជាឌីជីថល.* ភ្នំពេញ: ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *រាជរដ្ឋាភិបាល គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). *គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា. (២០១១). *ឯកសារអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ និងទី១២.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ. (២០០៤). *គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

ណាត, ស. ជ. (១៩៦៧). *វចនានុក្រមខ្មែរភាគទី១ ក-ម.* ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត.

Afzal, S. (2013). Using of the First Language in English classroom as a way of scaffolding for both the students and teachers to learn and teach English. *International Research Journal of Applied and Basic Sciences* , 1846-1854.

